ជូ · ថាន់

# កម្រងសរសេរតាមសូត្រ

**សម្រាប់:**

**មធ្យមសិក្សា**

មានអត្ថបទខ្លះសិស្ស
បានប្រឡងកាលពី
ឆ្នាំមុនៗរួចហើយ ។

បណ្ណាគារ
ឃាក់-ឃេង ភ្នំពេញ

**មាន:**

- ៥០ អត្ថបទសំរាំង
- ការពន្យល់ពាក្យ
- វេវចនសព្ទ
- សទិសសព្ទ
- អក្ខរាវិរុទ្ធ
- កំណត់ចំណាំផ្សេងៗ
- សំនួរ

CA 22

le 11-10-62

[signature]

ភិក្ខុសង្ឃជម្រៀនរ.
THÍCH-CHƠN-NHƯ. TỲ-KHƯU
釋真如. 比丘

ដូ-ថា ជី

# កម្រងសរសេរតាមសូត្រ

សម្រាប់

- វិទ្យាល័យ- អនុវិទ្យាល័យ
- ការប្រឡងសញ្ញាប័ត្រមធ្យមសិក្សា
- ការប្រឡងប្រជែងចូលធ្វើការផ្សេងៗ

មាន

- អត្ថបទសំរាំង
- ការពន្យល់ពាក្យ
- វេវចនស័ព្ទ
- សទិសស័ព្ទ
- អក្ខរាវិរុទ្ធ
- កំណត់ចំណាំផ្សេងៗ
- សំនួរ

**អត្ថបទខ្លះសិស្សបានប្រឡងកាលពីឆ្នាំមុនៗរួចហើយ**

ការផ្សាយរបស់

បណ្ណាគារហាក់-ហេង

ភ្នំពេញ

# លំដាប់អត្ថបទ

ឈ្មោះអត្ថបទ | ទំព័រ


- ព្រះរាជអាណាចក្រខ្មែរពីបុរេកាលមកទល់នឹងសតវត្សរ៍ទី ១១ ... ១
- អំពីបារាំងចូលមកកាន់ប្រទេសកម្ពុជា ... ៨
- គោលវិធីនៃការសិក្សាខ្មែរ ... ១៥
- យុវជននឹងបញ្ហាសិក្សា ... ២៥
- អង្គការសហប្រជាជាតិ ... ៣៣
- វត្ថុបំណងនឹងគោលច្បាប់នៃសហប្រជាជាតិ ... ៤១
- យុវជននឹងសន្តិភាព ... ៤៩
- ការបំរើនក្នុងផ្លូវនៃយុវជនយើង ... ៥៥
- អារ្យធម៌នៅសុវណ្ណភូមិ ... ៦៤
- បន្ទាយលង្វែក ... ៧២
- យុវជននឹងការប្រឡង ... ៨០
- សាលារៀនជាទីហ្វឹកហ្វឺនដើម្បីប្រកបជីវភាពក្នុងសង្គម ... ៨៩
- វិជ្ជានឹងសីលធម៌ ... ៩៧
- ជម្លោះថ្មីនៃមនុស្សបុរាណនឹងមនុស្សទំនើប ... ១០៤
- ជម្លោះថ្មីនៃមនុស្សបុរាណនឹងមនុស្សទំនើប ( តបច់ ) ... ១១៤
- ឥទ្ធិពលនៃវិទ្យាសាស្ត្រ ... ១២៣

— ជោគជ័យថ្មីនៃមនុស្សជាតិ ១៣៣
— មហាវិទ្យាល័យឡូម្ហូណូស្សូវ ១៤២
— មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត ១៤៩
— សេចក្ដីថ្លែងការរួមនៃប្រទេសកម្ពុជា
នឹងប្រទេសចិនប្រជាមានិត ១៥៩
— សន្ធិសញ្ញាមេត្រីភាពខ្មែរចិន ១៦៩
— សិល្បៈនឹងជីវភាពមនុស្សជាតិ ១៧៩
— អ្នកនិពន្ធនឹងអក្សរសាស្ត្រ ១៨៧
— ភារកិច្ចនៃសារពត៌មាន ១៩៦
— ឯករាជ្យ ២០៤
— លទ្ធិប្រជាធិបតេយ្យ ១១០
— បុណ្យពិធីរណ៌កសិកម្មជាតិ ២១៦
— បុណ្យសិទ្ធិមនុស្ស ២២៤
— មនុស្សធម៌ ២៣២
— វឌ្ឍនធម៌ ២៤១
— សង្គហធម៌ ២៤៧
— ស្រុកកូសាំងស៊ីន ២៥៦
— ជីវិតសាបសូន្យក្នុងអាថ៌កំបាំងលើនាវា ២៦៥
— បុណ្យភ្ជុំបិណ្ឌ ២៧៤
— ដំណើរឆ្លងកាត់ឆ្លបនឹងបេតប្រុក្រ ២៧៤
— រឿងឧបកនឹងស្គរ ២៩៥

— ចប់ —

# សេចក្ដីកែតម្រូវ

ដោយមានការភ្ញាំងភ្ញាត់ខ្លះខាងបច្ចេកទេសនៃការបោះពុម្ពផ្សាយ ដែលជាកំហុសរបស់រោងពុម្ព សូមអស់លោក-អ្នកទាំងមេត្តាកែតម្រូវពាក្យខុសទាំងឡាយក្នុងសៀវភៅនេះសិន មុននឹងយកទៅប្រើប្រាស់ ។

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|
| ១ | ១១ | ជ័យវ័ន្តន | ជ័យវ័ន្ត |
| ២ | ៧ | ស្រម័យ | សម័យ |
| ២០ | ៣ | សម្ភាះ | សម្ភារៈ |
| ៣៩ | ២ | ឧបត្ថម | ឧបត្ថម្ភ |
| — | — | ឧបត្ថមកៈ | ឧបត្ថម្ភកៈ |
| ១ | ៥ | ឧបត្ថម | ឧបត្ថម្ភ |
| — | ១១ | ឧបត្ថមកៈ | ឧបត្ថម្ភកៈ |
| ៤២ | ១២ | អន្តជាតិ | អន្តរជាតិ |
| ៥៩ | ៥ | អធិបតេយ្យភាព | អធិបតេយភាព |
| ៦២ | ២ | រដ្ឋបវេណី | រដ្ឋប្បវេណី |

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|
| ៧៦ | ២ | បរាជ័យភាព | បរាជយភាព |
| ៩៧ | ៧ | អបរំ | អប់រំ |
| ១០៩ | ១ | ឫកពារ | ឫកពា |
| ១៣១ | ១៤ | សម្លេង | សំឡេង |
| ១៣៩ | ៤ | គយគត់ | គន់គូរ |
| ១៣២ | ៤ | សស្ត្រាល្បែង | សាស្ត្រាល្បែង |
| ១៤០ | ១៤ | សម្លេង | សំឡេង |
| ១៦៧ | ១ | អព្យាក្រិត្យភាព | អព្យាក្រិតភាព |
| ១៩៧ | ៦ | អយត្តិធម៌ | អយុត្តិធម៌ |

# ពាក្យបំប្រួញសម្រាប់ប្រើក្នុងសៀវភៅនេះ

| ពាក្យបំប្រួញ | ត្រូវមើលថា |
|---|---|
| ន. | នាមស័ព្ទ |
| គុ. | គុណស័ព្ទ |
| កិ. | កិរិយាស័ព្ទ |
| កិ.វិ. | កិរិយាវិសេស |
| ឧ. | ឧទាហរណ៍ |
| បុំ. | បុំលិង្គ |
| ឥ. | ឥត្ថីលិង្គ |
| ឯក. | ឯកវចនៈ |
| ពហុ. | ពហុវចនៈ |
| ម. | មគធៈ |
| សំ. | សំស្រ្កឹត |
| ម.ថ. | មើលថា |

| | |
|---|---|
| រ.ស. | ភជស័ព្ទ |
| + | ផ្សំនឹង-បូកនឹង |
| < | មកពី, ក្លាយមកពី |
| > | ទៅជា, បានជា |
| = | ត្រូវជា ។ |

# ព្រះរាជអាណាចក្រខ្មែរពីបឋមកាល
# មកទល់នឹងសតវត្សទី ១១

ប្រវត្តិសាស្ត្រនៃប្រទេសខ្មែរចាប់កំណើតតាំងពីដើមគ្រិស្តសករាជ មកទល់នឹងគ្រិស្តសករាជទី ៦ ។ ប្រទេសដែលមាននាមថាហ្វូណន ហើយដែលនៅជាខាងត្បូងប្រទេសខ្មែរបច្ចុប្បន្ននេះ មានព្រំដែនឆ្ងាយទូលាយណាស់ ទៅដល់ភាគមួយចំណែកធំនៃប្រទេសថៃនិងកោះម៉ាឡាយូ ។ តែពត៌មានជាគោលរឿងនេះក៏បានមកតែពីការនិពន្ធ ដែលមិនសូវជាពិស្តារសព្វគ្រប់របស់អ្នកប្រវត្តិសាស្ត្រជាតិចិន ។

រជ្ជកាលអង្គរក៏មានកំណើតក្នុងរវាងគ្រិស្តសករាជ ៨០២ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ២ ។ ៧៥ ឆ្នាំក្រោយពីនោះមកក៏ព្រះបាទឥន្ទ្រវរ្ម័ន ដែលទ្រង់បានកសាងសិលាប្រាសាទជាលើកដំបូង និងទំនប់ទឹកធំផងនោះ ព្រះអង្គបានគ្រងរាជ

សម្បត្តិលើអាណាចក្រ ដែលមានព្រំដែន ពីខេត្រមាត់ជ្រូក "ចូវដុក" ទៅទល់នឹងខុបុល "ខុបោន„ ។

មានសេចក្ដីនៅលើសិលាចារឹកមួយបានថែងថា ៖ " ការគ្រប់គ្រងនៃមហាក្សត្រអង្គនេះ បីដូចជាកម្រងផ្កាម្លិះមួយដែលពាសទៅលើព្រះកេសនៃព្រះរាជាប្រទេសចិនចម្ប៉ានឹងជ្វា ដែលទ្រង់តែងប្រកបតែដោយការឈ្លានពាន„ ។ បានសេចក្ដីថា ក្នុងស្រម័យនោះមានមហាអំណាច ៤ តាំងនៅក្នុងទ្វីបអាស៊ីបូព៌ាគឺ ៖

- ប្រទេសចិនក្នុងរជ្ជកាល " តាំង„ ព្រះរាជអាណាចក្រចម្ប៉ា ដែលមានព្រះរាជធានីមាននាមថា "ឥន្ទ្របុរៈ" សព្វថ្ងៃនេះគឺឈ្មោះ "ក្វាងណាម" រាជាណាចក្រមាត់រាម " ជ្វា" នឹងស្រីវិជ័យ "ស៊ូម៉ាត្រា" នឹងរាជាណាចក្រខ្មែរ ។

ក្នុងរជ្ជកាលព្រះបាទសុរិយាវរ្ម័នទី ១ " ១០០២-១០៥០"

រាជាណាចក្រខ្មែរ មានព្រំដែនរហូតដល់ភូមិភាគខាងលិចនឹងខាងត្បូងនៃដែនកូសាំងស៊ីន ត្រើយទន្លេមេគង្គ នឹងត្រើយទន្លេមេណាម ។

សម្តេចចៅហ្វាវាំង ប៉ែន-នុត

## ពន្យល់ពាក្យ

រាជាណាចក្រ = (<រាជ+អាណាចក្រ) ន. អំណាចនៃការគ្រប់គ្រងប្រទេសដែលនៅក្រោមអំណាច នៃព្រះរាជា (Royaume) ។

បឋមកាល (<បឋម=ដំបូង+កាល) ន. កាលដំបូង ។

សតវត្ស ឬ សតវត្សរ៍ = ន. ពេលកំណត់ ១០០ ឆ្នាំ (Siècle) ។

សករាជ =(ម.ថ.ស័ក-ក្រាច) ន. ការរាប់ឆ្នាំតាមកាលកំណត់ដែលតាំងទុកពីមួយរៀងមក ដោយមានបុគ្គលអស្ចារ្យឬដោយមានហេតុអស្ចារ្យណាមួយ ដែលបណ្ដាអ្នក

គោរពត្រូវកត់ត្រាទុកមិនឲ្យបាត់ ។ គ្រិស្តសករាជ

ការកំណត់ឆ្នាំតាមសាសនាគ្រិស្ត (Ere chrétienne) ។

អ្នកប្រវត្តិសាស្ត្រ = ន. អ្នកកត់ត្រារឿងរ៉ាវរបស់ប្រទេស (Historien) ។

រជ្ជកាល. = (ម ចំ.រ៉ជ–ជ:–កាល) ន. កាលដែលព្រះមហាក្សត្រ អង្គនិមួយ ៗ គ្រងរាជ្យ (Règne) ។

ព្រះកស = (រ.ស) ន. ក្បាល ។

រាជធានី = ន. ទីក្រុងធំនៃប្រទេសណាមួយ ដែលព្រះមហាក្សត្រ គង់នៅ (Capitale) ។

សិលាប្រាសាទ = (<សិលា=ថ្ម+ប្រាសាទ) ន. ប្រាសាទដែល ធ្វើអំពីថ្ម ។

សិលាចារឹក = សេចក្ដីដែលចុះចម្លាក់នៅលើថ្ម ។

THICH-CHƠN-NHƯ, TY-KHƯU

វេវចនស័ព្ទ

ប្រទេស-ស្រុក-នគរ-ដែន-រដ្ឋ ។

សទិសស័ព្ទ

## ស័ក-សក្ក-សក្តិ-សាក់-សក្យ

ស័ក= ន-កាល, សម័យ, យុគ, ការរាប់ជាលំដាប់ឆ្នាំ ។

សក្ក ឬ សក្ក = (ម.ប.ស័ក–កៈ) ន. ពួកសាក្យ, សាក្យរាជ, ព្រះសាក្យមុនី ។ល។ ...

សក្តិ ឬ ស័ក្តិ = (ម-ប.ស័ក) ន.អំណាច, កម្លាំង, សក្តិយស, បុណ្យសក្តិ, សក្តិគួប, សក្តិធំ, សក្តិស្មើគ្នា, សង្គមសក្តិភូមិ ។

សាក់= កិ. ចាក់ដោយម្ជុល ឬដែកស្រួចបញ្ចូលទឹកខ្មៅទៅក្នុង សាច់=មនុស្សជាន់ដើមច្រើនតែសាក់ពេញខ្លួន ។

សក្យ ឬ សាក្យ = ( ម.ឋ-ស័ក-ក្យ៉ៈ ឬ សា-ក្យ៉ៈ ) ន. ជនមួយពួកនៅក្នុងដែនសក្កៈ (ក្នុងប្រទេសឥណ្ឌា) ។

អក្ខរាវិរុទ្ធ

បច្ចុប្បន្ន (ច្ចុ-ប្ប-ន្ន) ; គ្រិស្ត (ស្ត) ; រដ្ឋកាល (រដ្ឋ) ;

ចំណាំ

**និពន្ធ៍ – និពន្ធ**

ពាក្យពីរម៉ាត់នេះជាសន្ទានពាក្យ , តែមួយជានាមស័ព្ទ មួយជាកិរិយាស័ព្ទ ឬ គុណស័ព្ទ ។

និពន្ធ៍ = ជានាមស័ព្ទ មានន័យថា: ការសរសេរ , ការបង្គ្រង, ការតែង , ប្រឌិត ។

និពន្ធ = ជាគុណស័ព្ទ សម្រាប់ប្រើផ្សំនឹងពាក្យ អ្នក = អ្នកនិពន្ធ ។

ពាក្យនេះប្រើជាកិរិយាស័ព្ទក៏បាន មានន័យថា: បង្គ្រង, រៀបរៀង, តែង, ប្រឌិត ។

## សំណួរ

១ – ចូរពន្យល់ពាក្យៈ ប្រវត្តិសាស្ត្រ, គ្រិស្តសករាជ, រជ្ជកាល, រាជធានី ។

២ – ចូររកសទិសស័ព្ទនៃពាក្យៈ សាស្ត្រ ។

៣ – ចូររកវេវចនស័ព្ទនៃពាក្យៈ វង្ស ។

៤ – ចូរសម្ពន្ធប្រយោគទី ១ នៃអត្ថបទនេះ ។

៥ – តើអ្នកនិពន្ធអត្ថបទនេះមានឧត្តមគតិដូចម្តេច ?

# អំពីបារាំងចូលមកកាន់ប្រទេសកម្ពុជា

កងកម្លាំងទ័ពបារាំងដែលបានធ្វើសកម្មភាពក្នុងដែនកូសាំង-ស៊ីន ក្នុងគ្រិស្តសករាជ ១៨៦១ ទើបនឹងវាយយកដែននេះទាំងមូលបានលើកខែត្រវិញឡុង, បូរជុក, នឹងហាទៀន ដែលជាអាណាចក្ររបស់ខ្មែរ ហើយដែលគង់នៅក្នុងកណ្តាប់ដៃយួននៅឡើយ តែខែត្រទាំង ៣ នេះ ក៏បានបញ្ចូលក្នុងអាណាខេត្តអាណានិគមបារាំងក្នុងគ្រិស្តសករាជ ១៨៦៧ ដែរ ។

ក្នុងគ្រិស្តសករាជ ១៨៦១ ឧត្តមនាវីសាណែរបានចាត់បំរើមួយនាក់ ឲ្យមកថ្វាយសេចក្តីព្រះបាទសម្តេចព្រះនរោត្តម ពីបំណងរបស់បារាំងចំពោះដែនកូសាំងស៊ីន ។ ក្នុងពេលសន្ទនាការអ្នកបំរើនោះបានថ្វាយសេចក្តីព្រះមហាក្សត្រថា គោលបំណងរបស់ឧត្តមនាវីនោះ គឺសុំកុំឲ្យប្រទេសកម្ពុជាមានជាប់ចំណងស្ពានមេត្រីនឹងជាតិបរទេសណាឡើយ ហើយដរាបណាប្រទេសកម្ពុជា

មិនមានជាប់ចំណងស្ពានមេត្រីនឹងជាតិបរទេសនានា , ដរាបនោះ បារាំងនឹងនៅជាមិត្តស្និតស្នេហ៍នឹងខ្មែរបាន ។

ប៉ុន្តែបារាំងមានបារម្ភភ្លាម គឺសេចក្តីប៉ុនប៉ងរបស់សៀមចំពោះប្រទេសខ្មែរ ។ ដោយហេតុនេះហើយ បានជាក្នុងខែកក្កដា គ្រិស្តសករាជ ១៨៦៣ ឧត្តមនាវីឡាក្រង់ឌីយែរជាគូវែរណឺយោធាណាពលនៅដែនកូសាំងស៊ីន បានទូលស្នើដល់ព្រះបាទសម្តេចព្រះនរោត្តម សុំឲ្យប្រទេសកម្ពុជានៅក្នុងការគ្រប់គ្រងប្រទេសបារាំងសែស ។ ព្រះបាទសម្តេចព្រះនរោត្តមក៏ព្រះអង្គទ្រង់ព្រះរាជតម្រិះយល់ព្រមតាមសេចក្តីស្នើសុំនេះ ។ សន្ធិសញ្ញាស្តីពីការគ្រប់គ្រងប្រទេសកម្ពុជានេះ ក៏បានទទួលសច្ចាប័នពីប្រទេសបារាំង ក្នុងខែមិនា គ្រិស្តសករាជ ១៨៦៣ ។ ចំណែកសៀមក៏មានការក្រេវក្រោធឡើងដែរ ដោយយល់ថាចំណងជាឧក្រិដ្ឋរបស់ខ្លួនចំពោះប្រទេសខ្មែរនោះ ត្រូវរលាយសាបសូន្យដូចអំបិលត្រូវទឹក ។

តែជាការកុសលមួយ ក្នុងពេលដែលប្រទេសបារាំងបង្កើតនូវសំ
ខេបញ្ញាក់លក្ខខ័ណ្ឌឲ្យច្បាស់លាស់ពីព្រំប្រទល់ដែនខ្មែរ ព្រោះ
បារាំងច្រើនតែពាញ់បោកមន្ត្រីយួននឹងរដ្ឋាភិបាលសៀម ហើយ
ជាពិសេសទៅទៀត នាំឲ្យខូចប្រយោជន៍ដល់ជនជាតិដែលនៅ
ក្នុងអាណាព្យាបាលខ្លួន គឺខ្មែរយើងនេះជាច្រើន ។

សម្ដេចចៅហ្វាវាំង ប៉ែន-នុត

## ពន្យល់ពាក្យ

សកម្មភាព= ន. ដំណើរការដែលចេះតែមានបន្តបន្ទាប់គ្នាមិន
ដែលដាច់ (Activité) ។

អាណានិគម = ន. ប្រទេសដែលនៅក្រោមការត្រួតត្រារបស់
ប្រទេសដទៃ (Colonie) ។

អាណានិគមនិយម =ន. លទ្ធិដែលនិយមយកប្រទេសគេដាក់
ជាចំណុះប្រទេសខ្លួន (Colonialisme) ។

ឧត្តមនាវី = ន. នាយទាហានជាន់ខ្ពស់ខាងជើងទឹក (Amiral)

ស្ថិតស្ថេរ = គុ. ដែលតាំងនៅបានយូរអង្វែង ។

សន្ធិសញ្ញា = ន. សេចក្ដីសំគាល់ជាលក្ខណ្ឌ, សញ្ញាសំគាល់

ជាគោលចំពោះគ្នានឹងគ្នា (Traité) ។

សច្ចាប័ន = ន. ការយល់ស្របឥតលើកលែង (Ratification) ។

អាណាព្យាបាល = ន. ការគ្រប់គ្រង, ថែរក្សា (Tutelle)

លក្ខខណ្ឌ = ន. កំណត់, គោល, ព្រំ ។

បំណងឧក្រិដ្ឋ = បំណងអាក្រក់ ។

សទិសស័ព្ទ

## អង្គ - អង់

អង្គ = (ម.ថ.អង់) ន. អវយវៈ, រូប, កាយ, ពងកាយ ខ្លួន

ប្រាណ ។

អង្គ = ន. អង្គជាតព្រះឥសូរ ឬ សិវលិង្គ ។

អង្គ = ន. ឬ បុ.ស. នាក់ រូប, ខ្លួន, ទ្រង់ ។

អង់ = កិ. រង់, រង់ចាំ, ឈប់ចាំ = អង់ចាំ, អង់មួយស្របក់ ។

អង់អាប = គុ. ក្លាហាន, ឥតភ្លឹក, ឥតញាញើត ។

កុំច្រឡំនឹងពាក្យមួយទៀតគឺ អង្ក ឬ អង្ក := គ្រឿងសំគាល់, គ្រឿងចំណាំ ។ ត្រូវអានថា "អង់-ក:" មិនមែនអាន " អង់ " ទេ ។

## ជន - ជន្ម - ជន់

ជន = (ម.បិ-ជន់) ន. សព្វសត្វដែលកើតក្នុងលោក, មនុស្ស, អ្នកផង ។

ជន្ម = (ម.ប.ជន់) ន. ជីវិត = ជីពជន្ម, ព្រះជន្ម ។

ជន់ = កិ - ឡើងសាយភាយ = ទឹកជន់ ។

កុំច្រឡំនឹងពាក្យ ជិង ប្រដាប់ទេសាចមួយយ៉ាង

ដែលអានថា " ជិង " មិនមែនអានថា " ជិង់ " ទេ ។

## អក្ខរាវិរុទ្ធ

ខេត្ត ឬ ខែត្រ ។ កំឡាំង ឬ កម្លាំង ។

សថ្ឋា ( សថ្ឋា ) ។ ឧក្រិដ្ឋ ( ដ្ឋ ) ។ សូន្យ ( ន្យ ) ។

សកម្មភាព ( កម្ម ) ។

## សំនួរ

១– ចូរពន្យល់ពាក្យៈ អាណាព្យាបាល, អាណានិគម, សថ្ឋាប័ន, ឧក្រិដ្ឋ, សន្និសញ្ញា ។

២ – ចូរសម្ពន្ធប្រយោគបុងក្រោយបង្អស់របស់ 2
អត្ថបទនេះ ។

៣- ចូររកសទិសស័ព្ទរបស់ពាក្យ : អន្ធ ។

៤- ចូររកវេវចនស័ព្ទនៃពាក្យ : អ្នកបំរើ ។

៥- អ្នកមានយោបល់យ៉ាងណា ក្រោយដែលបាន អានអត្ថបទនេះ ? ។

# គោលវិធីនៃការសិក្សាខ្មែរ

ការសិក្សាខ្មែរត្រូវស្ថិតនៅលើវិទ្យាសាស្ត្រ និងមានលក្ខណៈជាតិជាមូលដ្ឋាន ។

ការអនុវត្តន៍ នូវគោលវិធីដែលបណ្ដុះការសិក្សាខ្មែរលើវិទ្យាសាស្ត្រ និងនាំឲ្យមានការខ្វះខ្វែង ខំបង្កើតទុកន្លែង , ទិញគ្រឿងប្រដាប់និងសម្ភារៈសម្រាប់បង្រៀនវិទ្យាសាស្ត្រ ព្រមទាំងធ្វើការពិសោធន៍ ដើម្បីធ្វើឲ្យការសិក្សាវិទ្យាសាស្ត្របានលទ្ធផលពេញទំហឹង ពីព្រោះការសិក្សាដែលពុំស្ថិតនៅលើប្រត្យក្សពិសោធន៍ ពុំអាចបណ្ដុះយោបល់យល់ឃើញ និងបង្កើតសេចក្ដីស្នេហាចំពោះវិជ្ជាអរូបិយបានឡើយ ។ ក្នុងពេលដែលផែនការ ៥ ឆ្នាំសង្កត់តម្លៃទៅលើឧស្សាហកម្មជាតិ , ការសិក្សាវិទ្យាសាស្ត្រឲ្យចេះពិតប្រាកដ ព្រមទាំងឲ្យទាន់ពេលវេលាដ៏ឆាប់រហ័ស គឺជាការចាំបាច់ ហើយជាភារកិច្ចមួយដ៏សំខាន់ក្រៃលែង ។

ការអនុវត្តន៍នូវគោលវិធីទី ២ ដែលបណ្ដុះការសិក្សាខ្មែរនៅលើលក្ខណៈជាតិ  នឹងផ្ដល់នូវលទ្ធផលល្អដូចជាការបង្កើតចិត្តជាតិនិយម  ពោលគឺចិត្តស្រឡាញ់ជាតិ, សាសនា, ព្រះមហាក្សត្រជាដើម ។

លក្ខណៈជាតិនៃការសិក្សាខ្មែរ នាំឲ្យអនុវត្ត នូវកម្មវិធីសិក្សាជាតិ ព្រមទាំងនាំឲ្យយើងដោះស្រាយបញ្ហា នឹងឧបសគ្គផ្សេង ៗ នៅក្នុងក្របខណ្ឌជាតិ នៃរដ្ឋឯករាជនេះឯង ។ ក៏ប៉ុន្តែលក្ខណៈជាតិ ពុំត្រូវបំពួនការសិក្សាខ្មែរឲ្យស្ថិតនៅម្នាក់ឯងពុំស្គាល់ វប្បធម៌សាកលនោះដែរ ។ យើងត្រូវសិក្សាទាំងសងខាងដើម្បីសាងវប្បធម៌ជាតិយើងឲ្យបានល្អ  តែកាលណាវប្បធម៌ល្អហើយប្រទេសយើងនឹងប្រជាជាតិយើងក៏មានអភិវឌ្ឍនៈគ្រប់វិស័យដែរ ។

## ពន្យល់ពាក្យ

គោលវិធី = ន.  ការកត់សំគាល់ឲ្យដឹងព្រំដែន ,  ភស្តុតាងសាក្សី (Principe) ។

វិទ្យាសាស្ត្រ = ន. វិជ្ជាមួយពួកដែលគេរកឃើញដោយការរៃរេ

ផ្សំធាតុផ្សេងៗ (Sciences) ។

លក្ខណៈ = ន. គ្រឿងសំគាល់, គ្រឿងចំណាំ, គ្រឿងសង្កេត

នាខ្លួនប្រាណ (Caractère) ។

មូលដ្ឋាន = (ម.ឋ មូ.ឡ:-ឋាន) ន. ដើមកំណើត, ទីតាំង,

ទ្រព្យដើម (Base) ។

អនុវត្តន៍ = ន. ការប្រព្រឹត្តតាម, ការធ្វើតាមផែនការណាមួយ

(Application) ។

សម្ភារៈ = (ម.ឋ សំ.ភា.រ:) ន គ្រឿងផ្សំ, គ្រឿងប្រើប្រាស់:

គ្រឿងសម្ភារ (Matériel) ។

ការពិសោធន៍ = (ម.ឋ.ពិសោធ) ការល្បងឲ្យដឹងម៉ត់ចត់, ឲ្យ

ឃើញពិតប្រាកដ (Expérience) ។

លទ្ធផល = (ម.ច.ល័ត-ធៈ-ផល់) ន. ផលដែលបានមកក្រោយពេលប្រកបកិច្ចការអ្វីមួយ (Résultat) ។

ប្រត្យក្ស = (ម.ច.ប្រត្យ័ក្ស) គុ. ច្បាស់លាស់, ជាក់ស្តែង ។

អរូបិយ = (ម.ច.អៈ-រូប-ប៉ិ) ន. គ្មានរូប , ធម្មជាតិដែលមើលមិនឃើញ (Abstrait) ។

ឧស្សាហកម្ម = (ម.ច.អ៊ុស-សា-ហៈ-កាំ) ន. ការដែលកើតមានឡើងដោយការខំប្រឹងធ្វើ, ការបង្កើតរបស់ប្រើប្រាស់តាមសម័យនិយម (Industrie) ។

ភារកិច្ច = (ម.ច.ភា-រៈ-កិច) ន. បន្ទុក, កិច្ចការធ្ងន់, កិច្ចការដែលត្រូវបំពេញជៀសវាងពុំបាន (Devoir obligatoire) ។

ជាតិនិយម ន. ការស្រឡាញ់ជាតិរបស់ឯង ជាងជាតិសាសន៍ដទៃ (Nationaliste) ។

ជាតិ = ន. កំណើត ។ ក្នុងអត្ថបទនេះមានន័យថា: មនុស្សដែលមាន

មាតុប្រទេសជាមួយគ្នា (Race) ។

ឧបសគ្គ = (ម.ឋ.អ៊ុប.ប៉.ស័ក) ន. គ្រឿងរាំងដំណើរ, គ្រឿង

ជំទាស់ (Obstacle) ។

ក្របខ័ណ្ឌ = ន. ការប្រព្រឹត្តិទៅក្នុងវង្វង់ច្បាប់ណាមួយ

(Cadre) ។

វប្បធម៌ = (ម.ឋ.វ័ប.ប៉:.ធ័រ) ន. ការសាបព្រោះ, ការបណ្តុះ

បណ្តាលចំណេះវិជ្ជាគ្រប់យ៉ាង (Culture) ។

អភិវឌ្ឍន៍: = (ម.ឋ.អ័ប.ភិ វ័ត.ធ:ន:) ន. កិច្ចការដែលចំរើនក្រៃលែង

(Grand progrès) ។ ពាក្យផ្ទុយ: ឧណភិ

វឌ្ឍន៍ (Sous développé)

វិស័យ = ន. តំបន់, ទីអាស្រ័យ, ផែក (Domaine) ។

វេវចនស័ព្ទ

ឧសាកាល - ឧសាសម័យ - បុព្វណ្ហកាល - បុព្វណ្ហសម័យ - អរុណោទ័យ ។

សម្ភារៈ - គ្រឿងប្រដាប់ - គ្រឿងប្រើប្រាស់ ។

ពិសោធ - ល្បង - សាក - ល ។

សទិសស័ព្ទ

| ឧសា - ឧស្សាហ៍ - ឧស្សាហ |
|---|

ឧសា = ន. ពន្លឺបំព្រាងជិតព្រឹក, វេលាភ្លឺស្រាង, ពេលក្រហមឯកើត (Aube) ។ ពាក្យនេះច្រើនប្រើផ្សំនឹងពាក្យឯទៀតដូចជា: ឧសាកាល, ឧសាសម័យ. ។

ឧស្សាហ៍ = (ម.ប.អ៊ុស-សា) (ម.ឧស្សាហ,សំ.ឧត្សាហ) ជានាមស័ព្ទ មានន័យថា: សេចក្ដីឧហាត, ការប្រឹងប្រែង:

មានឧស្សាហ៍ មានឧស្សាហ៍ធ្វើការ ។

សរសេរជា ឧស្សាហៈ ក៏បាន ។

ពាក្យនេះបើប្រើជាកិរិយាស័ព្ទក៏បាន, មានន័យថា : ឧហាត, សង្វាត, ខំប្រឹង ឧស្សាហ៍ធ្វើការ, ឧស្សាហ៍រៀនសូត្រ ។

ជួនកាលប្រើជាគុណស័ព្ទក៏បាន, មានន័យថា: *ដែលមានព្យាយាម, ដែលខំប្រឹងប្រែង: ក្មេងឧស្សាហ៍, មនុស្សឧស្សាហ៍, សិស្សឧស្សាហ៍ ...* ។ សរសេរជា ឧស្សាហៈ ក៏បាន ។

*ពាក្យ ឧស្សាហ៍ ឬ ឧស្សាហៈ នេះបើប្រើភ្ជាប់ពីខាងដើមសព្ទដទៃត្រូវលុបយុគលពិន្ទុ និងទណ្ឌឃាតចេញ គឺត្រូវសរសេរជា ឧស្សាហ ។ ពាក្យទាំងនោះគឺ ៖*

ឧស្សាហកម្ម = ( *សូមមើលសេចក្តីពន្យល់ខាងលើ* ) ។

ឧស្សាហករ = *ន. អ្នកធ្វើឧស្សាហកម្ម* ។

ឧស្សាហូបនីយកម្ម = *ន. ការធ្វើឲ្យទៅជាឧស្សាហកម្ម*

(Industrialisation) ។

អក្ខរាវិរុទ្ធ

ឧស្សាហ៍ ឬ ឧស្សាហៈ ។

ប្រក្យក្យ ( ក្យ-ក្យ ) ។ អរូបិយ ត្រូវអានថា “ អរូបប៊ុយ ” ។

បិត្ត គេមិនដែលសរសេរជា បិត្រ យ៉ាងនេះទេ ។

វិស័យ សូមកុំប្រឡំ នឹង ពាក្យ និស្ស័យ ។

ចំណាំ

**បិត្ត-បិត្រមូលភ្លើង**

តាមធម្មតា ពាក្យបាលីដែលសរសេរតម្រួតព្យាង្គលុះប្រែទៅជាសំស្ក្រឹតគេច្រើនប្រើជើង “ រ ” ឬ “ របាទ ” ជំនួសជើងតម្រួតនោះដូចជា ៖ សមុទ្ទ > សមុទ្រ . . . ។ល។ . . .

ប៉ុន្តែពាក្យចិត្តនេះសរសេរជា “ ចិត្រ ” មិនបានទេ ព្រោះពាក្យនេះជាពាក្យបាលីនិងសំស្ក្រឹត ។ គេសរសេរបានតែមួយយ៉ាងគឺ បិត្ត ។

ឯពាក្យ បិត្រ នេះមានតែមួយម៉ាត់គឺ ៖

បិត្រមូលភ្លើង = ឈ្មោះឈើមួយយ៉ាងដែលប្រើជាថ្នាំក្តៅ ។

**អនុវត្តន៍ - អនុវត្ត**

ពាក្យទាំងពីរម៉ាត់នេះ ជាសន្តានពាក្យ , មានន័យដូចគ្នា តែមួយជានាមសព្ទ មួយជាគុណសព្ទ ឬ កិរិយាសព្ទ ។ ហេតុនេះទើបគេសរសេរខុសគ្នា ។

អនុវត្តន៍ = ជានាមសព្ទ មានន័យថា ការប្រតិបត្តិតាម, ការធ្វើតាម។

សរសេរមាន ន៍ នៅខាងចុង ។

អនុវត្ត = ជាកិរិយាសព្ទមានន័យថា “ ធ្វើតាម,ប្រព្រឹត្តតាម” សរសេរជា

អនុវត្ត គ្មាន ន៍ នៅខាងចុងទេ ។

សំណួរ

១ - ចូរពន្យល់ពាក្យ : មូលដ្ឋាន , អនុវត្តន៍ , ឧស្សាហកម្ម , អរូបិយ ។

២ – ចូររកវេវចនស័ព្ទនៃពាក្យ : សម្ភារៈ ។

៣ – ចូររកសទិសស័ព្ទនៃពាក្យ : ឧស្សាហ៍ ។

៤ – ហេតុអ្វីបានជាគេសរសេរពាក្យអនុវត្តន៍ខុសគ្នា គឺមួយសរសេរជា អនុវត្តន៍ មួយសរសេរជា អនុវត្ត ? ។

៥ – ចូរអ្នកអធិប្បាយឲ្យបានពិស្តារនូវគោលវិធីនៃការសិក្សាខ្មែរដោយយោលទៅតាមអត្ថបទខាងលើនេះ ។

# យុវជននឹងបញ្ញាសិក្សា

ចាប់តាំងពីពេលបានឯករាជពេញលេញមកប្រទេសកម្ពុជា យើងក៏បានស្ថិតនៅក្នុងសន្តិភាពជាស្ថាពរ ៗ មានភ័ព្វនឹងបាន រៀនសូត្រដោយសុខសាន្តនៅក្នុងប្រទេសសន្តិភាពមួយ ដូច្នេះ យុវជនយើង គប្បីឆ្លៀតឱកាសដ៏ល្អនេះរៀនសូត្រឲ្យបានចំរើន កុំ ឲ្យខាតពេលកន្លងទៅចោលទទេ ឬ កន្លងទៅដោយយើងនៅកាយ មាយ ឬ ដោយយើងឆ្លៀតសប្បាយមិនគប្បី ៗ

ការដែលមានអារម្មណ៍ត្រឹមត្រូវដូច្នេះជា ការប្រសើរណាស់ ព្រោះថាបើយើងបានចំរើនច្រើនក្នុងការសិក្សា នោះផលល្អមាន ច្រើនណាស់ ផ្ទុយទៅវិញ បើការសិក្សារបស់យើងគ្មានសំរេច ត្រង់ណាសោះ នោះផលអាក្រក់ ក៏មានសំបើមណាស់ដែរ គឺ មានដល់មាតាបិតាគ្រួសារយើង មានដល់ប្រទេសជាតិយើង ហើយជាពិសេសនឹងមុនគេបង្អស់នោះគឺដល់ខ្លួនយើង ៗ ទាំង

នេះគឺមកពីក្នុងពេលបច្ចុប្បន្ន  យុវជននៅក្នុងការព្យាបាលបីបាច់រក្សារបស់គ្រួសារ  ហើយជីវភាពរបស់ខ្លួនជាប់ស្អិតនឹងជីវភាពគ្រួសារ ហើយទៅអនាគត  យុវជនជាកម្លាំងទ្រទ្រង់ជាតិដូច្នេះ ហើយបានជាយុវជនយើងតោងយល់ថា  ក្នុងលទ្ធផលល្អ ឬអាក្រក់ក្នុងការសិក្សារបស់ខ្លួន ៗ មិនមែនទទួលខុសត្រូវតែចំពោះខ្លួនឯងម្នាក់នោះទេ ថែមទាំងនៅចំពោះមុខគ្រួសារ នឹងប្រទេសជាតិទៀតផង ។ រឿងនេះយុវជនយើងតោងតែយល់ឲ្យច្បាស់ នឹងជ្រួតជ្រាបដល់ដំណើររបស់វា ៗ ចំពោះគ្រួសារ ឧបមាថា បើយុវជននោះ រៀនមិនបានចំណេះល្មមសម្រាប់ឡើងថ្នាក់ ឬត្រូវប្រឡងធ្លាក់  ពេលនោះឪពុកម្ដាយណាមួយរវល់គេស៊ីចិញ្ចឹមគ្រួសារផង ណាមួយរវល់ផ្គត់ផ្គង់ដល់ខ្លួនផង មួយឆ្នាំហើយមួយឆ្នាំទៀត  រួចបើចំពោះយុវជនរៀនសាលាឈ្នួលវិញ នោះគឺរឹតតែខាតពីរជាបីដងទៅទៀត ។

បំពោះប្រទេសជាតិវិញ គឺប្រទេសត្រូវការជាបន្ទាន់នូវពលរដ្ឋដែលមានសមត្ថភាព នឹងគុណសម្បត្តិគ្រប់គ្រាន់សំរាប់កសាងជាតិទាំងខាងផ្លូវស្មារតី ទាំងខាងផ្លូវសេដ្ឋកិច្ច ។ ហេតុនេះហើយបានជាព្រះរាជរដ្ឋាភិបាល ខំចេញប្រាក់បៀវត្សជូនគ្រូប ស្វះស្វែងរកជួលសាស្ត្រាចារ្យតាំងពីបរទេសមកទៀត ហើយខំបំណាយទៅលើសម្ភារៈផ្សេង ៗ ទៀតផង ។ ដូច្នេះបើក្នុងពេលម៉ោងណាមួយ យុវជនយើងរាយមាយមិនខំរៀនសូត្រ នោះមួយម៉ោងដែលរាជការ បំណាយប្រាក់ យ៉ាងច្រើន ទៅជាការឥតប្រយោជន៍ ហើយប្រាក់នេះទៀតវាក៏ជាកម្លាំងញើសរបស់មាតាបិតាយើងដដែល ។

បំពោះខ្លួនយើង គឺអនាគតយើងមិនបានភ្លឺចិញ្ចាចដូចគេឯងជាការនាំឲ្យយើងខូចកិត្តិយស នឹងកិត្តិនាម ហើយជាបញ្ញើក្អែកទម្ងន់ផែនដីផង ។

## ពន្យល់ពាក្យ

បញ្ហា = (ម.ឋ.ប៉ុញ-ហា) ន. ប្រស្នា, ចំណោទ (Question - Problèmes) ។

សន្តិភាព = ន. ភាពនៃសេចក្តីស្ងប់ស្ងាត់, រៀបរយ ប្រាសចាក ការបង្ហូរឈាម (Paix) ។ ពាក្យផ្ទុយ គឺសង្គ្រាម ។

ស្ថាពរ គុ. (សំ.ស្ថាវរ,ម.ថាវរ) មាំមួន, មាំទាំ, ខ្ជាប់ខ្ជួន, រុងរឿង, ស្ថិតស្ថេរ ។

ភ័ព្វ គុ. ដែលមានសំណាងល្អ (Bonne chance) ។ សរសេរជា ភ័ព្យ ក៏បាន ។

អារម្មណ៍ = ន. ចិត្ត, គំនិត ។

បច្ចុប្បន្នកាល = ន. ពេលឥឡូវនេះ (Présent) ។

អនាគតកាល = ន. ពេលខាងមុខ , ពេលដែលមិនទាន់មក
ដល់ (Futur) ។

ពលរដ្ឋ = ន. ប្រជាជន (Citoyen) ។

សមត្ថភាព = ន. ភាពនៃសេចក្ដីក្លាហានអង់អាច , មុះមុត ។

គុណសម្បត្តិ = ន. ការប្រកបដោយគុណ, ការបរិបូណ៌ ដោយ
សេចក្ដីល្អ, សេចក្ដីបរិសុទ្ធ (Qualité) ។
ពាក្យផ្ទុយ គឺគុណវិបត្តិ (Défaut) ។

សេដ្ឋកិច្ច = ន. មុខរបរដែលមានប្រយោជន៍សំខាន់បំផុតសំរាប់
ប្រទេសនិមួយ ៗ (Economie) ។

រាជរដ្ឋាភិបាល = (<រាជ + រដ្ឋ + អភិបាល) ន. អ្នកគ្រប់គ្រងរក្សាប្រជា
ជននឹងប្រទេស ដែលមានព្រះមហាក្សត្រគ្រង
រាជ្យ ហើយដែលនៅក្រោមអំណាចនៃព្រះ
មហាក្សត្រ (Gouvernement Royal) ។ 3

បៀវត្ស = ន. ប្រាក់ខែ (Salaire) ។

សាស្ត្រាចារ្យ= ន. គ្រូបង្រៀននៅមធ្យមសិក្សាគឺនៅវិទ្យាល័យ

ឬ អនុវិទ្យាល័យ (Professeur) ។

កិត្តិយស = ន. កេរ្តិ៍ឈ្មោះដែលរុងរឿង, ដែលត្រូវបានគេគោរ

សរសើរ (Honneur) ។

កិត្តិសព្ទ = ន. កេរ្តិ៍ឈ្មោះដែលល្បីខ្ទរខ្ទាយទៅគ្រប់ទិសទី

(Réputation) ។

វេវចនស័ព្ទ

កិត្តិសព្ទ-កិត្តិនាម-កេរ្តិ៍ឈ្មោះ ។

សភាព-មាំមួន-រឹងប៉ឹង-សិតសេរ ។

សទិសស័ព្ទ

| សុក - សុក្ក - សុទ្ធ |
|---|

សុក = ន. ឈ្មោះស្រោមស្រោបកូននៅក្នុងផ្ទៃម្ដាយ ។

សុក្ក ឬ សុក្កៈ = គុ. ស , ស្អាត, បរិសុទ្ធ , ភ្លឺថ្លា ។

សុក្ក ឬសុក្កៈ = ន. ទឹកកាម ; ឈ្មោះថ្ងៃទី ៦ នៃសប្ដាហ៍= ថ្ងៃសុក្រ ។

សុក្រ = ន. ឈ្មោះផ្កាយទី ៦ = ផ្កាយសុក្រ ឬ ឈ្មោះថ្ងៃ ទី ៦ = ថ្ងៃសុក្រ ។

សុខ = ន. សេចក្ដីសប្បាយ , សេចក្ដីរីករាយ , ការប្រាសចាក នូវរោគាព្យាធិផ្សេង ៗ ។

អក្ខរាវិរុទ្ធ

បំរើនឬចម្រើន ។ សំរេច ឬ សម្រេច ។ កំឡាំងឬកម្លាំង ។

សង្ខាង = សរសេរបានតែមួយយ៉ាងដូចនេះ ។ មិនត្រូវ សរសេរជា " សង្ខាង " ដូច្នេះទេ ។

បិតា = អានថា " ប៊ីតា " តែមិនត្រូវសរសេរជា " " ប៊ីតា " យ៉ាងនេះទេ ។

ផល = អានថា « ផល់ " ហើយក៏មិនត្រូវសរសេរជា "ផល់" យ៉ាងនេះដែរ ។

## សំណួរ

១ – ចូរពន្យល់ពាក្យ : សន្និបាត, ស្ថាពរ, អារម្មណ៍, បៀរវត្ស, កិត្តិស័ព្ទ ។

២ – ចូរកេពាក្យផ្សំយនឹងពាក្យ : សន្និបាត, សុខសាន្ត, គុណសម្បត្តិ ។

៣ – ចូរកេវេវចនស័ព្ទនៃពាក្យ : កិត្តិស័ព្ទ, ស្ថាពរ ។

៤ – ពាក្យ " កិត្តិស័ព្ទ " នឹង " កិត្តិនាម " មានន័យខុសគ្នាដូចម្ដេចខ្លះ ?

៥ – ចូរកេសទិសស័ព្ទនៃពាក្យ : សុខ ។

៦ – ចំពោះបញ្ហាសិក្សា តើយើងត្រូវទទួលខុសត្រូវយ៉ាងណាខ្លះ ?

# អង្គការសហប្រជាជាតិ

ការរំលត់ភ្លក់ភ្លើងសង្គ្រាម ជាគោលបំណងពិសេសនៃពពួកឥស្សរជនដែលជា ជនកសមាជិក នៃអង្គការសហប្រជាជាតិ ។

ធម្មនុញ្ញរបស់អង្គការនេះ បានចូលជាធរមានបញ្ញត្តិនៅថ្ងៃទី ២៤ តុលា ឆ្នាំ ១៩៤៥ គឺក្រោយពេលដែលសង្គ្រាមប្រល័យលោកលើកទីពីរបានរលត់ទៅ ។

ឥឡូវនេះ នៅគ្រប់តែប្រទេសទុនានិវត្សន៍ មានពពួកអ្នកជំនាញការនិងពួកបច្ចេកទេសគ្រប់មុខដំណែង និងគ្រប់មុខរបរបានទៅជួយធ្វើការនៅកន្លែង អ-ស-ប- ដោយស្មៀមស្ងាត់និងដោយសុទ្ធចិត្ត ឥតគិតដល់ការនឿយហត់ ដើម្បីប្រយុទ្ធនិងការស្រេកឃ្លាន ទុគ៌តភាព និងរោគាគ្រប់ប្រភេទ គឺជួយឧបត្ថម្ភប្រទេសទាំងឡាយជាសមាជិក ដែលទើបតែបានឯករាជថ្មី ៗ ឲ្យមានជំហររឹងប៉ឹងយ៉ាងឆាប់រួសរាន់ទាន់គេឯងឡើង ។

មិនតែប៉ុណ្ណោះ អង្គការសហប្រជាជាតិនេះ ជាឧត្តមមជ្ឈត្តករមួយ សម្រាប់សម្រុះសម្រួល បំបាត់ការខ្វែងគំនិតគ្នារវាងជាតិនិងជាតិ ។

ប្រទេសកម្ពុជា ដែលដម្កល់សេចក្ដីទុកទុកចិត្តយ៉ាងពេញបន្ទុករបស់ខ្លួនលើអង្គការសហប្រជាជាតិជានិច្ច ព្រមទាំងជំនឿរបស់ខ្លួនក្នុងការរិះរកសិទ្ធិ និងយុត្តិធម៌ ដើម្បីសម្រុះសម្រួលអធិករណ៍រវាងប្រជាជាតិទាំងឡាយ ព្រមទាំងដើម្បីទ្រទ្រង់សន្តិភាពអន្តរជាតិទៀតផង ។

## ពន្យល់ពាក្យ

**អង្គការសហប្រជាជាតិ** = ន. អង្គការមួយដែលប្រជាជាតិជាច្រើនក្នុងលោកនេះបានផ្ដួចផ្ដើមបង្កើតឡើងដើម្បីសន្តិភាពសាកល (Organisation des Nations unies) សរសេរកាត់ជា (អ-ស-ប) (ONU) ។

ឧត្តមមជ្ឈត្តករ = ន. អ្នកដែលនៅជាអាជ្ញាកណ្ដាល, អ្នកដែលមានមុខមាត់ខ្ពស់ជាងគេក្នុងការ សម្រុះសម្រួលរឿងជម្លោះរវាងជាតិ មួយនឹងជាតិមួយ (Arbitre Suprême) ។

ប្រទេសឧនាភិវឌ្ឍន៍=ន. ប្រទេសដែលមានអារ្យធម៌ មិនជឿនលឿន, ដែលមានសេដ្ឋកិច្ចដុនដាប (Pays sousdéveloppés) ។

ឥស្សរជន = ន. បុគ្គលខ្ពស់, បុគ្គលដែលមានឈ្មោះល្បីល្បាញ, បុគ្គលដែលធ្វើនយោបាយដឹកនាំជាតិ (Les grandespersonnalités, les hautes personnalités) ។

ជនកសមាជិក = ន. បុគ្គលដែលនៅក្នុងក្រុមមួយ ហើយដែលជាមេគំនិតនៃការបង្កបង្កើតក្រុមនោះ (Les membres fondateurs) ។

ធរមានបញ្ញត្តិ = ន. ការបានទទួល នូវសេចក្ដីយល់ព្រមតាមច្បាប់ ដើម្បីយកមកប្រើប្រាស់ជាប្រយោជន៍សាធារណៈ (Loi en vigueur) ។

អ្នកជំនាញ = ន. អ្នកប្រាជ្ញដែលប៉ិនប្រសប់ ហើយស្ទាត់ជំនាញក្នុងមុខការអ្វីមួយ (Expert) ។

អ្នកបច្ចេកទេស = ន. អ្នកដែលប៉ិនប្រសប់ ក្នុងមុខការជាង (Technicien) ។

ឧបត្ថម្ភ = ន.ឬ.កិ ជួយជ្រោមជ្រែង, ជួយទំនុកបំរុង, ជួយដោះទុក្ខគ្នា ។

ទុគ្គតភាព ឬ ទុគ៌តភាព = ន. ភាពខ្សត់ខ្សោយ ខានសម្ភារៈផ្សេង ៗ (Misère) ទុគ៌តជន (Les misérables) ។

អធិករណ៍ = ន. ការវិវាទ, ជម្លោះ, ការមានរឿងហេតុរវាងគ្នា នឹងគ្នា គឺរវាងបុគ្គលនឹងបុគ្គល ឬរវាងជាតិនឹងជាតិ ដូចជាអធិករណ៍ខ្មែរ-សៀមក្នុងរឿងព្រះវិហារជាដើម (Conflit) ។

ទុព្ភិក្ស = (ម.ថ.ទុ.រ:-ភិក) ន. ការអត់បាយ ។ ជាបាតុភូតមួយរបស់សង្គម ដែលប្រជាជនត្រូវស្លាប់ព្រោះដាច់ពោះ, អត់បាយ (Famine) ។

សិទ្ធិ = ន.អំណាចរបស់រដ្ឋ ឬ អំណាចរបស់បុគ្គល (Droit) ។

យុត្តិធម៌ = ការភ្ជាប់នឹងសេចក្ដីត្រឹមត្រូវ, ភាពមិនវៀចវេរ (justice,juste) ។

អន្តរជាតិ = ន. រវាងជាតិ នឹង ជាតិ, ពីជាតិមួយទៅជាតិមួយ (Inter-nation) ។

វេវចនស័ព្ទ

សង្គ្រាម-ចំបាំង ។

មុបត្តម-ជ្រោមជ្រែង-យិតយោង-ទំនុកបំរុង ។

សទិសស័ព្ទ

| រស-រស់-រួស |
|---|

រស = (ម.ថ.រស់) សម្ផស្សប្លែកៗ ដែលប៉ះពាល់នឹងជីវ្ហាបសាទជន ជាប្រៃ, ជូរ, ផ្អែម = រសប្រៃ, រសជូរ, រសផ្អែម ។

រស់ = កិ. ដែលមានជីវិត ; រស់រាន, រស់នៅ ... ។

រួស = គុ. ដែលរហ័ស, ឆាប់ ។ គោរួស : គោរហ័សស្រណុកប្រើ ។ រួសរាំ . រួសមាត់រួសក ។
ពាក្យនេះមានប្រើផ្សំនឹងពាក្យឯទៀតៗ ដូចជា :

រួសរាន់ , រួសរាយ , រួសរាំ ... ។

អក្ខរាវិរុទ្ធ

អគ្គការ = សរសេរជា « អគ្គ » កុំច្រឡំនឹងពាក្យ « អង់ » ។

ទុគ្គតភាព ឬ ទុគ៌តភាព ។ ប្រយុទ្ធ ( ទ្ធ ) ;

សុទ្ធ ( ទ្ធ ), រុស្សរាន់ ( រុស ) ។

## ចំណាំ

### ឧបត្ថម-ឧបត្ថមកៈ

ពាក្យទាំងពីរនេះ ជាសន្តានពាក្យ ហើយជា

នាមសព្ទដូចគ្នា ប៉ុន្តែមានន័យខុសគ្នា ។

ឧបត្ថម = ជានាមសព្ទមានន័យថា: ការទំនុកបំរុង , ការគាំទ្រ ,

ការផ្គុងផ្តើម, ការពឹងផ្អែក, ទីពំនាក់ =

មានឧបត្ថម្ភ ។

ពាក្យនេះខ្មែរយើង ប្រើជាកិរិយាសព្ទក៏បាន គឺ៖ ទំនុក

បំរុង , ពឹងផ្អែក = ឪពុកម្តាយបាន ឧបត្ថម្ភកូន

ឲ្យរៀនសូត្រ ។

ឧបត្ថមក ឬ កៈ = ក៏ជានាមសព្ទដែរ មានន័យថា: អ្នកទំនុកបំរុង,

អ្នកគាំទ្រ = បិតាខ្ញុំជា ឧបត្ថមក របស់ខ្ញុំ ។

## សំណួរ

១– ចូរពន្យល់ពាក្យៈ ឧត្តមមជ្ឈត្តករ; ប្រទេសឧនាភិវឌ្ឍន៍, ឥស្សរជន, ជនកសមាជិក, ធរមានបញ្ញាតិ ។

២– ពាក្យ "ឧបត្ថម" នឹង "ឧបត្ថមកៈ" មានន័យខុសគ្នាដូចម្ដេចខ្លះ ?

៣– ចូររកសទិសសព្ទនៃពាក្យៈ រស ។

៤– ចូរសម្ពន្ធប្រយោគទី ១ នៃអត្ថបទនេះ ។

៥– អង្គការសហប្រជាជាតិ កើតឡើងដោយមានគោលបំណងអ្វីខ្លះ ?

៦– អង្គការសហប្រជាជាតិ មានប្រយោជន៍ ឬទេ ? ព្រោះអ្វី ?

## វត្ថុបំណងនិងគោលច្បាប់នៃសហប្រជាជាតិ

វត្ថុបំណងនៃសហប្រជាជាតិ មានដូចតទៅ :

១–រក្សាទុកនូវសន្តិភាព និងសន្តិសុខអន្តរជាតិ ហើយដើម្បីសម្រេចនូវគោលបំណងនេះ ត្រូវប្រព្រឹត្តវិធានការណ៍រួបរួមគ្នាដ៏ស័ក្តិសិទ្ធិ ដើម្បីការពារនិងបង្ក្រាបអំពើរាតត្បាតទាំងអស់ ឬអំពើអ្វីៗដទៃ ដែលធ្វើឲ្យប្រេះឆាសន្តិភាព ហើយធ្វើឲ្យសម្រេចពិតប្រាកដនូវបទបញ្ហានៃការខ្វែងយោបល់គ្នា ឬបទបញ្ហានៃស្ថានការណ៍ទាំងឡាយមានលក្ខណៈអន្តរជាតិ ដែលអាចនាំឲ្យសន្តិភាពប្រេះឆាតាមមធ្យោបាយខាងសន្តិវិធី អនុលោមតាមគោលច្បាប់នៃយុត្តិធម៌ និងសិទ្ធិអន្តរជាតិ ។

២–ពង្រីករវាងប្រជាជាតិនូវការប្រាស្រ័យទាក់ទងជាមិត្តភាព ដែលលើកឡើងតាមសេចក្តីគោរពគោលច្បាប់សមភាព នៃសិទ្ធិប្រជារាស្ត្រ ហើយនិងមានសិទ្ធិវាត់វែងដោយខ្លួនឯង ព្រមទាំងចាត់វិធានការណ៍ដទៃទាំងអស់ដ៏សមរម្យ ដើម្បីពង្រឹងសន្តិភាពក្នុងលោក ។

៣-បង្កើតឲ្យមានពិតប្រាកដ នូវសហប្រតិបត្តិការអន្តរជាតិ ដោយដោះស្រាយនូវបញ្ហាអន្តរជាតិ ខាងរបៀបសេដ្ឋកិច្ច សង្គម បញ្ញា ឬមនុស្សធម៌ ដោយពង្រីកហើយនិងលើកទឹកចិត្តក្នុងការគោរពសិទ្ធិមនុស្ស និងសេរីភាពជាសារៈសម្រាប់មនុស្សជាតិទូទៅ ឥតសំគាល់ភេទ-ជាតិ-សាសនា ឡើយ ។

ពន្យល់ពាក្យ

សន្តិភាព = ន. ភាពនៃសេចក្តីស្ងប់ស្ងាត់, រៀបរយប្រាសចាក នូវការបង្ហូរឈាម (Paix) ។

សន្តិសុខ = ន. សេចក្តីរៀបរយ, សេចក្តីស្ងប់ ប្រាសចាកនូវ បម្បាំងកំងជល់ និងការជ្រួលជ្រើម គ្រប់បែបយ៉ាង (Sécurité) ។

សន្តិសុខអន្តរជាតិ = (សន្តិសុខ + អន្តរជាតិ) ន. សេចក្តីរៀបរយ, សេចក្តីស្ងប់រវាងជាតិនានា (Sécurité Internationale) ។

វិធានការណ៍ = ន. របៀបចាត់ចែងការ, បែបចាត់ចែង តាមវិធីណាមួយ (Mesure) ។

ស័ក្តិសិទ្ធិ = ន. ការសម្រេចដោយអំណាច ។ បើប្រើជាគុណស័ព្ទមានន័យថា: ដែលមានអំណាច ឬ ដែលអាចសម្រេចប្រយោជន៍បានយ៉ាងពិតប្រាកដ ។ ប្រើជាកិរិយាវិសេសន៍មានន័យថា: ធ្វើឲ្យឃើញជាក់ស្តែង, ពិតប្រាកដ ។ (ក្នុងអត្ថបទនេះគឺ ជាក់ស្តែង, ពិតប្រាកដ) ។

ស្ថានការណ៍ = ហេតុការណ៍ដែលមាន, បែបភាពដែលមានទៅ (Situation) ។

សន្តិវិធី = ន. វិធីស្ងប់, វិធីដែលប្រព្រឹត្តទៅដោយសុខ, ស្ងប់; វិធីដែលធ្វើឲ្យមានសន្តិសុខ ។ ពាក្យផ្ទុយគឺ យុទ្ធវិធី

យុត្តិធម៌ = ន. សេចក្ដីទៀងត្រង់, ការត្រឹមត្រូវតែតាមច្បាប់ (Justice) ។

សិទ្ធិ = (ម.ចំ.សុំត) ន. អំណាចរបស់រដ្ឋ ឬ អំណាចរបស់បុគ្គល (Droit) ។ សិទ្ធិមនុស្ស (Droit de l'homme) ។

សមភាព = ន. ភាពស្មើគ្នា, ភាពមិនប្រកាន់រើសធំតូច, មានក្រ, ភាពដែលមិនប្រកាន់វណ្ណៈ, ឋានៈ (Egalité) ។

សហប្រតិបត្តិការ = (សហ=រួមគ្នា + ប្រតិបត្តិ + ការ) ន. ការដែលត្រូវធ្វើរួមគ្នា (Coopération) ។

សហប្រតិបត្តិការអន្តរជាតិ = ការដែលត្រូវធ្វើរួមគ្នា រវាងជាតិនានា (Coopération Internationale) ។

សេដ្ឋកិច្ច ន. មុខរបរដែលមានប្រយោជន៍សំខាន់បំផុត សម្រាប់ប្រទេសនិមួយៗ (Economie) ។

មនុស្សធម៌ ន. ធម៌ដ៏ប្រពៃរបស់មនុស្ស គឺការនិយមមនុស្សផងគ្នា, ការមិនមើលងាយ, មិនជិះជាន់បំផ្លាញមនុស្សផងគ្នា (Humanité) ។

វេវចនស័ព្ទ

បញ្ញា - បញ្ញត្ត - បង្គាប់ ។

យោបល់ - មតិ - ទស្សនៈ ។

សទិសស័ព្ទ

| សា - សារ - សារៈ |
|---|

សា = កិ. មូរឡើងវិញ, គេចឡើងវិញ = សាស្រូវ, សាកន្ទេល ។

សា = ន. ស្រូវឬដំណាំពួកខ្លះដែលដុះលូតលាស់តពីគល់ចាស់ 4
ឬពីជញ្ជ្រាំងស្រស់ = សាស្រូវ, សាឪឡឹក ។

សារ ឬ សារៈ = ន.ខ្លឹម, សេចក្តីខាប់ខ្លួន ។ ប្រើជាគុណស័ព្ទក៏បាន: ខ្លឹមសារ, សារប្រយោជន៍ ។

សារ = ន. ឈ្មោះដំរីស្ករ ឬ ដំរីដែលមានភ្លុកអស់ទំហុំហើយ: ដំរីសារ ។

អត្ថាភិវុឌ្ឍ

ធ្វើទៅ ឬ ធ្បើទៅ ។ សារ ឬ សារៈ ។

សិទ្ធិ (ទ្ធិ) អានថាសិត ។ ពស្ត្រ (ស្ត្រ) អានថាពស ។

វិធានការណ៍ (ការណ៍) សេដ្ឋកិច្ច (ដ្ឋ,ច្ច) ។ សន្តិសរសេរជាសម្មតិ ក៏បានតែកុំសរសេរជា " សន្ត់ ,, យ៉ាងនេះឲ្យសោះ ។

បំណាំ

## សន្តត-សន្តតិ

ពាក្យទាំងពីរនេះមានន័យដូចគ្នា ប៉ុន្តែមួយជា

នាមស័ព្ទ មួយជាកិរិយាស័ព្ទ ហើយត្រូវសរ

សេរខុសគ្នា ។

សន្មតិ ឬ សម្មតិ = ជានាមស័ព្ទ មានន័យជា ការជឿជាក់, ការសន្យា,

ការអនុម័ត, ការយល់ព្រមជាមួយគ្នា ។ ត្រូវសរ-

សេរជា "សន្មតិ" ។

សន្មត ឬ សម្មត = ជាកិរិយាស័ព្ទ មានន័យជា: ជឿជាក់, សន្យា, អនុម័ត,

យល់ព្រមជាមួយគ្នា ។

ត្រូវចៀសវាងកុំសរសេរជា សន្មត់ ឬ សម្មត់ យ៉ាងនេះ

ឡើយ ។

សំនួរ

១ - ចូរពន្យល់ពាក្យ: សន្តិសុខអន្តរជាតិ, វិធានការណ៍,

សមភាព, សហប្រតិបត្តិការអន្តរជាតិ ។

២ - ចូររកវេវនសព្ទ នៃពាក្យ: បញ្ហា ។

៣ - ចូររកសទិសស័ព្ទ នៃពាក្យ : សា ។

៤ - ចូររកពាក្យផ្ទុយនឹងពាក្យ ៖ នាភិវឌ្ឍន៍ ។

៥ – វត្ថុបំណងនឹងគោលច្បាប់ នៃសហប្រជាជាតិមានបែង

ដូចម្ដេចខ្លះ ?

៦ – ប្រទេសកម្ពុជា មានចូលជាសមាជិកនៃអង្គការសហ-

ប្រជាជាតិឬទេ ? កាលពីឆ្នាំណា ?

# យុវជន និង សន្តិភាព

ឧត្តមគតិយុវជនយើងបច្ចុប្បន្ននេះគឺអ្វី ? ត្រង់នេះយុវជនយើងអាចឆ្លើយដោយខ្លួនឯងថា: សន្តិភាព អព្យាក្រិត្យ ឯករាជ្យ ដែលមានអគ្គសម្តេច ព្រះឧបយុវរាជ ជាព្រះប្រមុខដឹកនាំ ។ ឧត្តមគតិនេះ ដែលថ្លៃថ្នូរបំផុតរបស់យុវជនយើង គួរតែយុវជនយើង ស្គាល់ច្បាស់នូវតម្លៃទាំងនេះឲ្យបានរឹងជំហារ ព្រោះយុវជនយើងមែនមានវិចារណញ្ញាណ មិនមែនជាម៉ាស៊ីនទេ ។ បើយើងបណ្តោយឲ្យឧត្តមគតិយើង អណ្តែតអណ្តូងមិនទៅជាឧត្តមគតិបំរើ សន្តិភាព អព្យាក្រិត្យឯករាជ្យពិតប្រាកដ នោះឧត្តមគតិយើងមុខតែរវើរវាយ ជួនណាត្រឡប់ទៅជាម៉ាស៊ីនក៏មាន ត្រង់នេះមកពីយុវជនយើងភាគខ្លះ ដែលមិនទាន់យល់ថាសន្តិភាពជាអាយុជីវិតរបស់ប្រជាជនខ្មែរទាំងមូល ឬជាអាយុជីវិតសាកលលោកៗ ហេតុនេះយុវជនយើងត្រូវដឹងថា មាគាំសន្តិភាព អព្យាក្រិត្យ

ឯករាជ្យ ជារបស់នៃអាយុជីវិតរបស់ប្រជាជនខ្មែរ បើយើងត្រូវបាត់បង់មាគ៌ានេះ យើងអាចទទួលគ្រោះថ្នាក់អាសន្នយ៉ាងធំក្រៃលែង ព្រោះប្រជាជនខ្មែរ ក៏ដូចជាប្រជាជនសាកលលោក អ្នកណាក៏ស្រឡាញ់សន្តិភាពដែរ ដូច្នេះសន្តិភាពប្រាកដជាអាយុជីវិតរបស់ប្រជាជនយើង និងយុវជនយើង ។ ហេតុនេះគប្បីយុវជនយើងកុំបណ្តែតបណ្តោយឲ្យសោះ ព្រោះភារៈដែលថ្ងៃធ្ងរធ្ងន់បំផុតនៅលើយុវជនយើងនេះ គួរតែយុវជនយើងមិនត្រូវភ្លេចឲ្យសោះចំពោះភារៈធ្ងន់នេះឡើយ ។ ហើយយើងមិនត្រឹមតែភ្លេចនោះទេ បើកាលណាយើងដឹងហើយត្រូវតែយើងធ្វើដើម្បីបំពេញភារកិច្ចយើងជាយុវជនថ្ងៃធ្ងររបស់ប្រទេស ដោយប្រជាជនយើងនៅនាបច្ចុប្បន្នសង្ឃឹមតែលើយុវជន ដែលជាអ្នកមាន

nghị lực khả năng

កម្លាំងពលំ និងមានសមត្ថភាពសម្រេចនូវករណីយកិច្ចទាំងនេះ ។

## ពន្យល់ពាក្យ

សន្តិភាព = ន. ភាពសុខសាន្តត្រាណ, ភាពគ្មានចម្បាំងកំងដល់ (Paix) ។

ឧត្តមគតិ = (ម.ថ.អ៊ុ.ដំ.គ:.តិ) ន. (ឧត្តម = ខ្ពង់ខ្ពស់, ល្អ, ប្រសើរ + គតិ = ដំណើរ) ដំណើរដ៏ខ្ពង់ខ្ពស់, ដំណើរដ៏ប្រសើរ, គំនិតដ៏ខ្ពង់ខ្ពស់ ថ្លៃថ្លា (Idéal) ។

អព្យាក្រិតភាព = ន. ភាពដែលនៅចំកណ្តាល គឺមិនចូលខាងប្លុកលោកសេរី និងប្លុកសង្គមនិយម (Neutralité) ។

វិចារណញ្ញាណ = ន. ការរំពឹងពិចារណា ។ ប្រាជ្ញាដែលផុសផុលឡើង ព្រោះការពិចារណា, ប្រាជ្ញាសម្រាប់ពិចារណា (Raison) ។

ឯករាជ្យ = ន. រាជ្យតែមួយ, ភាពនៃការគ្រប់គ្រងប្រទេសដោយ
ខ្លួនឯង ( Indépendance ) ។

មាគ៌ា = ន. ផ្លូវ, ដំណើរ ។

អាសន្ន = ន. ការប្រកបដោយគ្រោះភ័យផ្សេងៗ ប្រើជា គុ. ក៏បាន ។

ភារៈ = ន. ការទទួលខុសត្រូវលើបន្ទុករបស់ខ្លួន ។

សមត្ថភាព = ន. ភាពនៃសេចក្ដីអាចបាន, សេចក្ដីម៉ុះម៉ុត ។

ករណីយកិច្ច = ន. កិច្ចដែលត្រូវបំពេញជាការចាំបាច់ (Devoir) ។

បច្ចុប្បន្ន = ន. ពេលឥឡូវនេះ (Présent) ។

ពលំ = ន. ពាក្យនេះខ្មែរយើងច្រើនប្រើផ្សំនឹងពាក្យ កម្លាំង = កម្លាំង
ពលំ គឺកម្លាំងដ៏រឹងប៉ឹងមាំមួន ។

វេវចនស័ព្ទ

មាគ៌ា - ផ្លូវ ។

ប្រមុខ - ប្រធាន - មេ ។

ប្រមុខរដ្ឋ-ប្រធានាធិបតី ។

សទិសស័ព្ទ

នៅ - ន្ធូវ

នៅ = កិ. ស្ថិត, មាន = នៅឯណា ? នៅផ្ទះ, នៅក្រុង ក្រុក ... ។

នៅ = កិ-វិ - ដែលមិនទាន់, ដែលមានទៀត = ហើយឬ នៅ ? នៅ ! ; នៅឡើយ, នៅ ទៀត ។

ន្ធូវ = (ម.ឋ.នៅ) និ. ទិឝ, ហើយទិឝ = ទៅកន្លែងគុកធំមាន អ្នកទោសសាមញ្ញ ន្ធូវ អ្នកទោសនយោបាយ ។

ន្ធូវ = (ម.ឋ.នៅ) អា.និ. ពាក្យប្រាប់ដំណើរសម្រេចអំពើដែល គេត្រូវធ្វើ = បុគ្គលធ្វើ ន្ធូវ អំពើល្អតែងទទួល ផលល្អ ។

## អក្ខរាវិរុទ្ធ

បំរើ ឬ បម្រើ ។ គប្បី ឬ គាប្បី ។ កំឡាំង ឬ កម្លាំង ។
សកល ឬ សាកល ។ ដំឡៃ ឬ ដម្លៃឬតម្លៃ ។

## សំណួរ

១ – ចូរពន្យល់ពាក្យ = ឧត្តមគតិ , វិចារណញ្ញាណ, សមត្ថភាព , ករណីយកិច្ច ។

២ – ចូររកវេវចនស័ព្ទនៃពាក្យ = ប្រមុខ ។

៣ – ចូររកសទិសស័ព្ទនៃពាក្យ = នូវ ។

៤ – ចូរសម្ពន្ធប្រយោគទី ១ នៃអត្ថបទនេះ ។

៥ – ចូររកឧត្តមគតិនៃអត្ថបទនេះ ។

# ការចំរើនក្នុងផ្ទៃនៃយុវជនយើង

មតិដែលថា "យុវជនជាកម្លាំងរបស់រដ្ឋ យុវជនជាអនាគតរបស់រដ្ឋឬជាបន្ទល់ នៃរដ្ឋទៅអនាគតនោះ" សព្វថ្ងៃនេះបានជ្រួតជ្រាបក្នុងសន្តានចិត្តនៃជនគ្រប់ៗរូបណាដែលគិតដល់វាសនានៃប្រទេសគេ ។ មតិនេះសមប្រកបដោយគតិបណ្ឌិតត្រឹមត្រូវណាស់ ។

ពេលក្រឡេកមកមើលសភាពការណ៍ ពិតនៅប្រទេសយើង តើយុវជនយើងចំរើនដល់ណាហើយ ក្នុងបច្ចុប្បន្នកាលនេះ ?

ទីងឃើញសេចក្តីចំរើននេះបានត្រឹមត្រូវ លុះណាតែយើងក្រឡេកមើលសភាពការណ៍ នៃយុវជនយើងក្នុងសម័យ ដែលប្រទេសយើងត្រូវបាត់ឯករាជ្យ បាត់អធិបតេយ្យ ហើយរស់នៅក្រោមអាណាព្យាបាលរបស់អាណានិគម និយមបារាំង ។

ក្នុងសម័យនោះ យុវជនយើងភាគច្រើន មិនបានយល់

ន័យរបស់ខ្លួន នឹងការៈរបស់ខ្លួនចំពោះប្រទេសយ៉ាងណា ៗ ទោះ ៗ ដូចនេះយើងក៏ឃើញតែខ្លួនឯងច្រើនជាងអ្វីនឹងមុនអ្វីទាំងអស់ ៗ

ពួកអាណានិគមនិយមបាកំងមិនហ៊ានឲ្យយុវជនយើង ដែលនៅសាលាផ្សេងគ្នា បានជួបមុខគ្នាញឹកញយទេ ខ្លាចយល់គ្នាស្រឡាញ់គ្នាគេអស់ផ្លូវ ប្តូមួយបើមានពេលជួបគ្នាម្តង ៗ គេខំបង្កជាអធិករណ៍រវាងគ្នានឹងគ្នា នាំឲ្យឈ្លោះគ្នាបាក់បែកគ្នាទៅវិញ ៗ ចុះឥឡូវ ? ឥឡូវរឿងរ៉ាវបានផ្លាស់ប្តូរសឹងតែទាំងអស់ទៅហើយ ប្រទេសយើងបានឯករាជ្យ បាកំងវិលទៅស្រុកវិញអស់ យុវជនយើងបានចូលមកដល់រយៈពេលមួយថ្មី គឺសម័យយោគយល់សាមគ្គី នឹងកសាង ៗ

យុវជនយើងមានឱកាសនឹងជួបគ្នា ដើម្បីពិភាក្សាប្តូរយោបល់គ្នាជាញឹកញយ គេបានយល់គ្នានឹងស្រឡាញ់គ្នាទៅវិញ

ទៅមកដោយគន្លងមិត្តភាពនឹងការគោរព ហើយគំនិតអាត្មានិយមក៏សាបរលាបទៅបន្តិចម្តង ៗ ទុកកន្លែងឲ្យគំនិតកសាងប្រទេសជាតិវិញ ។ គឺថាយុវជនតស៊ូនឹងឧបសគ្គគ្រប់បែបដើម្បីសាមគ្គីជាប្រយោជន៍ដល់ប្រទេសជាតិ ។ អ្វីដែលផ្ទុយនឹងប្រយោជន៍ជាតិគេសុខចិត្តមិនធ្វើឡើយ ។ ស្មារតីសាមគ្គីនេះកើតឡើងមកពីលក្ខណៈនឹងកាលៈទេសៈ ដែលប្រទេសយើងធ្លងកាត់គឺក្នុងការតាមទារឯករាជ្យ ក្នុងការការពារអព្យាក្រិត្យ ។ ក្នុងការតាំងនេះយុវជនយើងក៏បានជួយពេញទំហឹងដែរ ដោយបានឈរដំរៀបគ្នាជាជួរជុំវិញអង្គសម្តេច ។

ពិសេសទៅទៀត យុវជនយើងក្នុងសម័យនេះ មិនត្រឹមតែសាមគ្គីគ្នា ឬ យល់ដល់បញ្ហាជាតិទេ ថែមទាំងនាំគ្នាខិតខំក្នុងការបំរើជាតិទៀតផង ដូចជានាំគ្នាទៅបំពេញការហត្ថកម្ម

នៅទួលគក-ផ្លូវអយស្ម័យយានជាដើម ។ ត្រង់នេះសឲ្យឃើញថា និស្សិតម្នាក់ ៗ ក៏ជាពលករម្នាក់ដែលជាចន្ទល់សេដ្ឋកិច្ចជាតិយើង ដែលជាឬសគល់ នៃសង្គមកិច្ច វប្បធម៌ ។ល។..

## ពន្យល់ពាក្យ

មតិ=(ម.ថ.ម័ត.តិ) ន- យោបល់, សេចក្ដីយល់ឃើញ, ទស្សន:(Point de vue) ។

អនាគត = ន. ពេលខាងមុខ ។ ក្នុងអត្ថបទនេះ យុវជនជាអនាគតរបស់រដ្ឋ.=យុវជនជាកម្លាំង , ជាទីសង្ឃឹមរបស់រដ្ឋទៅថ្ងៃមុខ ។

វាសនា=ន. បរិយា ឬ បរិត ដែលអប់រំសន្សុំទុក ឬ កប់ទុកក្នុងសន្ដានចិត្ត ។ ពាក្យនេះខ្មែរយើងប្រើ សំដៅសេចក្ដីថា សំណាង (Chance) ។ ជៅគកាសនា សំណាងល្អ (Bonne-chance) ។

គតិបណ្ឌិត = ន. គំនិតរបស់អ្នកចេះដឹង, គតិរបស់អ្នកប្រាជ្ញ (Sagesse) ។

សភាពការណ៍ = ន. ដំណើរការណ៍, ហេតុការណ៍, ដំណើរប្រែប្រួល ។

អធិបតេយ្យភាព = (ម.ប.អ:-ធិប.ប៉ៈ-តៃ) ន. ភាពជាធំ (Souveraineté) ។

អាណាព្យាបាល = ន. ន-ការគ្រប់គ្រង, ថែរក្សា (Tutelle) ។ ក្នុងទីនេះ ប្រទេសបារាំងជាអាណាព្យាបាលរបស់ខ្មែរគឺ ប្រទេសបារាំងចូលមកជិះជាន់ប្រទេសខ្មែរ ។

អាណានិគមនិយម = ន. លទ្ធិដែលនិយម យកប្រទេសគេធ្វើជាខ្ញុំកញ្ជះរបស់ខ្លួន (Colonialisme) ។

អធិករណ៍ = ន. ការវិវាទ, ជម្លោះ, ការមានហេតុរវាងគ្នានឹង

គ្នា តវ៉ារវាងបុគ្គលនឹងបុគ្គល ឬរវាងប្រទេសនឹងប្រទេស (Conflit) ។

វិយ := ន. សង្កាត់, ផែក, ភាគ, កម្រិត, រយៈផ្លូវ, រយៈពេល ។

សាមគ្គី ន. ការប្រមូលផ្ដុំកម្លាំងគ្នា, ការព្រួតដៃគ្នា, ការមូលមតិគ្នា (Union) ។

ពិភាក្សា = កិ. ការជជែកវែកញែក, ការជជែកប្រយោបល់គ្នា (Débattre, Discuter) ។

មិត្តភាព ន. ការរាប់រកគ្នាជាមិត្ត, ភាពជាមិត្តសម្លាញ់នឹងគ្នា (Amitié) ។

ភាតរភាព = (ម.ថ.ភាតរ:) ន.ការរាប់រកគ្នាដូចជាបងប្អូន, ភាពជាបងប្អូននឹងគ្នា (Fraternité) ។

អាត្មានិយម = ន. ការនិយមតែខ្លួនឯងដោយមិនគិតដល់អ្នកឯទៀត ។

ឧបសគ្គ = ន. គ្រឿងរារែកជ្រែកដំណើរ , គ្រឿងជំទាស់ (Obstacle) ។

ការហត្ថកម្ម = ន. ការធ្វើដោយដៃ (Travail manuel) ។

សង្គមកិច្ច = ន. អំពើដែលធ្វើឡើង ដើម្បីជាប្រយោជន៍ដល់ជនរួមជាតិ (Action sociale) ។

វប្បធម៌ = ន. ការបណ្ដុះនូវចំណេះវិជ្ជាគ្រប់យ៉ាង , ការធ្វើឲ្យដុះដាលខាងចំណេះវិជ្ជា , ក្បួនច្បាប់ (Culture) ។

វេវចនស័ព្ទ

អ្នកប្រាជ្ញ-បណ្ឌិត-វិញ្ញូ-វិទូ-វេទី-វិបស្សី-មុនី-វិបស្សិត-សុធី-សុធីរៈ - ។

សទិសស័ព្ទ

រដ្ឋ-រត្ន-រាត់ 5

រដ្ឋ = (ប.ថ.ភត់) ន. ដែន , ប្រទេស , អ្នកនៅក្នុងដែន, រាស្ត្រ ,

ប្រជាជន ។ ពាក្យដែលប្រើផ្សំនឹងពាក្យរដ្ឋគឺ :

រដ្ឋកម្ម, រដ្ឋការ, រដ្ឋបុរស; រដ្ឋបវេណី, រដ្ឋមន្ត្រី;
រដ្ឋសភា; កម្ពុជរដ្ឋ: រដ្ឋធម្មនុញ្ញ ។ ល ។... ។

រតន, រត្ន ឬ រ័តន៍,រ័ត្ន = ( ម.ប.រៈ-តៈនៈ, រ័ត្នៈឬរ័ត្នៈ ) ន.កែវ
ពេជ្រ, ត្បូងពេជ្រ, មាសប្រាក់ ... ។ ពាក្យដែលប្រើផ្សំនឹង
ពាក្យ រតន ឬ រត្ន គឺ ៖

រត្នគ៌ភា, រត្នគិរី, រតនឬរត្នត្រ័យ, រតនប្បភា, រតនពាណិជ្ជ,
រតនវិចិត្រ ។ ល ។...

រត្ត – (ម ប.រ័ត.តៈ) គុ. ដែលជ្រលក់ហើយ, ដែលផាត់ពណ៌
ហើយ ។ ពាក្យដែលផ្សំនឹងពាក្យ រត្ត គឺ

រត្តកម្ពល, រត្តចន្ទន៍, រត្តបវី. រត្តសុវណ្ណ, ទីឃរត្ត, អត្ថរត្ត,
រត្តុប្បល ។ ល ។ ..

រាត់ = កិ.ឬ.កិរិ. ពាក្យខ្មែរសុទ្ធមានន័យថា : ទាញកន្ត្រាក់ផ្ដាច់ដោយ

បង្ខំ = ទាញរាត់ផ្ដាច់ ។

## អក្ខរាវិរុទ្ធ

កំឡាំងឬកម្លាំង ។ ចំរើនឬចម្រើន ។ ជំលោះឬជម្លោះ ។

ឧបសគ្គឬឧបសគ្គៈ ។ រតន ឬ រត្ន ឬ រ័តន៍ ឬ រ័ត្ន ។

## សំណួរ

១ – ចូរពន្យល់ពាក្យ: គតិបណ្ឌិត, អធិបតេយភាព, ភាតរភាព, សង្គមកិច្ច ។

២ – ចូររកវេវចនស័ព្ទ នៃពាក្យ:បណ្ឌិត ។

៣ – ចូររកសទិសស័ព្ទ នៃពាក្យ:រដ្ឋ ។

៤ – ចូររកពាក្យផ្ទុយនឹងពាក្យ: សាមគ្គី ។

៥ – ចូររកឧត្តមគតិ នៃអត្ថបទនេះ ។

# អារ្យធម៌នៅសុវណ្ណភូមិ

ដែនដីជ្រុងពិភពលោកត្រង់ភូមិភាគយើងនេះ មានការផ្លាស់ប្ដូរឈ្មោះផ្សេងៗតាមកាលសម័យ ។ ដើមឡើយអ្នកឥណ្ឌៀហៅថា "សុវណ្ណភូមិ" ព្រោះទីឋាននេះសម្បូណ៌ដោយលោហធាតុធីតមានមាសជាដើម ។ ក្នុងកាលតមក ឈ្មោះថា "សុវណ្ណភូមិ" ក៏រលប់រលាយបាត់បង់ទៅ ហើយកើតឈ្មោះមួយមកជំនួសវិញថា "ឥណ្ឌូចិន" ។ ការសន្មតិឈ្មោះថាឥណ្ឌូចិនក៏សមឈ្មោះដែរ ព្រោះទីឋាននេះឋិតត្រង់ចន្លោះប្រទេសឥណ្ឌៀនឹងប្រទេសចិន ។ ឥឡូវនេះឈ្មោះឥណ្ឌូចិន រកគល់រលុបទៅទៀតហើយ លេចមានឈ្មោះមួយទៀតកើតឡើងថា អាស៊ីភាគអាគ្នេយ៍ ។ ឈ្មោះថ្មីនេះមានហេតុផលសមរម្យដែរ ព្រោះថាទីនេះឋិតនៅត្រង់ជ្រុងពិភពលោក ត្រង់ភាគអាគ្នេយ៍នៃទ្វីបអាស៊ី ។

បើយើងយកភូមិសាស្ត្រមកលាតត្រដាងមើល ហើយបើកទំព័រប្រវត្តិសាស្ត្រមកធ្លុះមើលផង នុះយើងនឹងមើលឃើញនូវប្រជាជនក្នុងទីឋាននេះ បានយ៉ាងច្បាស់លាស់ គឺខ្មែរមន-ចាម អាស្រ័យលើភាគដែនដីធំ ឯជ្វាអាស្រ័យនៅតាមកោះធំក្នុងមហាសមុទ្រៗ ប្រជាជនទាំងនេះហើយដែលអាស្រ័យទីឋាននេះតាំងតែពីបុរាណកាល ហើយមានវឌ្ឍនភាពយ៉ាងបរិបូណ៌ មានអារ្យធម៌ប្រសើរកប់ពាន់ឆ្នាំមកហើយ មិនមែនដូចអ្នកផងពោលថា អរញ្ញជននោះទេ ដូចមានបុរាណដ្ឋាន បុរាណវត្ថុនិងប្រពៃណីនិយមជាសក្ខីភាពស្រាប់ ។

វឌ្ឍនធម៌នៃប្រជាជនទាំងនេះ កើតចេញមកពីអារ្យធម៌ធំពីរ គឺអារ្យធម៌ឥណ្ឌានិងអារ្យធម៌ចិន ៗ អារ្យធម៌ទាំងពីរនេះមកជួបគ្នានៅដែនដីអតីតសុវណ្ណភូមិនេះ ហើយយកជាព្រំប្រទល់នៃវិគ្ការកម្មតែរៀងខ្លួន ៗ ជនជាតិធំទាំងពីរនេះនៅតែបន្តសកម្មភាព

ផ្សាយវប្បធម៌រៀងខ្លួន លុះមកដល់ឥឡូវនេះ ។ អារ្យធម៌នៃជនជាតិទាំងពីរនេះមកជួបគ្នា ផ្សំផ្គុំគ្នា នៅរួមសំរាសជាមួយគ្នាយូរលង់ទៅ ក៏បានកើតជាអារ្យធម៌នៃជនជាតិក្នុងទីនេះតែសព្វខ្លួន ។

វីរិយបណ្ឌិតោ ចាំង-ហាត់

## ពន្យល់ពាក្យ

អារ្យធម៌ = ន. ដំណើរដែលមានបែបបទល្អប្រសើរ, ដែលនាំឲ្យមានការចំរើនទាន់សម័យនិយម (Civilisation) ។

សុវណ្ណភូមិ = (< សុវណ្ណ: មាស + ភូមិ: ដំបន់) ន. ដំបន់ដែលមានមាស ។ គឺជាឈ្មោះឥណ្ឌូចិនក្នុងអតីតកាល ។

សន្មតិ = ន. ការសន្យា, ការប្តេជ្ញា, ការអនុម័តិ, ការយល់ព្រមជាមួយ ។ សរសេរជា សម្មតិ ក៏បាន ។

អាគ្នេយ៍ = ន. ទិសដែលនៅក្នុងចន្លោះទិសខាងត្បូងនឹងខាងកើត (Sud-Est) ។

អាស៊ី = ន. ឈ្មោះទ្វីបមួយនៅក្នុងចំណោមទ្វីបទាំង ៥ នៃពិភពលោក មានទំហំ ៤៥.០០០-០០០ គម២ ហើយដែលមានប្រទេសខ្មែរយើងនៅក្នុងនោះផង (Asie) ។

ប្រវត្តិសាស្ត្រ = ន: ក្បួនឬសៀវភៅឬសេចក្ដីតារឹក ដែលបានកត់ត្រាទុកនូវរឿងរ៉ាវនៃប្រទេសនិមួយៗ; ក្បួនប្រាប់ពង្សាវតារអ្វីមួយ (Histoire) ។

វិឌ្ឍនភាព = ន- ភាពចំរើនលូតលាស់ (Progrès) ។

អារញ្ញជន (ម.ថ.អារ៉ុញ-ជន់) ន. (<អារញ្ញ: ព្រៃ + ជន) = មនុស្សព្រៃ, មនុស្សនៅក្នុងព្រៃ, មនុស្សល្ងង់ខ្លៅហួសប្រមាណ, មនុស្សដែលពុំបានទទួលនូវអារ្យធម៌តាមសម័យនិយម ។ សរសេរជាអារណ្យជនក៏បាន ។

បុរាណ ឬ បូរាណ គុ. ចាស់, ដែលកើតមានមុន, ដែលមានយូរមកហើយ (Ancien) ។

បុរាណដ្ឋាន = ( <បុរាណ + ឋាន ) ន. ទីកន្លែងដែលមានយូរមកហើយ, ទីដែលតាំងនៅតាំងពីព្រេងនាយមក ។

បុរាណវត្ថុ ( <បុរាណ + វត្ថុ ) ន. របស់ដែលមានយូរមកហើយ, របស់ដែលមានមកកាលពីព្រេងនាយ ។

ប្រពៃណី = ន. ការទម្លាប់, ការដែលធ្លាប់ធ្វើ, ធ្លាប់និយមពីដើមរៀងមក (Coutume - Mœurs) ។

សក្ខីភាព = ន. ដំណើរដែលជួយដឹងឮ, ដែលជាកស្តុតាង, ជាសាក្សី (Témoin) ។

វិត្ថារកម្ម = (ម.ថ.វិត-ថា-រ៉ាកាំ) ន. អំពើទូលាយ, កិច្ចការទូលាយ ។

សកម្មភាព = ន. ភាពដែលកំរើក, ដែលមានដំណើររស់រវើក, ដែលមានចលនាជានិច្ច (Activité) ។

រួមសំវាស = ន. ការនៅរួមគ្នា, ការនៅជាមួយគ្នា, ការរួមបវេណី ។ សរសេរជា សង្វាស ក៏បាន ។

វេវចនស័ព្ទ

ពិភពលោក - សាកលលោក ។

សុវណ្ណ - មាស ។

សទិសស័ព្ទ

## លិប - លេប

លិប = កិ. លិចបះបាត់ទៅ, ចូលកប់បាត់ទៅក្នុងទឹកជាដើម= ថ្ងៃក្រលិច, ព្រះអាទិត្យលិច ។

លិប = (ម.ថ.ឡិច) ន. ឈ្មោះទិសដែលព្រះអាទិត្យស្តង្គត, ទិសបស្ចិម ។

លេច = ក. ចេញពីទីកំបាំង : ស្រាប់តែលេចពីក្នុងព្រៃ ។

ជ្រាបហូរចេញ = ទឹកលេចពីក្អស្រែ ។

ធ្លាយឬលាន់ចេញ = លេចសំដី, លេចដំណឹង ។ល។...

លេច = ខ. ដែលមិនគត់ = ក្អមលេច, ផ្ទះលេច, ការុងលេច ។ល។..

លេច = គ. ឈ្មោះដំបៅមួយយ៉ាង = ដំបៅលេច ។

អក្ខរាវិរុទ្ធ

ឋិត ឬ ស្ថិត ។ ឋាន ឬ ស្ថាន ។ សមុទ្ទ ឬសមុទ្រ ។ សង្កាស ឬ សំកាស ។ បុរាណ ឬ បូរាណ ។ ធម្ម ឬ ធម៌ ។ អារ្យធម៌ ឬ អារិយធម៌ ។ សុវណ្ណ ( ណ្ណ ), វិត្ថារកម្ម ( ត្ថារ ), សំកាស ( សំ )

## សំណួរ

១ – ចូរពន្យល់ពាក្យ : អារ្យធម៌ , សន្តតិ , អរញ្ញជន , សក្តីភាព , វិត្ថារកម្ម ។

២ -- ចូររកវេវចនសព្ទនៃពាក្យ : សុវណ្ណ ។

៣ – ចូររកសទិសសព្ទនៃពាក្យ : លេប ។

៤ – ដូចម្តេច បានជាគេឲ្យឈ្មោះប្រទេសខ្មែរថា "ជ្រោយសុវណ្ណភូមិ" ?

# ក្រុងលង្វែក

ក្រុងលង្វែកជាបុរាណរាជធានីនៃកម្ពុជរដ្ឋ ឋិតនៅខាងទិសឦសាននៃក្រុងឧដុង្គមានជ័យ សព្វថ្ងៃតាំងនៅក្នុងខេត្តកំពង់ឆ្នាំង ។ ព្រះបាទសម្តេចព្រះភូមិន្ទនរបតីបរមបពិត្រជាខេមរប្រមុខក្នុងសម័យបុរាណ បានទ្រង់ត្រាស់ព្រះរាជបញ្ជាឲ្យកសាងព្រះរាជនិវេសន៍វាំងក្នុងទីនោះ ឲ្យដាំសុទ្ធតែឫស្សីរលៀកគុម្ពធំ ៗ ព័ទ្ធហ៊ុំជុំវិញវាំង ជាភាគកំពែងដ៏គ្រាស់ជិតស្និទ្ធល្អ ទុកចិត្តថាជាបាការភាពស្ថាពរ សន្មតជានគរមានគ្រឿងការពារដ៏ស្តុកស្តម្ភមាំមួន ល្មមធន់ទ្រាំទប់ទល់នឹងការពុះពារយាយីនៃពួកបច្ចាមិត្រ បើទុកជាមានបុទ្ធានុភាពខ្លាំងពូកែស័ក្តិសិទ្ធិប្រោះប្រាជ្ញ ក៏ពុំអាចនឹងប្រទូស្តបានឡើយ ។ ប៉ុន្តែដោយសន្តិសុខសម្រាន្តក្សាន្តបាករណភ័យ នាំឲ្យរដ្ឋាធិបតីរវាតឃ្លាតបាកសតិសម្បជញ្ញធ្លាក់ចុះក្នុងការធ្វេសប្រហែស រដ្ឋាភិបាលប្រើកិរិយាក្រអែសមិនសូវ

ប្រុងប្រយ័ត្នដោយម៉ឺនម៉ាត់ កម្ពុជាណាចក្រក៏វិបត្តិទៅជាកើត
កោលាហល ពលរដ្ឋទាំងសាកល ភ័យជ្រួលច្របល់របល់ទាំង
មន្ត្រីទាំងរាស្ត្រ ពួកសត្រូវបានឱកាសក៏លើកទ័ពចូលដល់មកព័ទ្ធ
ឡោមបោមវាយបន្ទាយលង្វែកបែកខ្ទេច ដល់នូវបរាជយភាព ។
កម្ពុជប្រទេសថយអំណាចចុះទន់ទាប ព្រោះតែប្រមាទធម៌និង
ការបែកសាមគ្គី ។

គួរពួកនរៈនិងនារីខេមរជាតិ ឧស្សាហ៍ខ្មីឃ្មាតសង្វាតរៀន
វិជ្ជានិងសីលធម៌ គួរតាំងអធ្យាស្រ័យបំពេញសាមគ្គីសស្មោះសរ
កគ្នាឲ្យបរិបូណ៌ឡើង ដើម្បីសាងមាតុភូមិយើងឲ្យបានចំរើនរុង
រឿងដូចដើមឡើងវិញ ។

វិញ្ញាសាប្រឡងប្រជែងជ្រើសរើសលេខាធិការ ការិយាល័យនឹងខេត្តឆ្នាំ១៩៥៨ ។

ពន្យល់ពាក្យ

បុរាណរាជធានី=( < បុរាណៈចាស់+រាជធានីៈ ទីក្រុង )ន.ទីក្រុ

ចាស់ (Ancienne capitale) ។

ភូមិន្ទ ឬ ភូមេន្ទ្រ=(ភូមិ+ឥន្ទ)ន. អ្នកដែលធំជាងអស់ប្រជាជ

នៅលើផែនដីគឺស្ដេច, ព្រះរាជា (Roi) ។

នរបតី = ន. ម្ចាស់នៃពពួកមនុស្សៈ ព្រះរាជា ។

បរម = គុ. ខ្ពង់ខ្ពស់, ប្រសើរ, ល្អប្រពៃ

បពិត្រ = ន. អ្នកដែលផ្គត់ផ្គង់, ស្កប់ស្កល់ ដោយទ្រព

សម្បត្តិ ។

ព្រះភូមិន្ទនរបតីបរមបពិត្រ = ស្ដេចដែលជាម្ចាស់ នៃព

មនុស្ស, ដែលមានឋានៈខ្ពង់ខ្ពស់, ដែលល្អប្រពៃ ហើ

ដែលសម្បូណ៌ទ្រព្យសម្បត្តិ ។

និវេសន៍ ន. ទីសំរាក់អាស្រ័យជានិច្ច ។ ពាក្យនេះប្រើខប្រើជារាជ

ព្រះរាជនិវេសន៍គឺព្រះរាជដំណាក់ ព្រះរាជនិវេសន៍ពិជ ពិជដែលព្រះរាជាគង់នៅជានិច្ច ។

បាការភាព = ន. ភាពជាទីមាំមួន, រឹងប៉ឹង ។

បច្ចាមិត្រ = ន. សត្រូវ, (Ennemi)

ឫទ្ធានុភាព = ( <ឫទ្ធិ+អានុភាព ) ន. អំណាចដ៏ខ្លាំងក្លា, កម្លាំងនៃអំណាច ។

ស័ក្តិសិទ្ធិ = គុ. ដែលខ្លាំងពូកែ, ពុតឆាប់ ។

ប្រទូស្ត = កិ. បៀតបៀន, រករឿងហេតុនាំឲ្យវិនាស, បំផ្លាញ ។

រណភ័យ = ( រណៈ សង្គ្រាម + ភ័យ ) ន. ភ័យដែលកើតឡើងពីសង្គ្រាម ។

សតិសម្បជញ្ញៈ = ( សតិ : ស្មារតី + សម្បជញ្ញៈ ការមិនភ្លេចខ្លួន ) ន. ការមានស្មារតីមិនភ្លេចខ្លួន, ការប្រុងប្រយ័ត្នស្មារតីជានិច្ច (Mémoire-conscience) ។

កោលាហល = ន. សេចក្ដីកររ, ច្រួលច្របល់ ។

បរាជ័យភាព = ន. ភាពដែលចាញ់គេ ។

សីលធម៌ =( ម.ថ.សីលៈធ័រ ) ន. ការប្រកបដោយធម៌ គឺការ

ដឹងខុសត្រូវ (Moralité) ។

វេវចនស័ព្ទ

ជោគជ័យ - ជ័យជំនះ ។

ខេមរ - ខ្មែរ ។

បច្ចាមិត្រ - សត្រូវ - បរប័ក្ស ។

សទិសស័ព្ទ

| ស្ថិត - ស្ថិទ្ធិ |
|---|

ស្ថិត = ន. សំណុំផ្លែចេក ដែលនៅជាប់នឹងស្ទង=ចេកមួយ

ស្ថិត ។

ស្និត = ន. ក្រាសមួយយ៉ាងមានធ្មេញញឹកតាំងសងខាង ល្អិតញឹកជិតគ្នា សម្រាប់សិតឲ្យដោយចៃ : ស្និតសិតចៃ ។

ស្និទ្ធ = (ម.ថ. ស្និត) គុ. ដែលជាទីស្រឡាញ់, ជាទីរាប់អាន, ជាទីពេញចិត្ត : ស្និទ្ធស្នាល, ស្និទ្ធស្នេហា ... ។

## សម័យ - ស្រមៃ

សម័យ = ន. កាល, វេលា, ពេល, រដូវ, គ្រា = សម័យនិយម, បុព្វណ្ហសម័យ ។

ស្រមៃ = កិ. នឹកដល់ហាក់ដូចជាឮឬឃើញ ឬ ជានឹងបានតាមបំណង : ខ្ញុំស្រមៃហាក់ដូចជាត្រូវឆ្នោត ។

### អក្ខរាវិរុទ្ធ

ភូមិន្ទ ឬ ភូមេន្ទ្រ ។ រាំង ឬ វង៉ ។

ខេត្ត ឬ ខេត្រ ឬ បច្ចាមិត្ត ឬ បច្ចាមិត្រ ។ 6

ស្តុកស្តម្ភ ( ស្តម្ភ ) ; ស្ថាពរ ( ស្ថា ); ស័ក្តិសិទ្ធិ ( សិទ្ធិ ) ;

ប្រទុស្ត ( ស្ត ) ; សម្រាន្ត ( ន្ត ) ; ក្បាន្ត ( ន្ត ) ; ។

ចំណាំ

## ប្រមាថ - ប្រមាទ

ពាក្យទាំងពីរនេះ ជាសទិសស័ព្ទ ហើយមានន័យប្រហាក់ប្រហែលគ្នា អាចឲ្យអ្នកសរសេរច្រើនតែភាន់ច្រឡំ ។

ប្រមាថ = ន. ការបៀតបៀន ; ការញាំញីគេ, ការធ្វើទុក្ខបុកម្នេញឲ្យគេលំបាក ។ ប្រើជាកិរិយាស័ព្ទក៏បាន: មនុស្សប្រមាថសត្វ ។

ប្រមាទ = ន. ការភ្លេចស្មារតី, ធ្វេសស្មារតី, សេចក្ដីប្រហែស ។ ប្រើជាកិរិយាស័ព្ទ មានន័យថា: ភ្លេច, ធ្វេស, ប្រហែសស្មារតី ។ ប្រើតាមទម្លាប់ថា "មើលងាយ" ក៏បាន ។

សំនួរ

១ - ចូរពន្យល់ពាក្យ : នរបតី, ព្រះភូមិន្ទនរបតីបរមបពិត្រ,

និវេសន៍, សតិសម្បជញ្ញៈ ។

២ – ចូររកវេវចនស័ព្ទនៃពាក្យៈ បច្ចាមិត្ត ។

៣ – ពាក្យ "ប្រមាថ" នឹង "ប្រមាទ", មានន័យផ្សេងគ្នាដូចម្ដេចខ្លះ?

៤ – ចូរសម្ពន្ធឃ្លាទី ២ នៃអត្ថបទនេះ ។

៥ – តើអ្នកនិពន្ធអត្ថបទនេះមានគំនិតបែបណា ?

# យុវជននឹងការប្រឡង

កាលពីដើមឲ្យតែជិតដល់ពេលប្រឡង មានយុវជនយើងមិនតិចទេឡើយ ហើយធម្មតាគឺមាមីង, ឪពុកម្ដាយបងប្អូនច្រើនរវះរវាមទៅនិមន្តព្រះសង្ឃសូត្រមន្តដំឡើងរាសីឲ្យបេក្ខជន ដើម្បីឲ្យមានជ័យជំនះក្នុងការប្រឡងយកសញ្ញាបត្រ មិនតែប៉ុណ្ណោះ មានបងប្អូនខ្លះទៀតរត់ទៅរកហូតដល់ហោរា ឲ្យព្យាករយលេខអត្តៈគិតគូរមើលតើ “កូនបុក្ខយ” របស់ខ្លួនជាប់ឬធ្លាក់ ធ្វើហាក់ដូចជាមេប្រយោគបូកពិន្ទុដូចោះដៃ ។

គ្រោះថ្នាក់នៃការផ្សាយលទ្ធផលមុនពេលប្រឡងដូច្នេះរាស្ថិតនៅត្រង់ឥទ្ធិពលនៃការទាយនេះ ដែលនឹងអាចមានទៅលើសតិអារម្មណ៍របស់បេក្ខជនគ្រប់បែបយ៉ាង ៗ ពេលជិតប្រឡងបើបានដំណឹងថាជាប់ បេក្ខជនដែលកំពុងតែខំប្រឹងរៀនសូត្របែរជាអាងថាខ្លួនជាប់ហើយ គឺមិនរវល់នឹងខំប្រឹងរៀនសូត្រទៅទៀតនាំឲ្យធ្លាក់ទៅវិញក៏មាន ។ ចំពោះបេក្ខជនដែលបានដឹងជាមុនថា

នឹងប្រឡងធ្លាក់នោះ ជាការនាំឲ្យលំអក់ចិត្តខ្លាំងណាស់ គឺចិត្តដែលគេគំពុងដុសខាត់ឲ្យបានបរិសុទ្ធ មុនពេលទៅប្រឡង ។ ហើយបើសិនជាលទ្ធផលនៃការប្រឡងបានបង្ហាញផ្ទុយពីការគាយរបស់គេហោកទៅវិញ នោះសាមគ្គីភាពរវាងមេក្ខជននឹងហោរក៏បែកបាក់តំណួខាន ។

ប៉ុន្តែគង់សម័យវិទ្យាសាស្ត្រនិយម-សម័យឯកភាព , ជំនឿមិនសមហេតុផល ពោលគឺអបិយៈជំនឿរបៀបនេះក៏វិនាសសាបសូន្យបន្តិចម្តង ៗ ទៅដែរ ។ ប្រជាជនសម័យវិទ្យាសាស្ត្រច្រើនតែយល់ថាៈហោរាតាំងឡាយ មិនដែលតាំងជឹងអំពីគម្ពីរ នៃការប្រឡងផង ធ្វើម្តេចនឹងមានសមត្ថភាពទាយឲ្យគេទៅកើត? ។

ម្យ៉ាងទៀតការប្រឡងជាប់ មិនមែនជាបញ្ហាសំណាងទេ ហើយមិនមែនជាបញ្ហាថែជន្សទៀតផង ព្រោះការប្រឡងជាប់នឹងធ្លាក់នេះវាគ្រាន់តែជាសក្ខីភាពនៃការគ្រាប់គ្រង់ របស់សិស្សតែប៉ុណ្ណោះ ។ បើសិស្សមានវិរិយភាពក្នុងការរៀនសូត្រ សិស្ស

កំប្រឡងជាប់ តែបើសិស្សខិលច្រអូសមិនខំប្រឹងរៀនសូត្រ លទ្ធផលនៃការប្រឡងកាន់តែអន់ថយឲ្យដោយផុយជាជាប់ខាត ។

ពាក្យលំពាក្យ

និមន្ត = (សង្ឃស័ព្ទ) កិ. អញ្ជើញ, សូមឲ្យទៅ ឬ សូមឲ្យមក ។

បេក្ខជន = ន. អ្នកចូលរួមក្នុងការប្រឡង ឬ ចូលរួមក្នុងការឈរឈ្មោះឲ្យគេបោះឆ្នោត ជ្រើសរើស (Candidat) ។

សញ្ញាបត្រ = ន. សន្លឹកក្រដាស ដែលក្រសួងមានសមត្ថកិច្ចចេញឲ្យសម្រាប់សំគាល់ នូវវិជ្ជាអ្វីមួយ (Diplome) ។

ព្យាករ = កិ. ពោលអួត, ទាយ (Deviner) ។

លេខអត្ថ: = លេខដែលពូកពោក គិតគូរតាមក្បួនពោហាររបស់ខ្លួន ។

លទ្ធផល = ន. ផលដែលសម្រេចក្រោយពីការបំពេញមុខងារ

អ្វីមួយ (Résultat) ។

ឥទ្ធិពល = (ម.ប.អិត.ធិ-) ន. អំណាច, កម្លាំង ។

សតិអារម្មណ៍ = ន. ចិត្ត, គំនិត (Esprit, mémoire)។

សាមគ្គីភាព = ន. ការរួបរួមគ្នា, ការទាក់ទងគ្នា ។

សម័យវិទ្យាសាស្ត្រនិយម = សម័យដែលប្រជាជនទូទៅនិយមវិទ្យាសាស្ត្រគឺបោះបង់ចោល នូវជំនឿមិនសមហេតុសមផល ។

អបិយជំនឿ = ន. ជំនឿអាក្រក់, ជំនឿផ្តេសផ្តាស, ជំនឿដែលផ្តល់នូវសេចក្តីអន្តរាយដល់មនុស្សលោក ។

កម្មវិធី = (ម.ប.កាំ.ម:-) ន. បែបផែនដែលគេបានគ្រោងទុកជាមុនក្នុងមុខការអ្វីមួយ (Programme) ។ កម្មវិធីសិក្សា = (Programme scolaire) ។

សមត្ថភាព = ន- ភាពនៃសេចក្តីក្លាហាន, មុះមុត (Capacité) ។

បៃដិស្ស = ន. ការកើតឡើងដោយមិនដឹងខ្លួន, ដោយមិនបាន ប្រុងប្រៀបទុកជាមុន គឺកើតឡើងដោយឯង ៗ ។

សក្ខីភាព = (ម.ប.ស័ក.ខី) ន. ភាពដែលកំណត់យកជាគ្រឿង សំគាល់, យកជាសាក្សី (Témoignage) ។

វិរិយភាព = ន. ភាពនៃការព្យាយាម, ការខំប្រឹងប្រែង ។

វេវចនស័ព្ទ

ព្យាករ - ទាយ - គន់គូរ ។

ឥទ្ធិពល - កម្លាំង - អំណាច - តេជៈ ។

សទិសស័ព្ទ

| អត្ត-អត្ថ-អត្តៈ-អាត់ |
|---|

អត្ត = (ម.ប.អ័ត តៈ) ន. ជាពាក្យបាលី, សំស្ក្រឹតជា អាត្មន៍ គឺខ្លួន, ចិត្ត ៗ ពាក្យដែលផ្ដើមឡើងពី អត្ត គឺ៖

អត្ត កិលមថានុយោគ=ការប្រកបព្យាយាមតឹងហួសពេក នាំឲ្យ

នឿយលំបាកខ្លួនឥតប្រយោជន៍ ។

អត្តឃាតកម្ម អត្តវិនិបាតកម្ម=ការសម្លាប់ខ្លួនឯង ។

អត្តទត្ថបុគ្គល បុគ្គលដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន ។

អត្តទន្ត = អ្នកទូន្មានខ្លួន , អ្នកបង្ហឹកខ្លួន ។

អត្តពលកម្ម = ការដែលកើតឡើងពីកម្លាំងខ្លួន ។

អត្តធីនភាព = សេរីភាព ។

អត្តហេតុ = ការឃើញប្រយោជន៍ផ្ទាល់ខ្លួន ។

អត្តនុវាទភ័យ = ភ័យអំពីការតិះដៀលខ្លួនឯង ។

អត្តុក្កំសនកថា = សំដីលើកខ្លួនឯង ។

អត្តុក្កំសនភាព = ការលើកដំកើងខ្លួន ។ល។ --- ។ល។ ---

អត្ត:=(ម.ជ-អ័ត.ត:) សូមមើលសេចក្តីពន្យល់ខាងលើ ។

អត្ថ = (អ.ថ-អ័ត) ន.ប្រយោជន៍ ។ ពាក្យដែលផ្តើមឡើងពី អត្ថ គឺ៖

អគ្គគោវិទ = អ្នកប្រាជ្ញ ។

អគ្គគវេសនា = ការស្វែងរកប្រយោជន៍ ។

អគ្គរស = ខ្ទឹមសារនៃសេចក្តី

អគ្គវិនាស = ការខូចប្រយោជន៍ ។

អគ្គសម្ពន្ធិន = អ្នកដែលត្រូវបានទ្រព្យសម្បត្តិ ។

អាត់ = គុ-តូប , ក្រិស = សេកអាត់ , ស្វាយអាត់ ។

អាត់ = ន-ឈ្មោះមេក្រមីដែលនៅក្រោមស្បែកមានទឹករងៃថ្លា ៗ

អាត់ដៃ = រវល់ដៃ ។

## អគ្គាភិរុទ្ធ

សំរេច ឬ សម្រេច ។ ថៃជន្យ ឬ ថៃជន៍ ។

វីរិយៈ ឬ វិរិយៈ ឬ វីរិយ ឬ វិរិយ ។

កម្មវិធី ( កម្ម ) កុំច្រឡំនឹងពាក្យ " កាំ " : កាំរស្មី ។

## ចំណាំ

### និមន្តន៍-និមន្ត

ពាក្យទាំងពីរនេះជាសន្តានពាក្យ តែមួយជានាមស័ព្ទ, មួយជាកិរិយាស័ព្ទ ហើយត្រូវសរសេរខុសគ្នា ។

និមន្តន៍ = ជានាមស័ព្ទ (សង្ឃស័ព្ទ) មានន័យថា ការអញ្ជើញ, ការសូមឲ្យទៅឬឲ្យមក ។ សរសេរមាន "ន៍" នៅខាងចុង ។

និមន្ត = ជាកិរិយាស័ព្ទ សរសេរគ្មាន "ន៍" នៅខាងចុងទេ ។

### ព្យាករណ៍-ព្យាករ

ពាក្យទាំងពីរនេះក៏ជាសន្តានពាក្យ តែមួយជានាមស័ព្ទ, មួយជាកិរិយាស័ព្ទ ហើយត្រូវសរសេរខុសគ្នាដែរ ។

បើប្រើជានាមស័ព្ទ ត្រូវសរសេរជា ព្យាករណ៍ ។

បើប្រើជាកិរិយាស័ព្ទ ត្រូវសរសេរជា ព្យាករ ។

## សំណួរ

១- ចូរពន្យល់ពាក្យ : បេក្ខជន, ឥទ្ធិពល, សម័យវិទ្យាសាស្ត្រនិយម, អបិយជំនឿ ។

២- ចូររកវេវចនស័ព្ទនៃពាក្យ: ព្យាករ ។

៣- ចូររកសទិសស័ព្ទនៃពាក្យ: អត្ត ។

៤- ចូរសម្គាល់វេយ្យាករណ៍ (Annalyse grammaticale) នូវឃ្លាដូចតទៅនេះ៖ " មេប្រយោគបូកពិន្ទុ " ។

៥- អត្ថបទខាងលើនេះ បង្ហាញឲ្យយើងឃើញដូចម្តេចខ្លះ ? ក្នុងសម័យវិទ្យាសាស្ត្រនិយម តើយើងត្រូវយកអបិយជំនឿមកជាគន្លងទៀតឬទេ? ព្រោះអ្វី ?

## សាលារៀនជាឆាកទីហ្វឹកហ្វឺនដើម្បីប្រកប ជីវភាពក្នុងសង្គម

សាលារៀនមិនមែនមានគោលបំណង សម្រាប់តែបង្រៀនប៉ុណ្ណោះទេ សាលារៀនមានបេសកកម្មមួយទៀតដ៏សំខាន់គឺបេសកកម្មដឹកនាំកុមារអំពីគ្រួសារឲ្យចូលទៅកាន់សង្គម ។

សាលារៀនដែលទទួលយកកុមារ មានអាយុចាប់តាំងពី៥ ឬ៦ឆ្នាំ ហើយដែលបើកឲ្យកុមារចេញមកវិញ នៅអាយុ ១៤ ឬ ១៥ ឆ្នាំនោះ (បើនិយាយអំពីសាលាបឋមសិក្សា) ជាអង្គការដែលតែងស្រូបយកកុមារចេញអំពីបរិយាកាសគ្រួសារ ដ៏ជិតស្និទ្ធនោះ ដើម្បីឲ្យវាឆ្លងទៅកាន់វិជ្ជាជីវៈ ឬ ជីវភាពពិតប្រាកដ ដែលទើបនឹងផ្តើមកំណើតឡើងក្នុងសង្គមនោះឯង ។ មុខងារដែលគេពុំស្គាល់ ឬ ដែលគេច្រើនបំភ្លេចពេលនោះ មិនមែនមុខងារប្រកបដោយប្រយោជន៍តិចជាងគេនោះសោះឡើយ ។

លុះយុវភាពជាបឋម "៣ឆ្នាំ" ដែលជាសម័យក្មេង នៅក្នុងអនិស្សរភាពនៃមាតានោះបានចប់ហើយ សម័យមួយថ្មីចាប់ផ្តើមឡើង ដែលនៅពេលនោះមុខងាររបស់បិតា ជាការសំខាន់ឯក ដើម្បីការដុះដាលនៃកុមារ ឬ អាចារមារយាទនៃបិតាអាចជួយសំរួល ឬ ស្ទាក់ទប់នូវការដុះដាលមជ្ឈិមវ័យនៃកុមារ ។

គឺពេលនេះហើយ ដែលសាលារៀនចូលមកក្នុងជីវភាពនៃកុមារ ។

គូកននឹងគ្រូអាចារ្យម្ខាង ម្ខាងទៀតឪពុកម្ដាយ អ្នកទាំងអស់គ្នាត្រូវហ្វឹកហ្វឺនក្មេង ដើម្បីនាំវាទៅជួបសុកុមារភាពនៅអាយុ១៥ ឬ១៦ ឆ្នាំ ។ បើក្មេងមិនទៅសាលាទេនោះ វានឹងនៅតែស្រឡាញ់តែម្ដាយឬឪពុកវា ក្នុងភាពជាក្មេងជានិច្ច ។ ហើយបើសាលាក៏គ្មានគ្រួសារក៏គ្មានផងនោះ គេនឹងឃើញកើតឡើងបាននូវហ្វូងក្មេងអនាថា ដូចច្រើនមាននៅអឺរ៉ុប និងសហរដ្ឋអាមេរិក ។

នៅសេស

## ពាក្យលំបាក

ហ្វឹកហ្វឺន = (ម.ថ ហ្វឹក.ហ្វឺន) កិ. ណែនាំ, ដឹកនាំ ។

ជីវភាព =ន- ការរស់នៅ, ដំណើរនៃការរស់នៅ (Vie) ។

១. ជីវភាពកម្មករខុសអំពីជីវភាពនាយទុន ។

សង្គម = ន- ក្រុម, បក្ស, ពួក, ក្រុមហ៊ុន (Société) ។ សង្គមមនុស្ស (Société humaine) ។ ក្នុងទីនេះ គឺការប្រមូលផ្តុំគ្នាជាក្រុម, ជាពួក ។

បេសកកម្ម=(ម.ថ.បេ.សៈ.កៈ-កំ) ន- ការបំពេញមុខងារអ្វីមួយ, ការបំពេញការៈ ក្នុងកិច្ចការណាមួយ (Mission) ។

អង្គការ ន- ទម្រង់នៃកិច្ចការណាមួយ, បែបផែននៃកិច្ចការ (Organisation) ។

បរិយាកាស (ម.ថ.បរិយាកាស) ន- អាកាសនៅជុំវិញខ្លួនយើង (Atmosphère) ។

វិជ្ជាជីវៈ = ន. របររកស៊ីចិញ្ចឹមជីវិត, មុខងារ (Profession) ។

យុវភាព = ន. ភាពដែលនៅក្មេង, ភាពរបស់ក្មេង (Jeunesse) ។

ជាបឋម = ជាដំបូង, ជាមុន ។

អធិស្សរភាព ន. ភាពដែលមិនមានឥស្សរៈភាព, ភាពដែល
មិនមែនជាធំខ្លួនឯង គឺភាពដែលត្រូវនៅក្រោម
ការគ្រប់គ្រងរបស់អ្នកដទៃ (Dépendance) ។
ក្មេងនៅក្នុងអធិស្សរភាពរបស់មាតាបិតា: ក្មេង
នៅក្នុងការគ្រប់គ្រង របស់មាតាបិតា ។

អាចារ = (ម ចិ.អា ចា.រះ) ន. គំនិតមារយាទ, សណ្ដាប់ធ្នាប់,
កិរិយា, បុគ្គល (Comportement) ។

មជ្ឈិមវ័យ = (ម.ចិ.ម៉ុច.ឈិម – ) ន. វ័យជាចន្លោះកណ្ដាលនៃ
បឋមវ័យនឹងបច្ឆិមវ័យ គឺវ័យពាក់កណ្ដាល ។

សុកុមារភាព = ន. ភាពនៃកុមារ ។

អគាថា = គ. ដែលឥតទីពឹង, ឥតពុំនាក់ ។ ក្មេងអនាថា=
ក្មេងគ្មានឳពុកម្ដាយ ដែលដើរតែលតោល ព្រោះរកបាយ
ស៊ីគ្មាន ។

សហរដ្ឋ = (ម.បិ.សៈ.ហៈ-រ័ត) ន. រដ្ឋជាច្រើនដែលរួមបញ្ចូល
គ្នាក្នុងការគ្រប់គ្រងរបស់ប្រធានាធិបតីតែមួយ
(EtatsUnis)
សហរដ្ឋអាមេរិក (Les E as-Unis d'Amérique) ។

វេវចនស័ព្ទ

កុមារ ក្មេង ។

សម័យ - កាល - ពេល - វេលា ។

សទិសស័ព្ទ

## អាហារ-អាហារ្យ

អាហារ ឬ អាហារៈ = (ម.បិ.អា.ហា.រៈ) ន. ការប្រព្រឹត្តិ, ចរិយា,[7]
ឫក, ឫកពារ, មារយាទ, បែបបទ, សណ្ដាប់ធ្នាប់ : មាន

ចារៈល្អ, មានអាចារៈពុំសមគួរ ។ បាលី: អាចរិយ

អាចារ្យ = (ម.ថ.អា.៣) សំស្ក្រឹត: អាចាយ៌ តែខ្មែរយើងប្រើជា

អាចារ្យ ដើម្បីឲ្យស្រួលងាយមើល អ្នកប្រដៅឬ

ហាត់មារយាទ , អ្នកប្រព្រឹត្តល្អ , អ្នកកាន់,

ប្រព្រឹត្តត្រឹមត្រូវ = គ្រូអាចារ្យ ។

កុំច្រឡំនឹងពាក្យមួយទៀតគឺ អនាចារ=ការប្រព្រឹត្តខុសបែបបទ ។

អក្ខរាវិរុទ្ធ

ហ៊ឹកហ៊ឺន ឬ វ៉ឹកវ៉ឺន ។ ហ៊ុន សរសេរជាវ៉ូន មិនបានទេ ។

អនាថា កុំសរសេរជា អានាថា ។

## អំពីវិសជ្ជនីយ និងយុគលពិន្ទុ

គេច្រើនច្រឡំវណ្ណយុត្តិទាំងពីរនេះជាញឹកញយ ក្នុងការសរសេរ ។ ដើម្បីកុំច្រឡំ ចូរចំណាំដូចតទៅ ៖

វិសជ្ជនីយ = “ ះ ” - សម្រាប់ប្រើជំនួសខ្យល់ “ ស ” គួប្រកប

នៅក្នុងពាក្យដែលកើតឡើងពីស្រៈ ( អ ), ( ិ ), ( ុ ), ( េ ), ( ៃ ), ( ោ ), ( ើ ) ។ ឧទាហរណ៍ បះ-ដិះ-បុះ សេះ-ផែះ-តោះ-បង្កើះ- ។ ល ។ ...

យុគលពិន្ទុ = " : " - សម្រាប់ប្រើញ៉ាំងស្រៈ " អ " ដែលជាទីបំផុតនៃពាក្យបាលីនិងសំស្ក្រឹត ឲ្យចេញសូរស័ព្ទពេញមាត្រាដើម្បីជាជំនួយក្នុងការអានឲ្យបានត្រឹមត្រូវម៉ត់ចត់ តាមបែបបាលីនិងសំស្ក្រឹត ។ ឧទាហរណ៍ៈឆន្ទៈ- ទីយសរៈ ធម្មរតនៈ- ជរាលក្ខណៈ- ទន្ដជៈ- នហារនោទកៈ- លក្ខណៈ ។ល។

## សំណួរ

១ - ចូរពន្យល់ពាក្យ: បេសកកម្ម, បរិយាកាស, អនិស្សរភាព, សហរដ្ឋ ។

២ – ចូររកសទិសស័ព្ទនៃពាក្យ : អាចារ ។

៣ – ចូររកវេវចនស័ព្ទនៃពាក្យសម័យ ។

៤ – ចូរពន្យល់អំពីវណ្ណយុត្តិ "វិសជ្ជនី និងយុគលពិន្ទុ" ។

៥ – ចូរពន្យល់អំពីឧត្តមគតិនៃអ្នកនិពន្ធអត្ថបទនេះ ។

# វិជ្ជានិងសីលធម៌

មនុស្សទាំងឡាយ ដែលមានចំណេះវិជ្ជា ហើយនឹងយកវិជ្ជានោះទៅធ្វើឲ្យទៅជារបស់អ្វីផ្សេងៗបាន លុះណាតែមនុស្សនោះមានដើមគំនិតបញ្ញាដែលដើងឲ្យធ្វើរបស់នោះ ទើបសំរេចទៅបាន ។ ហើយដើមគំនិតនេះទៀតដែលជាអ្នកកាច់ចង្កូតមនុស្សរាអាចមានគោលបំណងគាប់ប្រសើរឬចង្រៃអាក្រក់ ទៅតាមតែការអប់រំនឹងសីលធម៌របស់មនុស្សនោះ ៗ ដូច្នេះសីលធម៌កាច់ចង្កូតដើមគំនិត ហើយដើមគំនិតដឹកនាំមនុស្សប្រើចំណេះវិជ្ជាឲ្យធ្វើការ ៗ គឺជាស្នាដៃឬការងារនៃមនុស្សនោះរាគាប់ប្រសើរនឹងផ្តល់នូវសារគុប្រយោជន៍ដល់សង្គមជាតិយើងបាន បើសិនជាមនុស្សនោះប្រកបដោយសីលធម៌ ៗ ផ្ទុយពីនេះ បើសិនមនុស្សនោះគ្មានសីលធម៌ទេ នោះការងាររបស់គេក៏ប្រែជាផ្តល់នូវគ្រោះសប្បដ៏ភ័យនឹងភយន្តរាយទៅវិញ ។

ក្នុងវគ្គខាងលើ យើងបានឃើញប្រត្យក្សថា សីលធម៌កា

ចង្កឹតមនុស្សឲ្យប្រើវិជ្ជា ដើម្បីសំរេចគំនិតអ្វីមួយ ៗ ដូច្នេះបើគ្មានវិជ្ជាទេ ទោះបីមនុស្សនោះ មានសីលធម៌យ៉ាងណាក៏មិនអាចធ្វើការងារដើម្បីលើកដំកើងដល់ភាពសង្គមមនុស្សបានដែរ ៗ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ អ្នកមានសីលធម៌ខ្វះវិជ្ជា ក៏នៅតែគ្រាន់បើជាងមនុស្សមានវិជ្ជាខ្វះសីលធម៌ ទុកណាជាធ្វើខ្លួនឯងមិនកើត ក៏អាចនិយាយប្រាប់គេឯង ដែលមានវិជ្ជាអំពីគោលបំណងរបស់ខ្លួន ឲ្យគេយកគោលបំណងនោះទៅធ្វើបាន ៗ ចំណែកឯអ្នកមានវិជ្ជាខ្វះសីលធម៌ គេអាចធ្វើអ្វីបានទាំងអស់ ព្រោះគេមានបំណេះវិជ្ជា ប៉ុន្តែស្នាដៃគេប្រៀបបានទៅនឹងអតិសុខុមប្រាណដែលបំផ្លិចបំផ្លាញសង្គមជាតិ ឲ្យធ្លាក់ទៅក្នុងអគតិវិនាសយ៉ាងពិតប្រាកដ ៗ

សរុបសេចក្តីមក វិជ្ជានិងសីលធម៌ទាំងពីរមុខនេះ វាជាកង់ទាំងពីរនៃទោចក្រយាន ហើយវាត្រូវតែធ្វើដំណើរព្រមជាមួយគ្នា ទើបអាចជម្រុញប្រទេសជាតិឆ្ពោះទៅកាន់វឌ្ឍនភាពបាន ៗ

## ពន្យល់ពាក្យ

សីលធម៌ = (ម.ថ.សី ឡៈ-ធ័រ) ន. ក្បួនច្បាប់សម្រាប់ហ្វឹកហ្វឺន ចរិយាឲ្យបានត្រឹមត្រូវ (Moralité) ។

បញ្ចោ = កិ. បង្គាប់ ។

អប់រំ = កិ. ហាត់ចិត្ត, បង្ហឹកចិត្ត, ណែនាំឲ្យប្រព្រឹត្តល្អ, ត្រឹមត្រូវ (Eduquer) ។

សារត្ថប្រយោជន៍ = (ម.ថ.សា.រ័ត.ថៈ) ន. (សារ + អត្ថ + ប្រយោជន៍) ប្រយោជន៍សំខាន់ ។

សប្បដិភ័យ = (ម.ថ.ស័ប បៈ-ឌិ.ភ័យ) គុ. ដែលប្រកបដោយ ភ័យដ៏ពន្លឹក, ដែលមានភ័យខ្លាំងក្រៃ ។

ភយន្តរាយ = (ម.ថ ភៈយ័ន.តៈរ៉ាយ) ន. (<ភយ + អន្តរាយ) អន្តរាយដែលគួរឲ្យភ័យ, អន្តរាយយ៉ាងសំបើម ។

ជីវភាព = ន.ការរស់នៅ, ជីវិតដែលរស់នៅ, ដំណើរនៃការរស់នៅ (Vie) ។ ជីវភាពសង្គម = ដំណើររស់នៅរបស់ប្រជាជនក្នុងសង្គម (Vie sociale) ។

អតិសុខុមប្រាណ = ន. សត្វល្អិតដែលជាមេរោគ, សត្វរោគ, មេរោគ (Microbe) ។

អត្ថវិនាស = ន. ការនាំឲ្យខូចប្រយោជន៍ ។

វិឌ្ឍនភាព = ន ការចំរើនដុះដាល, លូតលាស់ (Progrés) ។

### វេវចនស័ព្ទ

អប់រំ-ហ្វឹកហ្វឺន-ណែនាំ-បង្ហាត់បង្រៀន ។

### សទិសស័ព្ទ

**ក្រួស-គ្រោះ**

ក្រួស = ន. ថ្មតូចៗ សម្រាប់ក្រាលថ្នល់ : ថ្មក្រួស, ក្រួសអាចម៍ផ្កាយ ។ល។ ...

គ្រោះ = ន. គុណ, ទោស, សុខ, ទុក្ខ, ថ្នាំងថ្នាក់ដែលកើតមាន កន្លងកាលមួយៗ តាមដំណើរអំពើល្អឬអាក្រក់របស់បុគ្គលពល់ រូប: គ្រោះកាច, គ្រោះជា, គ្រោះថ្នាក់, គ្រោះល្អ, គ្រោះអាក្រក់ ... ។

គ្មានពាក្យ "គ្រស" នេះទេ ។

## ប្រៀប ព្រាប ត្រៀប

ប្រៀប = កិ. ធៀប, ប្រដូច=ប្រៀបធៀប, ប្រៀបផ្ទឹម, ប្រៀបប្រាយ, ពាក្យប្រៀប ។

ព្រាប =ន. ឈ្មោះសត្វបក្សីមួយពួក រូបរាងស្រដៀងនឹងលលក: សត្វព្រាប ។

ត្រៀប = គុ-ឬ-កិ-វិ- ដែលពេញកំពុងរកកល់នឹងហៀរ : ពេញត្រៀប, ទឹកជន់ត្រៀបច្រាំង ។

## អក្ខរាវិរុទ្ធ

សម្រេចឬសំរេច ។ ប្រចក្សឬប្រត្យក្ស ។

បង្គត មិនអាចសរសេរជា " បង់គូត ,, យ៉ាងនេះទេ ។

| ពាក្យដែលមានសំឡេង " ុំ " និង " ុះ " |
|---|

ក្នុងពាក្យពីរព្យាង្គ, ព្យាង្គដើមមានសំឡេង " ុំ " ឬ " ុះ " មិនដែលមានបុះជើងទេ ។

ឧទាហរណ៍ :

លំអ-លំនាំ-ជំនុំ-ជំពាក់-តំនួរ-តំរូ ។ល។ ...

លើកលែងតែពាក្យ ជុំវិញ ចេញ ។

### សំណួរ

១–ចូរពន្យល់ពាក្យ : សីលធម៌, សារត្ថប្រយោជន៍,

កយន្តកាយ, វិឌ្ឍនធម៌ ។

២– ចូររកវេវចនសព្ទនៃពាក្យ : អប់រំ ។

៣– ចូររកសទិសសព្ទនៃពាក្យ គ្រោះ ។

៤ ចូរសម្ពន្ធពាក្យ " មនុស្ស " ក្នុងឃ្លាទី ១ នៃអត្ថបទនេះ ។

៥- ហេតុអ្វីបានជាអ្នកនិពន្ធប្រៀបធៀប មនុស្សមានវិជ្ជាខ្វះសីលធម៌ ទៅនឹងមេរោគបំផ្លាញសង្គមជាតិ ?

៦-តើអ្នកនិពន្ធអត្ថបទនេះមានគំនិតដូចម្ដេច ?

## ជម្លោះប្តីនៃមនុស្សបុរាណនឹងមនុស្សទំនើប

យើងតែងតែជជែកការពារ ដើម្បីជំរឿននូវការសិក្សាខាងបច្ចេកទេស និងខាងវិទ្យាសាស្ត្រជាជាងវិជ្ជាដ៏ជ្រៅជ្រះសុទ្ធៗ ។ ក៏ប៉ុន្តែមានមតិខ្លះលេចឡើង ដើម្បីទ្រទ្រង់យោបល់ផ្ទុយពីនេះទៅវិញ ។ មានអ្នកខ្លះយល់ថា ក្នុងពេលដែលវិទ្យាសាស្ត្របានសម្រេចការចំរើនឥតឧបមា ក្នុងប្រវត្តិសាស្ត្រនៃមនុស្សជាតិ ដែលជាហេតុឲ្យកើតមានការ ប្រកួតប្រជែងខាងវិទ្យាសាស្ត្រ ដោយមនុស្សម្នាក់ ៗ មានសង្ឃឹមនឹងបានឈ្នះសត្រូវរបស់ខ្លួន ដោយប្រើមធ្យោបាយ គ្រប់យ៉ាង នៅក្នុងពេលដែលមនុស្សជាតិទាំងមូលអាចនឹងទទួលគ្រោះថ្នាក់ផងនេះ គប្បីយើងប្រញាប់គិត លៃលកចំរើនខាងការសិក្សា នៃបរមត្ថវិទ្យាឲ្យបានគ្រប់សព្វ ។ ពិតមែនថាវឌ្ឍនភាពខាងវិទ្យាសាស្ត្រជាការចាំបាច់ ។ ក៏ប៉ុន្តែវឌ្ឍនភាពនេះ ក៏ត្រូវណែនាំមកនូវវឌ្ឍនភាព

ខាងចរិយាឲ្យបានសមល្មមនឹងគ្នាដែរ ។ ផ្ទុយទៅវិញ គេហាក់ដូចជាភ្លេចលែងឃើញនូវចរិយា គិតតែដំឡៃតែខាងវិទ្យាសាស្ត្រទៅវិញ ។

តាមគោលការណ៍វិទ្យាសាស្ត្រ និងចរិយាសាស្ត្រមិនមែនមិនចុះសម្រុងគ្នាទេ ។ ការនេះសម្រេចនៅលើឆន្ទៈ ចេតនានៃមនុស្សយើងទេ ។ វិទ្យាសាស្ត្រអាចនឹងសម្លាប់មនុស្សក៏បាន ប៉ុន្តែវិទ្យាសាស្ត្រអាចនឹងជួយសង្គ្រោះជីវិតមនុស្ស ក៏បានដែរ ។ ការស្របគ្នា ក្នុងការចំរើននៃវិទ្យាសាស្ត្រ និងចរិយាសាស្ត្រ បេះតែធ្វើទៅកើតទាំងអស់បើមនុស្សយើងមានបំណង × ។ តាំងពីយូរណាស់មកហើយ ក្នុងពេលប្រជុំអង្គការសហប្រជាជាតិក្តី ក្នុងពេលប្រជុំឯទៀត ៗ ក្តី គេតែងយករឿងបន្ថយសព្វាវុធ និងការប្រើប្រាស់កម្លាំងបរមាណូ ក្នុងផលប្រយោជន៍សន្តិភាពមកពិភាក្សា ។ ប៉ុន្តែរហូតមកដល់ឥឡូវនេះ យើងពុំទាន់ឃើញបានផលប្រយោជន៍អ្វីសោះ ដែលជាហេតុឲ្យពលរដ្ឋនៃ

ប្រទេសតូចតាចដូចជាប្រទេសកម្ពុជាយើងជាដើម មានការធ្លាក់ទឹកចិត្តជាខ្លាំង ៗ ហើយប្រជាជាតិទាំងឡាយទៅជាលែងយកសន្និសិទទាំងនោះ ជាការដែលសុទ្ធសឹងតែជាបំណុរឃោសនារបស់ប្រទេស " ធំ ៗ " តែប៉ុណ្ណោះមែន ៗ

ប៉ុន្តែបញ្ហាមិនមែននៅត្រង់នេះទេ ៗ សេចក្តីចំរើនក្នុងការរស់នៅ ការផ្លាស់ប្តូរក្នុងគមនាគមន៍ ក្នុងការទាក់ទងរវាងមនុស្សនឹងមនុស្ស លក្ខ័ណថ្មីៗ នៃការប្រតិបត្តិការងារ ហេតុទាំងនេះនាំឲ្យជម្លោះរវាងមនុស្សបុរាណ នឹងមនុស្សទំនើបទៅជាការឥតប្រយោជន៍ស្មោះ ៗ សេចក្តីយុត្តិធម៌ក្នុងសង្គមនឹងសេរីភាពក្នុងគ្រួសារលែងមានសភាពផ្ទុយគ្នាហើយ ៗ ហើយការបង្ហាត់ខាងបច្ចេកទេស ក៏សឹងតែលែងខុសនឹងការអប់រំមនុស្ស ឲ្យសមជាមនុស្សដែរហើយ ៗ នេះគឺជាអំពើផ្ទុយលែងពិត ឬ ជាការស្មុគស្មាញដែលលែងប្រាកដឡើយ ៗ ផ្ទុយទៅវិញគេអាចផ្តល់ឲ្យអ្នកទាំងអស់គ្នានូវវិជ្ជាជីវៈមួយលើសពីវិជ្ជាទូទៅ ដោយ

ឥតដកហូតអំពីការអប់រំមនុស្ស ឲ្យសមជាមនុស្សនោះបានដោយ

ឥតទាស់អ្វីឡើយ(១) ។

## ពន្យល់ពាក្យ

បច្ចេកទេស = (ម.ជ.ប៉ុច-ចេកៈ-ទេស) ន. ការស្ទាត់ជំនាញខាងវិជ្ជាពិសេសណាមួយ, វិជ្ជាពិសេសដែលលាយនឹងការប៉ុនប្រសប់(Technique) ។

វិទ្យាសាស្ត្រ = ន. វិជ្ជាដែលអ្នកប្រាជ្ញរកឃើញដោយការពិសោធជាតុផ្សេងៗ (Science) ។

មតិ = (ម.ជ.ម៉ុត.តិ) ន. យោបល់, ការយល់ឃើញ, ទស្សនៈ (Opinion, point de vue).

---

១ – អត្ថបទនេះវែងឆ្ងាយសមគួរ ព្រោះយើងពុំអាចកាត់បោលបាន ។ ហេតុនេះក្នុងពេលសរសេរតាមសូត្រ សូមលោកគ្រូមេត្តាកាត់ឲ្យខ្លីផងចុះ ។

ប្រវត្តិសាស្ត្រ=ន. ក្បួនតម្រាដែលនិយាយអំពីរឿងរ៉ាវនៃមនុស្ស
ណាម្នាក់ ឬ និយាយអំពីរឿងរ៉ាវនៃប្រទេស
ណាមួយ (Histoire) ។

ប្រវត្តិសាស្ត្រមនុស្សជាតិ = ន- រឿងដែលកើតមាន
ឡើងក្នុងប្រវត្តិនៃមនុស្ស ។ ឧ.ការបង្ហោះ
នាវាចក្រវាលរបស់សហភាពសូវៀតបានបើក
ទំព័រថ្មីនៃប្រវត្តិសាស្ត្រមនុស្សជាតិ ។

មធ្យោបាយ = ន. ការរិះរកផ្លូវ ឬ វិធីណាមួយសម្រាប់ដោះ
ស្រាយរឿងរ៉ាវឬបញ្ហាផ្សេងៗ (Moyen) ។

បរមត្ថវិជ្ជា = (ម.ថ.ប៉ៈ-រ៉ៈ-ម៉ុត-ថៈ) ន. វិជ្ជាយ៉ាងល្អិតល្អន់សម្រាប់
រៀនរិះរកសេចក្ដីផ្សេងៗ

---

វឌ្ឍនភាព = (ម.ថ.វ័ត-ធៈ-នៈ-) ន. ការចំរើនលូតលាស់ ដំណើរ
ជឿនលឿនជុះដាល (Progrés) ។

បរិយា = ន. បុគគារ , ការប្រព្រឹត្ត ฯ

បរិយាសាស្ត្រ = ន. វិជ្ជាអប់រំឲ្យមានចរិយាត្រឹមត្រូវ, ក្បួនសម្រាប់បង្រៀនឲ្យមានគំនិតមារយាទត្រឹមត្រូវ (Morale) ฯ

ឆន្ទៈ = (ម.ឋ.ឆ័ន.ទ:) ន. គោលបំណង, សេចក្ដីប្រាថ្នាចំពោះវត្ថុអ្វីមួយ (Volonté) ฯ

ចេតនា = ន. គំនិត, គំនិតដែលនាំចិត្តឲ្យផ្ចង់នឹក, ឲ្យផ្ចង់គិត ฯ

អង្គការសហប្រជាជាតិ = ន. អង្គការមួយដែលប្រជាជាតិជាច្រើនក្នុងសាកលលោកបានផ្ដួចផ្ដើម បង្កើតឡើង ដើម្បីការពារ សន្តិភាព សាកល (Organisation des Nations Unies) ฯ

សព្វាវុធ = ន. គ្រឿងអាវុធទូទៅ (Armement) ฯ

បរមាណូ = (ម.ថ.ប៉:-រ:មា៉-ណូ) ន. ធាតុល្អិតក្រៃលែង 8 (Atome) ฯ គ្រាប់បែកបរមាណូ (Bombe atomique) ฯ

សន្និសីទ = ន. ការប្រមប្រជុំដើម្បីថ្លែងការណ៍អ្វីមួយ

(Conférence) ។

គមនាគមន៍ = (ម.ចិ.គ-:ម:-នា.គុំ) ន. ការធ្វើដំណើរកាន់ទ

ទៅវិញទៅមក (Communication) ។

សេរីភាព=ន. ភាពដែលអាចធ្វើទៅបានតាមចិត្ត (liberté)

លក្ខខណ្ឌ=(ម.ចិ.ល័ក.ខ័ន) ន. ការកំណត់ជាគោល, រឿ

សំខាន់ជាគោល (Condition) ។

សនិសស័ព្ទ

ខណ្ឌ-ខន្ធ-ខាន់

ខណ្ឌ =(ម ចិ.ខ័ន) ន (ម.សំ)សង្កាត់, ប៉ែក, កំណត់, ប៉ែកអា

ណាខេត្ត : ខណ្ឌភ្នំពេញ ... ។

ខណ្ឌ =(ម.ចិ.ខ័ន) ន. (ម.សំ) កំរែត, បំពាមផ្ដាច់មិនឲ្យធ្វើ

ទៅបានឥតមានខណ្ឌទេ, ព្រះរាជខណ្ឌ ។

ពាក្យដែលផ្ដើមឡើងពីខណ្ឌគឺ៖

ខណ្ឌស្ករ = ន. ឈ្មោះថ្នាំមួយយ៉ាង ។

ខណ្ឌសីមា = ន. ឈ្មោះពុទ្ធសីមាមួយយ៉ាង ។

ក្ខខណ្ឌ = ( សូមមើលសេចក្ដីពន្យល់ខាងលើ ) ។

ខន្ធ = ( ម ជ.ខ័ន ) ន. (ជាពាក្យបាលី,សំស្ក្រឹតជា ស្កន្ធ ) ក , ដើម,
គំនរ , ពួក , កង, ប្រជុំ , សេចក្ដីកំណត់ ។
ធ្លាយខន្ធគឺស្លាប់ ។

ខាន់ ឬ ខ័ន = ន. ( សំ-ខឌ្គ,ម -ខគ្គ ) គ្រឿងសាស្ត្រាវុធសម្រាប់
រាជ្យ មានមុខទាំងពីរខាង : ព្រះខ័ន ។

ខាន់ទៅ = ន. កំណល់, ស្នើនសម្រាប់គេមើលដម្ងៃ: ស្នើន
ខាន់ទៅ ។

ខាន់ដីប = ន. រំយោលគ្រឿងសេះចុះសំយុងក្រោមចង្កា ។

ខាក់ បៀត = ន. ឈ្មោះរោគមួយ យ៉ាងកើតបៀតបំពង់ក ។

ខាក់ លៀន = ន. ឈ្មោះរោគដែលបណ្ដាលឲ្យសាច់ឡើងលៀន

ខាក់ ស្វា = ន. ប្រាក់ជំនូនមេបាខាងប្រុស យកទៅជូនមេបាខាងស្រី ។

ខាក់ ស្វាក់ = ន. ឈ្មោះរោគមួយ យ៉ាង កើតកណ្ដាលក ។

អត្ថាភិវុទ្ធ

បដិបត្តិឬប្រតិបត្តិ ។ ដម្លោះឬដំលោះ ។ បុរាណ ឬបូរាណ ។ ទូទៅ ឬ ទួទៅ ។ បរមត្ថវិទ្យា ឬ បរមត្ថវិជ្ជា ។ ដម្លៃឬ ដំឡៃ ។ ចម្រើនឬចំរើន ។ កម្លាំង ឬកំឡាំង ។

ចំណាំ

**ប្រតិបត្តិ-ប្រណិប័តន៍**

ចូរកុំច្រឡំពាក្យទាំងពីរនេះ ។

ប្រតិបត្តិ ឬ បដិបត្តិ = ( ម.ថ.ប៉.ដិ.ប័ត.ឬប្រតិប័ត ) ន. ជាពាក្យបាលី

ឬសំស្រឹតមានន័យថា: ការប្រព្រឹត្តិ, កាន់, ធ្វើតាម, ប្រើនិយាយថា សេចក្ដីបដិបត្តិ, ការប្រតិបត្តិ ។ ខ្មែរយើង ប្រើជាកិរិយាស័ព្ទក៏បាន: ត្រូវប្រតិបត្តិតាមច្បាប់ ។

ប្រណិប័តន៍ = ន. (សំ-ប្រណិបតន) ការគំនាប់, ការសំដែងនូវសេចក្ដីគោរព។ ប្រើជាកិរិយាស័ព្ទក៏បាន: សូមក្រាបប្រណិប័តន៍។

## សំណួរ

១- ចូរពន្យល់ពាក្យ: បរមត្ថវិជ្ជា, បរមាណូ, សន្និសិទ, គមនាគមន៍ ។

២- ចូររកសទិសស័ព្ទនៃពាក្យ: ខ័ន ។

៣- ចូរសម្ពន្ធប្រយោគ " តាមគោលការណ៍វិទ្យាសាស្ត្រ នឹងបរិយាសាស្ត្រ មិនមែនមិនចុះសម្រុងគ្នាទេ ។

៤- ចូររកឧត្ដមគតិនៃអត្ថបទនេះ ។

## ជម្លោះប្រឹងមនុស្សបុរាណ នឹងមនុស្សទំនើប (តប...

នៅក្នុងសេដ្ឋកិច្ច ដែលពេលឥឡូវ សឹងក្លាយទៅជារ... សម្រាប់ ដោយលែងមាននៅជាដោយឡែកឯកឯងដូចមុន ហើយ... នៅពេលដែលការអ្វីក៏ដោយ ក៏ត្រូវតែមានដំណើរជាសាកលនៅ... គ្រប់ប្រទេសត្រូវចាត់ការទាក់ទងគ្នាទៅវិញទៅមក ដោយចាំបា... ស្ថាបនាការទាក់ទងរវាងមនុស្ស ព្រមទាំងការផ្ទេរផលិតផលផង... យើងត្រូវបង្រៀន, បង្ហាញនាំឲ្យសប្បាយខ្លះ, ផ្សះផ្សាខ្លះ ៗ ស... ថ្ងៃ យើងកាន់តែត្រូវការច្រើនឡើងៗហើយ នូវបុគ្គលិកជំនាញ...

ក្នុងក្របខ័ណ្ឌ ខាងអ្នករាជការ, ភ្នាក់ងារពាណិជ្ជកម្ម... សាស្ត្រាចារ្យ, គ្រូបង្រៀន, អ្នកនិពន្ធ, អ្នកសារពត៌មាន, សិល្បក... វេជ្ជបណ្ឌិត, គ្រូពេទ្យ, អ្នកប្រជាសង្គ្រោះស្រីៗ ។ល។ ក្រៅអំ... កិច្ចការខាងបច្ចេកទេស គឺការដែលគិតតែពីបង្កើតសម្ភារៈនេ... ការសម្រាប់រៀបចំការទាក់ទងរវាងមនុស្សនឹងមនុស្ស ក៏ត្រូវក... ណាស់ដែរ នូវភ្នាក់ងារជំនាញ និងនាយដែលមានចំណេះវិជ្ជ...

ជ្រៅជ្រះ ។ រីឯការខាងលើនេះ ថ្វីបើមិនមែនជាការបច្ចេកទេសធំស្មោះនោះ ក៏គង់ត្រូវការវិជ្ជាខាងវិទ្យាសាស្ត្រនិងខាងបច្ចេក-ទេស ច្រើនជាជាងខាងអក្សរសាស្ត្រផង ។ នៅក្នុងផ្នែកការជាច្រើន "ពាណិជ្ជកម្ម-រដ្ឋបាល-ធនាគារ-សង្គមកិច្ច" ដែលចំណេះវិជ្ជាទូទៅនិងការពិសោធន៍ផ្ទាល់ខ្លួន អាចនឹងគ្រប់គ្រាន់បានរហូតមកដល់ឥឡូវនេះ ដើម្បីប្រតិបត្តិឬត្រួតត្រានោះ ឥឡូវសឹងមានរបៀបខាងគណិតសាស្ត្រ ឬ ខាងពិសោធន៍-ស្ថិតិ, ការរៀនមើលកិច្ចសន្យា,ការរិះរកតាមលេខសាស្ត្រ,ញាណវិជ្ជាជីវសាស្ត្រ។ល។ ដែលត្រូវការឲ្យអ្នកប្រតិបត្តិ មានអាកប្បកិរិយាដូចគ្នានឹងអាកប្បកិរិយា នៃវិស្វករឬរបស់អ្នករដ្ឋបាលឬអ្នករត់ការធម្មតាដែរ ។

គឺយ៉ាងនេះហើយ បានជាយើងសូមទាមទារ និងសូមឲ្យយុវជនជាន់នេះនិងជាន់ក្រោយ បានប្រកបនូវការអប់រំខាងបច្ចេកទេសឲ្យកាន់តែខ្លាំងឡើង ។

ចៅ-សេង

# ពន្យល់ពាក្យ

សេដ្ឋកិច្ច = ន. មុខរបរដែលមានប្រយោជន៍សំខាន់បំផុតសំរាប់ប្រទេសនិមួយៗ (Economie) ។

ស្ថាបនា = (ម.ជ.ស្ថា.ប៉.ណា) កិ. កសាង, សង់ , ធ្វើ (Construire) ។

ផលិតផល = (ម.ជ.ផល់.លិត.តៈ-ផល់) ន. ផលដែលគេធ្វើឡើងបានសម្រេច (produit) ។ ផលិតកម្ម (Production) ។

បុគ្គលិក = (ម.ជ.បុក.គៈ-លិក) ន. អ្នកធ្វើការ, មនុស្សដែលប្រកបកិច្ចការ (Personnel) ។

ក្របខ័ណ្ឌ = ន. វង្វង់ច្បាប់អ្វីមួយ (Cadre) ។

ពាណិជ្ជកម្ម ន. ជំនួញ, របររកស៊ី, កិច្ចការរបស់អ្នកជំនួញ (Commerce) ។

អ្នកស្រាវពត៌មាន = ន. អ្នកនិពន្ធកាសែត (Journaliste) ។

សិល្បករ = (ម.ចំ.សិល.ល្ប៉ៈក) ន. អ្នកចេះវិជ្ជាខាងជាង,

អ្នកស្ដែងតួល្ខោន, អ្នកចេះសិល្បៈ (Artiste) ។

វេជ្ជបណ្ឌិត = (ម.ចំ.វេជ.ជៈ-) ន. អ្នកប្រាជ្ញខាងពេទ្យ, អ្នក

ប្រាជ្ញខាងមើលជម្ងឺ (Docteur) ។

រដ្ឋបាល ន. ការគ្រប់គ្រងប្រទេស, ការត្រួតត្រារដ្ឋ

(Administration) ។

ធនាគារ = ន. មន្ទីរទុកប្រាក់ឬបង្កើតប្រាក់សម្រាប់ចាយវាយ,

ឃ្លាំងប្រាក់ (Banque) ។

សង្គមកិច្ច = ន. អំពើដែលធ្វើឡើង ដើម្បីជាប្រយោជន៍ដល់ជន

រួមជាតិ (Action sociale) ។

ពិសោធន៍ = ន. ការសាកល្បង (Expérience) ។

គណិតសាស្ត្រ = ន. ក្បួនវិជ្ជាខាងលេខ, នព្វន្ធ (Mathématique)

ពិសោធន៍-ស្ថិតិ = ន. វិទ្យាសាស្ត្រខាងប្រមូលផ្ដុំ តាមរបៀបនូវ
កិច្ចតាំងឡាយរបស់សង្គម (Statistique) ។

ញាណវិជ្ជាជីវសាស្ត្រ = វិជ្ជាសម្រាប់ស្ទង់ចិត្តគំនិត (Psycho-logie) ។

វិស្វករ = ន. អ្នកចេះស្ទាត់ជំនាញខាងវិជ្ជាពិសេស គឺវិជ្ជាផ្នែក
ខាងការសំណង់ផ្សេងៗ (Ingénieur) ។

វេវចនស័ព្ទ

បុគ្គលិក - ភ្នាក់ងារ ។

ផ្សះផ្សា - សម្រុះសម្រួល ។

សទិសស័ព្ទ

**ផ្សា - ផ្សារ - ផ្សះ ផ្សា**

ផ្សា = កិ.ប្ដុ. - ឈឺចាប់តឹតពេលពលផ្សៀបៗដោយមុខសស្ត្រ,

របួស, ដាច់, រលាត់, ប៉ះពាល់ត្រូវ, ប្រទះនឹងជាតិជូរ, ប្រៃ, ហឹរ ... ។ ផ្សាខ្លោច ឬ ខ្លោចផ្សា ។

ផ្សារ=ន. ទីប្រជុំលក់ដូររបស់ផ្សេងៗ: ផ្សារធំថ្មី, ផ្សារស្ទួង, ផ្សារហ៊ានហោច ... ។

ផ្សារ=កិ. ភ្ជាប់ដោយទឹកបន្ទា: ផ្សារឆ្នាំង, ផ្សារដិល ។

ផ្សះផ្សា = កិ. ធ្វើឲ្យជាគ្នាវិញ: ផ្សះផ្សាប្ដីប្រពន្ធដែលលែងគ្នា ។

## អក្ខរាវិរុទ្ធ

សកល ឬ សាកល ។

អាកប្បកិរិយា សរសេរបានតែមួយយ៉ាង កុំសរសេរជា "អកប្ប-កិរិយា" យ៉ាងនេះឲ្យសោះ ។

# ព្យញ្ជនៈ " ឋ "

កុំពាក្យខ្មែរសុទ្ធ ព្យញ្ជនៈ " ឋ " ឥតមាននៅពីក្រោមព្យញ្ជនៈឯទៀតទេ មានតែកុំពាក្យបាលីនិងសំស្ក្រឹត ។

កុំពាក្យពីរព្យាង្គ ព្យញ្ជនៈ " ឋ " នៅក្រោមព្យញ្ជនៈ " ន ,, ដូចពាក្យ : បន្ទយ,បន្ថែម ។ល។ ...

បំណាំ– " ឋ " ដាក់ជើង " អ " ( ឋ្អ ) គ្មានប្រើទេ ។ មានតែ " ធ " ដាក់ជើង " អ " ( ធ្អ ) ។

ហេតុនេះត្រូវជៀសវៀងកុំសរសេរ " ឋ្អញ្ឋ្អ,, បែបនេះឲ្យសោះ ។ ត្រូវសរសេរជា " ធ្អញ្ធ្អ " ។

ចំណាំ

# ពិសោធន៍-ពិសោធ

ពាក្យទាំងពីរនេះជាសន្ទានពាក្យ តែមួយជានាមសព្ទ, មួយជាកិរិយាសព្ទ ហេតុនេះទើបសរសេរខុសគ្នា ។

ពិសោធន៍ = ជានាមស័ព្ទមានន័យថា: ការសាកល្បង, ដំណើរ

ពិនិត្យឬសាកមើលឲ្យឃើញពិត: នៅក្នុងពិសោធន៍,

ជាប់ពិសោធន៍... ។

ពិសោធ = ជាកិរិយាស័ព្ទមានន័យថា: សាកល្បង, ពិនិត្យឬសាក

មើលឲ្យឃើញពិត: អ្នកវិទ្យាសាស្ត្រ ពិសោធ គ្រឿង

ប្រដាប់របស់ខ្លួន ។

សរសេរជា ពិសោធ ក៏មាន ។

## សម្បត្តិ-សម្បាប់

ចូរកុំប្រឡំពាក្យទាំងពីរនេះ ។

សម្បត្តិ = ជាពាក្យបាលីនឹងសំស្ក្រឹត,នាមស័ព្ទ,មានន័យថា សេចក្ដី

សម្រេច,ការសមប្រកប,សេចក្ដីសុខ,លំអ,ទ្រព្យ,ធនធាន

ពាក្យនេះខ្មែរប្រើសំដៅទៅលើ ទ្រព្យធន: ទ្រព្យសម្បត្តិ ។

សម្បាប់ ឬ សំបាប់ = (សំស្ក្រឹតជាសម្បាច) ន. ទ្រព្យកេរ្តិ៍, របស់ជាដំណែល, មរតក ។ បុត្រធិតាទទួល សម្បាប់របស់មាតាបិតា ។

## សំណួរ

១–ចូរពន្យល់ពាក្យ: ស្ថាបនា, ផលិតផល, វេជ្ជបណ្ឌិត, ធនាគារ, សង្គមកិច្ច ។

២–ចូររកវេវចនស័ព្ទនៃពាក្យ: វេជ្ជបណ្ឌិត ។

៣–ចូររកសទិសស័ព្ទនៃពាក្យ: ផ្សា ។

៤–ចូរសម្ពន្ធប្រយោគទី៣នៃអត្ថបទនេះ ។

៥–អ្នកមានយោបល់យ៉ាងណាចំពោះអត្ថបទខាងលើនេះ ។

# ឥទ្ធិពលនៃវិទ្យាសាស្ត្រ

កាប់រយសតវត្សរ៍មកហើយ ដែលមនុស្សយើងភាគច្រើន បានផ្ញើជាគរសនាទៅនឹងអាទិទេព ដោយបាននាំគ្នាអុចធូបបន់ស្រន់សុំឲ្យបានហោះហើរទៅកាន់ពិភពចក្រវាល សុំឲ្យបានធ្វើដំណើរពីនគរមួយ ទៅនគរមួយដោយមន្តវិជ្ជាការ, សុំឲ្យបានស្ដាប់សំឡេងដូរ្យតន្ត្រីនៅស្ថានលើដោយការស្រមៃ ។ ល ។... ប៉ុន្តែកាប់រយសតវត្សរ៍កន្លងទៅ មនុស្សនៅតែនៅលើដីដដែល សេចក្ដីប៉ុនប៉ងរបស់គេ ក៏នៅតែជាការយល់សប្តិដែលគ្មានផលសក្ដិសិទ្ធិអ្វីសោះ ។

ផ្ទុយទៅវិញ ពួកអ្នកប្រាជ្ញវិទ្យាសាស្ត្រ ដែលពុំព្រមផ្ញើជាគរសនាទៅនឹងការផ្សងព្រេងឥតសមហេតុផលនេះ ក៏បាននាំគ្នាស្រាវជ្រាវរកវិទ្យាសាស្ត្រ ដើម្បីបង្កើតជាអច្ឆរិយវត្ថុផ្សេង ៗ លុះត្រាតែបានសំរេច ហើយដែលមនុស្សលោកភាគខ្លះ សឹងតែមិនព្រមជឿថាជាស្នាដៃរបស់មនុស្សសាមញ្ញផង ។ គេបង្កើតបានជា

រថយន្ត , រថភ្លើង , សំរាប់ធ្វើគមនាគមន៍កាន់គ្នា ទៅវិញទៅមក , បង្កើតជាអាកាសយាន , យន្តហោះប្រតិកម្ម , ឧទ្ធម្ភាគចក្រ ... ដើម្បីហោះហើរលើអាកាសបានយ៉ាងទាន់ចិត្ត ។ គេបង្កើតបានជាទូរលេខ ទូរសព្ទដើម្បីនិយាយឆ្លើយឆ្លងគ្នា ឬ ទាក់ទងគ្នាទៅវិញទៅមកបានគ្រប់ពេលភ្លាមៗ ។ គេបង្កើតបានជាវិទ្យុសម្រាប់ចាប់យករលកសំឡេងផ្សព្វផ្សាយ, វិទ្យុទូរទស្សន៍ សម្រាប់ចាប់យករូបភាពផ្សេង ៗ មានរបាំ ភាពយន្តជាដើមបានយ៉ាងជាក់ស្តែង ។ល។ ហើយគ្រប់ពេលថ្មី ៗ នេះសហភាពសូវៀត បានទាំងបញ្ជូនអ្នកចក្រវាលគោចរ ទៅកាន់ពិភពចក្រវាលបានដោយសុវត្ថិភាពទៀតផង ។

ហ្នឹងហើយឥទ្ធិពលនៃវិទ្យាសាស្ត្រ ។ ប៉ុន្តែវិទ្យាសាស្ត្ររមែងមានឥទ្ធិពលខុសគ្នា តាមការប្រើប្រាស់របស់មនុស្ស ។ ពួកចក្រពត្តិយកវិទ្យាសាស្ត្រមកធ្វើជាសស្ត្រាវុធ ប្រហារជីវិតមនុស្សលោក ដូចជាបង្កើតអាវុធស្វ័យប្រវត្ត គ្រាប់បែកបរមាណូជាដើម

ហើយអ្នកខ្លះទៀតបានយកវិទ្យាសាស្ត្រមកប្រើប្រាស់ ដើម្បីជាគុណប្រយោជន៍របស់មនុស្សជាតិទូទៅ ។

ពន្យល់ពាក្យ

ឥទ្ធិពល = (ម ថ.អិត.ធិ.ពល់) ន. កម្លាំង, អំណាច ។

សតវត្ស ឬ សតវត្សរ៍ = ន. ពេលកំណត់ ១០០ ឆ្នាំ (Siècle) ។

ជោគវាសនា = ន. ព្រេងសំណាង, ភ័ព្វព្រេង, បុណ្យភ័ព្វ ។

អាទិទេព = ន. ឈ្មោះទេវតាជាធំដែលបង្កើតលោក (Dieu) ។

ចក្រវាល ឬ ចក្កវាឡ = ន. ខ្សែគំនូសនៃពិភពលោកត្រង់ទីគោ-ចរនៃព្រះអាទិត្យ ។

អ្នកចក្រវាលគោចរ = ន. អ្នកធ្វើដំណើរ ក្នុងចក្រវាល (Cosmosnaute) ។ លោកហ្គាហ្គារីន នៃសហភាពសូវៀតជាអ្នកចក្រវាលគោចរទី ១ ។ 9

បក្តិសិទ្ធិ = គុ. ពូកែពុតឆាប់, ជាក់ស្ដែង ។

អច្ឆរិយវត្ថុ = (ម.ច.អ័ច.ឆៈ.រិ.យៈ-) ន. (អច្ឆរិយ = អស្ចារ្យ + វត្ថុ)

ន របស់ដ៏អស្ចារ្យ, របស់ប្លែកដែលពុំដែល

មានជាធម្មតា (Chose merveilleuse) ។

មនុស្សសាមញ្ញ = មនុស្សធម្មតា គឺ មិនមែនជាទេវតា ឬ ជា

មនុស្សនៅស្ថានដទៃក្រៅពីផែនដីយើងនេះ ។

រថយន្ត = ន. រថដែលអាចធ្វើដំណើរបានដោយម៉ាស៊ីន ។ ពាក្យ

សាមញ្ញហៅថា : ឡាន (Automobile) ។

អាកាសយាន = ន. យានដែលធ្វើដំណើរលើអាកាស (Avion) ។

យន្តហោះប្រតិកម្ម ឬ អាកាសយានប្រតិកម្ម = ន. យន្តហោះ

ដែលគ្មានកង្ហារ គឺធ្វើដំណើរដោយកម្លាំង

ខ្លួនហើយដែលអាចធន់ទ្រាំនឹងធាតុអាកាស

បានគ្រប់យ៉ាង (Avion à réaction) ។

ឧទ្ធម្ភាកប្រ = (ម.ច.អុត.ថ័ម.ភាគ ក.ប:-) ន. យន្តហោះដែល

មានកង្ហារនៅពីលើហើយដែលអាចចុះសំចត នៅទីកន្លែងណាក៏បាន (Hélicoptère) ។

គមនាគមន៍ = (ម.ព.គ.ម.នា.គុំ) ន. ការធ្វើដំណើរកាន់គ្នាទៅវិញទៅមក (Communication) ។

ទូរលេខ = ន. លិខិតដែលគេវាយជាលេខ តាមផ្លូវប្រៃសណីយ៍ (Télégramme) ។

ទូរស័ព្ទ = ន. ប្រដាប់សម្រាប់និយាយទាក់ទងគ្នាទៅវិញទៅមក ពីចម្ងាយ គឺនិយាយតាមខ្សែ (Téléphone) ។

វិទ្យុ = ន. ប្រដាប់សម្រាប់ចាប់យកសម្លេង ដែលគេផ្សាយតាម ប៉ុស្តិ៍និមួយៗ (Radio) ។

វិទ្យុទូរទស្សន៍ = (ម.ព.វិទ្យុ-ទូរទស់) ន. ប្រដាប់សំរាប់ចាប់យក រូបភាពផ្សេងៗ ដែលគេស្ដែងតាមប៉ុស្តិណា មួយ (Radiotélévision) ។

ភាពយន្ត = ន. គ្រឿងប្រដាប់សម្រាប់បញ្ចាំងរូបភាពផ្សេង ៗ ជាស្រមោល (Cinéma) ពាក្យសាមញ្ញហៅថា កុន ។

សុវត្ថិភាព = (ម.ថិ.សុ វ័ត ថិ.ភាព) ន. ការប្រកបដោយសេចក្ដីសុខ, ការប្រព្រឹត្តទៅបានសំរេច តាមគោលបំណង, ការប្រកបដោយជោគជ័យ ។

ស្វយប្រវត្ត = គុ. ដែលប្រព្រឹត្តទៅដោយខ្លួនឯង (Automatique) ។ អាវុធស្វ័យប្រវត្ត (Armes automatiques) ។

សស្ត្រាវុធ = ន. គ្រឿងអាវុធផ្សេង ៗ (Armements) ។ សរសេរជា សស្ត្រាយុធ ក៏បាន

សទិសស័ព្ទ

**សប់-សត-សត្វ-យល់សប្ត**

សប់ = (ជាពាក្យខ្មែរសុទ្ធ) កិ. ស្រូបខ្យល់ដោយស្នប់ = សប់កាដ់, សប់ចង្ក្រាន ... ។

សព=(ម.ធ.សប់) (សំ-ឝវ, វ > ព=ឝព, ម ឆវ, ខ្មែរប្រើផ្លាស់ ឆ ជា ស វ ជា ព > សព) ជានាមស័ព្ទ មានន័យថា ខ្មោចស្រស់, រូបបុគ្គលស្លាប់, សាកខ្មោច : ដំកល់សព, រំលាយ សព, បូជា សព ... ។

សព្ទ=(ម.ធ.សប់) (ជាពាក្យបាលី, សំស្ក្រឹតជា សព្ទ) គុ.ឬ.កិ.វិ.ទាំងពួង, ទាំងអស់, ទាំងមូល, ទាំងស្រង់, ទាំងគ្រប់, ខ្ទូទៅ = សព្វជង, សព្វគ្រា, សព្វប្រការ, ដឹងសព្វ, ចេះសព្វ ... ។

សព្វ=(ម.ធ.សប់.ពះ) វិ.ស.ឬ.គុ. ទាំងពួង, ទាំងអស់, ទាំងមូល ។

ពាក្យដែលផ្ដើមឡើងពី សព្វ គឺ : សព្វគុណ, សព្វញ្ញូ, សព្វញ្ញុតញ្ញាណ, សព្វវិបតាធិប្បាយ ។ល។

ចល់ សប្ត ឬ សប្ដិ = ន. ការដេកលក់ឃើញការម្មណ៍ផ្សេងៗ ។

## ស័ប្ត-សប្ប-ស័ទ្ទ-សត្ថ-សាប់

*ពាក្យទាំងនេះមិនមែនអានថា "សប់" ដូច*

*ពាក្យទាំងប៉ុន្មានខាងលើទេ គឺត្រូវអានថា*

*"សាប់" ឬ "ស័ប-ប:"* ។

សប្ត ឬ ស័ប្ត (ម.ច.ស័ប.ប្ត:ឬស័ប) ន. *ប្រាំពីរ (៧)=សប្តស័ក,*

*សប្តាហ៍ ...* ។

សប្ប = (ម.ច.ស័ប.ប៉ះ) ជាពាក្យបាលី, សំស្ក្រឹតជា *សប៌* ន. *ពស់* ។

*សប្បជាតិ = ជាតិពស់, ពស់គ្រប់យ៉ាង* ។

ពាក្យដែលថ្ពែមឡើងពី សប្ប គឺ: សប្បជិភ័យ,

សប្បជិភាព, សប្បធំ ។

សទ្ទ ឬ ស័ទ្ទ =(ម.ច.ស័ប) ន. *(សំ - គទ្ទ; ម - សទ្ទ) សូរ, សំឡេង,*

*សំនៀង, ភាសា, ពាក្យ, សំដី, សម្រែក* ។

សព្ភិ = (ម.ថ.សប់ភិ-ឬសប់) អា.និ. ដោយសប្បុរសទាំងឡាយ, ជាមួយនឹងពួកសប្បុរស ។

សាប់ = កិ. (ជាពាក្យខ្មែរសុទ្ធ) កាប់ចិញ្ច្រាំស្រាលៗញាប់ៗឲ្យដាច់ ជាចំណិតតូចៗស្ដើងៗ: សាប់ខិំពាំង, សាប់ផ្លែល្ហុង ។ អុំទូកញាប់ៗ: សាប់ច្រវាព្រមគ្នា ។

## អក្ខរាវិរុទ្ធ

សតវត្ស ឬ សតវត្សរ៍ ។ ភាស្នា ឬ ភាសា ។

បក្កាឡ ឬ បក្រាល ។ សម្រេច ឬ សំរេច ។

យល់សប្ដ ឬ យល់សប្ដិ ឬ យល់សប្ន ។

ដូរិយតន្ត្រី ឬ ដូរ្យតន្ត្រី ឬ តូយ៌តន្ត្រី ឬ តូរ្យតន្ត្រី ។

## ចំណាំ

**សស្ត្រា-សាស្ត្រា**

ពាក្យទាំងពីរនេះ មានសូរស័ព្ទសម្លេងប្រហែលគ្នា ប៉ុន្តែមានន័យខុសគ្នា ។

សស្ត្រឬសស្ត្រា = ន. គ្រឿងប្រដាប់ធ្វើដោយដែកមានមុខមុត ដូចជាកាំបិត, ដាវ, លំពែងជាដើម ។

សាស្ត្រា = ន. គម្ពីរ, ក្បួន, ច្បាប់ ដែលចារនៅលើស្លឹករឹត = សាស្ត្រាល្បែង, សាស្ត្រាទេសន៍... ។

ពាក្យនេះខ្មែរប្រើក្លាយទៅជា សាត្រា ។

## សំណួរ

១- ចូរពន្យល់ពាក្យ: អច្ឆរិយវត្ថុ, ទុទ្ធាកបត្រ, ទូរទស្សន៍, ស្វ័យប្រវត្តិ ។

២- ចូររកវេវចនស័ព្ទនៃពាក្យ: យល់សប្តិ ។

៣ ចូររកសទិសស័ព្ទនៃពាក្យ:សប់ទឹងសាប់ ។

៤- ចូរសម្ពន្ធពាក្យ: វិទ្យាសាស្ត្រ ( ប៉ុន្តែវិទ្យាសាស្ត្រមែងមានឥទ្ធិពលខុសគ្នា ) ។

៥ -តើអ្នកនិពន្ធអត្ថបទនេះ មានឧត្តមគតិដូចម្តេច ?

## ជោគជ័យថ្មីនៃមនុស្សជាតិ

ដំណឹងនៃជោគជ័យ ក្នុងការបង្ហោះនាវាចក្រវាលរបស់រុស្ស៊ី បានធ្វើឲ្យមហាជន នឹងរដ្ឋបរទេសទូទៅទាំងសាកលលោកអបអរ កោតសរសើរនឹងជូនពរជាកិយោគាព ៗ លោកប្រធានាធិបតីនៃសហរដ្ឋអាមេរិកបានផ្ញើសារមុនគេដល់លោកនាយក គ្រុស្ចេហ្វ ៗ

គួរឲ្យកោតសរសើរមែន ព្រោះចក្រវាលនេះជាតំបន់មួយក្នុងពិភពលោកដែលគ្មាននរណាអាចទៅដល់ឡើយ ៗ ហើយមនុស្សលោកចាប់តាំងពីចាប់បដិសន្ធិមានជីវិតមក ក៏បានប៉ងប្រាថ្នាថា ធ្វើដូចម្តេចឲ្យទៅដល់ទាល់តែបាន ៗ តាំងពីនោះមកដល់ពេលបច្ចុប្បន្ននេះ រាប់រយសតវត្សបានកន្លងទៅហើយ តែសេចក្តីប៉ងប្រាថ្នានេះ នៅតែជាការយល់សប្តិតកោះត្រើយដដែល ៗ ឥឡូវសូវៀតបានបើកឆាកមុនគេ ហើយក៏ដូចតែសូវៀត បានបើកឆាកមុនគេអញ្ចឹងដែរខាងបង្ហោះស្ពុតនិក ខាង

បង្ហោះផ្កាយវិទ្យាសាស្ត្រឲ្យវិលជុំវិញព្រះអាទិត្យ ខាងថតរូបព្រះចន្ទ ខាងបង្ហោះស្ថានីយវិទ្យាសាស្ត្រឲ្យទៅរកព្រះសុក្រ ... ។

ជ័យជំនះរបស់វិទ្យាសាស្ត្រសូវៀតលើកនេះ បានផ្តល់នូវគុណប្រយោជន៍ជាអនេកប្បការឲ្យដល់មនុស្សជាតិទូទៅ ។ ក្រៅពីគុណប្រយោជន៍ខាងវិទ្យាសាស្ត្រសុទ្ធ ៗ ជ័យជំនះនេះនៅដាប់សតិអារម្មណ៍របស់ជនសាមញ្ញឲ្យឃើញទៀតថា សូវៀតជាមហាអំណាចមួយធំផ្ដាច់លើសកលលោក រីឯឥទ្ធិឫទ្ធិនេះមិនមែនបានមកដោយចៃដន្យឡើយ គឺពិតជាបានមកដោយសាររបបគ្រប់គ្រងសង្គមនិយមនិងលទ្ធិសង្គមនិយម (វិទ្យាសាស្ត្រ) ផ្ដល់ឲ្យ ។ មាគ៌ានេះជាមាគ៌ាឯកបំភ្លឺផ្លូវឲ្យប្រជាជាតិឯទៀត ៗ សញ្ជឹងនឹងថ្លឹងបានដោយសត្យានុម័តិ ។ ម្យ៉ាងទៀតជ័យជំនះនេះ បានបំរើបុព្វហេតុសន្តិភាពដោយពិតប្រាកដ ។

## ពាក្យលំបាក

ជោគជ័យ = ន. ជ័យជំនះដ៏សំបើមអស្ចារ្យ, ជ័យជំនះដែលបាន សម្រេចយ៉ាងជាក់ស្ដែង ។

មនុស្សជាតិ = ក្នុងអត្ថបទនេះគឺ មនុស្សទូទៅលើពិភពលោក ។

នាវាចក្រវាល = ន. ឈ្មោះនាវា (កាំជ្រួច) របស់សហភាពសូវៀត ដែលបានធ្វើដំណើរក្នុងចក្រវាល (Vostok) ។

រដ្ឋបុរស = អ្នកកាន់កាប់ការធំៗ របស់ប្រទេស, អ្នកមានឈ្មោះល្បីក្នុងការបំរើប្រទេសជាតិ (Homme d'Etat) ។

ភិយ្យោភាព = ន. ដំណើរច្រើនក្រៃលែង, ការៈលើសលែង ។

ប្រធានាធិបតី = ន. អ្នកដែលជាប្រមុខលើប្រទេសនិមួយៗ (សម្រាប់ប្រទេសសាធារណរដ្ឋ ដែលគ្មានស្ដេចគ្រងរាជ្យ) ។ ឧ. លោកលីវ-ចាវ-ជី ជាប្រធានាធិបតីនៃប្រទេសចិនប្រជាមានិត ។

បដិសន្ធិ = ន. ដំណកំណើតសត្វ, ការចាប់កំណើតនៃមនុស្ស, សត្វ ។

ព្រះសុក្រ = ន. ឈ្មោះផ្កាយទី ៦ ។

ស្ថានីយ = ន. ដំណាក់, ទីសំចត ។

គុណប្រយោជន៍ = ន. ប្រយោជន៍ដែលជាគុណ គឺប្រយោជន៍ដ៏ល្អវិសេសសម្រាប់មនុស្ស ។

អនេកប្បការ = គុ. ដែលមានប្រការច្រើន, ដែលច្រើនក្រៃពេកពុំអាចនឹងពណនាបាន ។

ឥទ្ធិឫទ្ធិ = ( ឥទ្ធិ ជាពាក្យបាលី; សំស្ក្រឹត ឫទ្ធិ ) ខ្មែរយើងច្រើនប្រើទាំងពីរនេះតែម្តង អានុភាព,អំណាច,សេចក្តីសម្រេច ។

បៃដិក្ស = ន. ការដែលបានមកដោយឯង ១ គឺបានមកដោយឥតបានធ្វើឬឥតបានបម្រុងទុក ។

លទ្ធិសង្គមនិយម = លទ្ធិដែលផ្តុយនឹងលទ្ធិបក្រពត្តិនិយម ។

គឺលទ្ធិប្រសើរដែលគ្មានការ រំលោភជិះជាន់ មនុស្ស, គ្មានរឿងអ្នកធំមើលងាយអ្នកតូច, គ្មានរឿងនាយទុនជិះជាន់កម្មករ ... ។ ក្នុងប្រទេសដែលកាន់លទ្ធិសង្គមនិយម ពលរដ្ឋទូទៅត្រូវរស់នៅដោយស្មើមុខ (Socialisme) ។

សត្យានុម័តិ ឬ សច្ចានុម័តិ = ន. ការយល់ស្របឥតល្អៀង, ការសំដែងសេចក្ដីយល់ព្រមដោយស្មោះ ។

បុព្វហេតុ = ន. ហេតុដែលកើតឡើងមុនគេ, ហេតុដើម (Cause) ។

## វេវចនស័ព្ទ

ព្រះចន្ទ-និសាករ-ប្រភាករ ។

ដំណឹង-ពត៌មាន-រឿងរ៉ាវ ។

## សទិសស័ព្ទ

### ព - ពរ - ព័រ

ព = (ជាពាក្យខ្មែរសុទ្ធ) កិ. លើកដាក់លើចង្កេះកៀកនៅដៃឈរ

ប្រដើរ : ពប្អូន, ពក្មេង, បីព ៗ

ពរ = ន. (សំ;ប. វរ) គុណជាតដ៏ប្រសើរ : សូមពរ, ឲ្យពរ,

ឲ្យពរសព្វសាធុការ...ៗ

ពរ = កិ. លាបបូកដោយជ័រឲ្យក្រាស់ជិតសាច់ពុំឲ្យទឹកជ្រាបចូល

បាន : បិទពរ, ពរទូក...ៗ

ព័រ = ន. ឈ្មោះមនុស្សមួយពួក : ជាតិព័រ, ពួកព័រ ៗ

### គណ-គន់-គន្ធ-គុណ-គុន

គណ = (ម.ថ.គន់) (ជាពាក្យបាលីនិងសំស្ក្រឹត) ពួក, ក្រុម; ជន ៗ

មេគណ គឺមេក្រុមនីមួយ ៗ ៗ

គន់ = កិ. (ជាពាក្យខ្មែរសុទ្ធ) រកមើល ។ ពាក្យនេះ កម្រប្រើជាប់តែឯង ណាស់ប្រើនិយាយថា: គយគន់; គន់មើល ។

គន់គូរ = កិ. ពិចារណាដោយក្បួនវេទ (ក្បួនហោរ): ហោរា គយគន់ ។

គន្ធ = (ម ប.គធ់.ធ:) ន. ជាពាក្យបាលីនិងសំស្ក្រឹត, មានន័យថា ក្លិន; គ្រឿងក្រអូប (សម្រាប់ប្រើក្នុងកំណាព្យ) ។

ពាក្យដែលផ្តើមឡើងពី គន្ធ គឺ: គន្ធជាតិ, គន្ធរស, គន្ធពិដោរ ... ។

គុណ = ន. ប្ក ស៊ុ. ជាពាក្យបាលីនិងសំស្ក្រឹត ដំណើរធ្វើឲ្យចំរើន កើនឡើង: គុណ ១០ ជា ២០; លេខគុណ ។

គុណ = ន. (ជាពាក្យបាលីនិងសំស្ក្រឹត) សេចក្តីចំរើន, ថ្នាក់, ជាន់, លក្ខណ:, ចំណែក; សភាព, បែបបទ ... ។

គុណ = ន. (ជាពាក្យបាលីនិងសំស្ក្រឹត) សភាវធម៌ដែលចំរើនឡើង ដោយលក្ខណ:របស់ខ្លួន គួរគេបស្ទឹងខានពុំ

បាន : គុណមាតាបិតា, គុណគ្រូ, អ្នកមានគុណ ... ។ ពាក្យដែលផ្ដើមឡើងពី គុណ គឺ៖ គុណជាតិ, គុណធម៌ គុណសម្បត្តិ; គុណវុឌ្ឍិ ។

គុន = *ន.* (ជាពាក្យខ្មែរសុទ្ធ) *ឈ្មោះសិល្បខាងគ្រឿងអាវុធសម្រាប់ចូលប្រឡុកលោតហក់ប្រយុទ្ធផ្ទាល់ខ្លួន :* គុនដាវ, គុនដំបង, គុនខែល ... ។

អក្ខរាវិរុទ្ធ

*ដំបន់ ឬ តំបន់ ។ ព្រះចន្ទ ឬ ព្រះច័ន្ទ ។ ឋានីយ ឬ ស្ថានីយ ។ សត្យានុម័តិ ឬ សច្ចានុម័តិ ។ ចៃដន់ ឬ ចៃដន្យ ។*

ចំណាំ

**គន្ធជាត - គុណជាត**

*ពាក្យទាំងពីរនេះមានសូរស័ព្ទសម្លេងប្រហែលគ្នា តែមានន័យខុសគ្នាស្រឡះ ។*

គន្ធជាត = ន. ក្លិន, គ្រឿងក្រអូប (សូមមើលសេចក្ដីអធិប្បាយ ដ៏ពិស្ដារខាងលើ ។

គុណជាតឬគុណជាតិ =(ម. ថ. គុណ·ជាត) ន. ជាពាក្យបាលីនិង សំស្ក្រឹត គឺ គុណគ្រប់យ៉ាង ។

## សំណួរ

១ – ចូរពន្យល់ពាក្យ : នាវាចក្រវាល, កំហ្យោភាព, លទ្ធិ សង្គមនិយម, សត្យានុម័ត ។

២ – ចូររកវេវចនស័ព្ទនៃពាក្យ = ព្រះអាទិត្យ ។

៣ – ចូររកពាក្យផ្ទុយនឹងពាក្យ = មនុស្សធម៌ ។

៤ – ចូររកសទិសស័ព្ទនៃពាក្យ = គុន ។

៥ – តើការបង្ហោះនាវាចក្រវាល របស់សូវៀត បានផ្ដល់-គុណប្រយោជន៍យ៉ាងណាខ្លះដល់មនុស្សជាតិ ?

# មហាវិទ្យាល័យឡូម៉ូណូសូវ

មហាវិទ្យាល័យឡូម៉ូណូសូវ ឈរសម្ងឹងនៅចំពីមុខយើង ដោយមានកំពូលស្រួចបះឡើងបន្ទុំទៅនឹងពពក ។ យើងបានដើរមកកាន់វិទ្យាល័យ កាត់តាមវិថីស្អាតមួយដែលនៅ អមសួនផ្កា ប្រកបដោយរុក្ខជាតិ និងបុប្ផាគ្រប់យ៉ាងព្រមទាំង ស្រះមួយ ដែលឧប្បត្តិកឡើងព្រមមួយអន្លើដោយ ស៊ីកនឹងផ្កាឈូករបនា ហាក់ដូចជាផ្កាឈូកធម្មជាតិ ។ នៅខាងមុខជិតមហាវិទ្យាល័យ រូបបដិមាករនៃលោកឡូម៉ូណូសូវ ដែលជាស្ថាបនិកមហាវិទ្យាល័យនេះបានឈរសម្ងឹងយ៉ាងញញឹមទៅរកក្រុងមូស្គូ ។

មហាវិទ្យាល័យនេះមានដប់ពីរវិជ្ជាស្ថាន, មួយពាន់ទីពិសោធន៍; សាស្ត្រាចារ្យយ៉ាងចំណាន ៗ និងអ្នកប្រាជ្ញជួយធ្វើសហប្រតិបត្តិការមានចំនួនជាងពីរពាន់នាក់, និស្សិតដែលចូលរៀនមានចំនួនដប់ប្រាំមួយពាន់នាក់ ហើយមានបន្ទប់សម្រាប់ជា សយនដ្ឋានរបស់និស្សិត ដែលមកពីបរទេសចំនួនប្រាំមួយពាន់បន្ទប់ ។

ចំណែកបន្ទប់ទាំងអស់ដែលមានក្នុងមហាវិទ្យាល័យនេះ គេ បានប្រៀបឲ្យយើងស្តាប់ថា បើយើងមានអាយុមួយរយឆ្នាំ ហើយចាប់តាំងពីកំណើតមក យើងដេកក្នុងមួយថ្ងៃមួយបន្ទប់នោះ យើងត្រូវដេកនៅឲ្យបានចប់ក្នុងគំរប់មួយរយឆ្នាំ ។

មហាវិទ្យាល័យឡូម៉ូណូសូវ ខ្ពស់ស្កឹមស្កៃណាស់ជា វិថ្ងន្នគ្រឹះដែលមានរហូតដល់ទៅសាបសិបមួយជាន់ ។

ហ៊ា - ឆិម

## ពន្យល់ពាក្យ

មហាវិទ្យាល័យ = សាលាជាន់ខ្ពស់ គឺខ្ពស់ជាងវិទ្យាល័យទៅទៀត ( Université ) ។

ឧប្បត្តិក =( ម.ថ អ៊ុម.ប៉ះផិកឬផឹក )ន. (ជាពាក្យបាលីនឹងសំស្ក្រឹតលាយគ្នា) (ម. ឧប្បត្តិ, សំ ឧត្បត្តិ) ការកើត, ការកើតឡើង, ការចាប់ជាតិ, ការចាប់កំណើត ។

រចនា =( ម.ថ.រៈចៈនា ) ន.ការតាក់តែង, ការធ្វើឲ្យវិចិត្រផ្សេងៗ ។

( ពាក្យនេះខ្មែរយើងនិយមប្រើ ជាកិរិយាស័ព្ទក៏បាន ) ។

បដិមាករ = ន. រូបប្រៀប, រូបសំណាក, រូបដំណាងគឺរូបដែល
គេធ្វើឡើងដើម្បីទុកជាដំណាងបុគ្គលណាមួយ
(Statue) ។ ប្រើជា បដិមា ក៏បាន ។

ស្ថាបនិក = ន. អ្នកសង់, អ្នកតាក់តែង, អ្នកផ្ដើមគំនិតស
(Constructeur) ។

វិជ្ជាស្ថាន ឬ វិជ្ជាឋាន = ន. ទីសម្រាប់រៀន, កន្លែងសិក្សា
(Institut) ។

ទីពិសោធន៍ = កន្លែងឬបន្ទប់សម្រាប់ធ្វើការសាកល្បងវត្ថុផ្សេងៗ
(Salle d'expérience) ។

សាស្ត្រាចារ្យ = ន. គ្រូបង្រៀននៅមធ្យមសិក្សា គឺបង្រៀន
នៅវិទ្យាល័យឬអនុវិទ្យាល័យ (Professeur) ។

សហប្រតិបត្តិការ = ន. កិច្ចការដែលត្រូវធ្វើរួមគ្នា, ប្រតិបត្តិ
ការរួមគ្នា (Coopération) ។

និស្សិត = ន. សិស្សនៃមហាវិទ្យាល័យ ( Etudiant ) ។

សយនដ្ឋាន = (ម.ថ.សៈយៈនៈឋាន) ន. កន្លែងសម្រាប់ដេក ( Dortoir ) ។

វិប្ពន្ធគ្រឹះ = (ម.ថ.វិប.ព័ន.ធៈ –) ន. ផ្ទះមានជាន់ថ្នាក់ច្រើន, ផ្ទះច្រើនជាន់ (Etage) ។

វេវចនស័ព្ទ

វិថី- ផ្លូវ - មាគ៌ា ។

ទីក្រុង-ធានី-រាជធានី-ទីប្រជុំជន ។

សទិសស័ព្ទ

ព័ន្ធ = ( ម.ថ.ពាន់ ) ( សំ.មៈ ព័ន្ធ ) កិ. ចង, ជាប់, ជំពាក់, ភ្ជាក់

ប្រពាក់គ្នា = ពាក់ព័ន្ធ, ព័ន្ធដំណើរ, ព័ន្ធសំដី ។

ពាន់ = ចំនួន ១០០ដប់ដង : មួយពាន់រៀល, ពីរពាន់ ។

# រាង - រៀង

រាង = ន. ស្រែគ្មានដំបូលសម្រាប់ដាក់អ័កន់លក់ជាដើម=រានបន្លែ, រានលក់ត្រី ... ។

រាង = កិ. កាប់គាស់រំពោះទីដីឲ្យកើតបានជាស្រែ, ចំការ, ភូមិ

លំនៅ: រានស្រែ, រានភូមិ ... ។

ជំនះបួលឲ្យបានទៅមុនៈរានទី . . ។

រៀង = កិ. សិក្សា, ខំសង្កេតឲ្យចេះ; ទទួលយកចំណេះ: រៀនសូត្រ, រៀនអក្សរ, រៀនធ្វើការ ... ។

អក្ខរាវិរុទ្ធ

សម្ងឹងឬសំឡឹង ។ បដិមាឬបដិមាករ ។

វិជ្ជាឋានឬវិជ្ជាស្ថាន ។ សម្រាប់ឬសំរាប់ ។

គម្រប់ឬគំរប់ ។ ធម្មជាតឬធម្មជាតិ ។

ចំណាំ

## សយនដ្ឋាន-អាសយដ្ឋាន

ពាក្យទាំងនេះអាចឲ្យយើងប្រើប្រឡំគ្នាជាញឹកញយ ៗ ហេតុនេះចូរចំណាំដូចតទៅ ៖

សយនដ្ឋាន = ន. ទីសម្រាប់ដេក (Dortoir)

អាសយដ្ឋាន = ន. ទីកន្លែងអាស្រ័យ, កន្លែងនៅ, (Adresse)

## ស្ថាបត្យករ - ស្ថាបនិក

ស្ថាបត្យករ = ន. អ្នកគូរប្លង់ខាងការសំណង់ទូទៅ, អ្នកព្រាងកិច្ចការសំណង់ផ្សេង ៗ (Architecte) ។

ស្ថាបនិក = ន. អ្នកធ្វើ, អ្នកសង់, អ្នកសាង (Constructeur)

## ស្ថាបនកម្ម-ស្ថាបត្យកម្ម

ស្ថាបត្យកម្មឬគិម្មាបនកម្ម = ន. ការព្រាងសំណង់, កិច្ចការ

ខាងគូរប្លង់ផ្ទះ ឬ សំណង់ផ្សេង ៗ

(Architecture) ។

ស្ថាបនកម្ម = ន. ការកសាង , ការសង់ (Construction) ។

## សំណួរ

១ – ចូរពន្យល់ពាក្យ : ឧប្បត្តិក , វិជ្ជាស្ថាន , ស្ថាបនិក , វិច្ឆន្តគ្រិះ ។

២ – ចូររកវេវចនស័ព្ទនៃពាក្យ : ធានី ។

៣ – ចូររកសទិសស័ព្ទនៃពាក្យ : ពី ។

៤ – ពាក្យស្ថាបនិក និង ស្ថាបត្យករ ខុសគ្នាដូចម្ដេចខ្លះ ។

៥ – ចូរសម្ពន្ធប្រយោគទី ១ នៃអត្ថបទនេះ ។

៦ – ហេតុអ្វីបានជាគេដាក់ឈ្មោះ មហាវិទ្យាល័យនេះថា មហាវិទ្យាល័យឡូម៉ូណូស្សូវ ?

# មន្ទីរពេទ្យមិត្តភាពខ្មែរ - សូវៀត

ប្រជាជនខ្មែរគ្រប់ជាន់ថ្នាក់នៅចាំជាប់ជានិច្ចក្នុងសតិអារម្មណ៍របស់ខ្លួនថា កាលពីគ្រិស្តសករាជ ១៩៥៦ សម្តេចសហជីវិន ជាព្រះអគ្គមគ្គុទ្ទេសក៍របស់ខ្មែរ បានទ្រង់ស្តេចយាងទៅកាន់សហភាពសង្គមនិយមសូវៀត ដើម្បីធ្វើព្រះរាជទស្សនកិច្ចជាផ្លូវការ ។ ក្នុងពេលនោះអ្នកដឹកនាំធំៗ ពោលគឺវីរបុរស និងរដ្ឋបុរសនៃសហភាពសូវៀត បានសន្យាថានឹងផ្តល់ជំនួយយ៉ាងស្កុកស្តុមដល់ប្រទេសកម្ពុជា ជាមន្ទីរពេទ្យមួយ ដើម្បីទុកជាសក្ខីភាពនៃមិត្តភាពរវាងប្រទេសកម្ពុជា និងសហភាពសូវៀត ។

សហភាពសូវៀត បានគោរពតាមពាក្យសន្យានេះដោយត្រឹមត្រូវ ។ នៅថ្ងៃ១៦ ឧសភា ១៩៥៨ វិស្វករ អ្នកបច្ចេកទេស និងកម្មករខ្មែរ-សូវៀត ក៏បានចាប់ស្ថាបនាមន្ទីរពេទ្យនេះ លុះគ្រាតបានសម្រេចជារូបភាពជាក់ស្តែងឡើង ។

លុះដល់ថ្ងៃទី ២៦ សីហា ១៩៦០ មន្ទីរពេទ្យនេះបានទទួលការសម្ពោធន៍យ៉ាងមហោឡារិក ក្រោមព្រះរាជាធិបតីភាពនៃសម្តេចសហជីវិន ចំពោះមុខគណៈប្រតិភូសូវៀតទាំងឡាយ ។ ហើយមន្ទីរពេទ្យនេះក៏ត្រូវបានទទួលនូវការសន្មតនាមថា "មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ,, ដរាបរៀងមក ។

មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជាជំនួយយ៉ាងស្តុកស្តម្ភក្រៃលែងរបស់សហភាពសូវៀត ចំពោះប្រទេសកម្ពុជា ហើយជាជំនួយផ្នែកសាធារណសុខាភិបាលយ៉ាងធំបំផុតក្នុងបណ្តាប្រទេសទាំងឡាយនៅអាស៊ី ។ ប្រជាជនខ្មែរមានបីតិសោមនស្សចំពោះមន្ទីរពេទ្យនេះជាអតិបរមា ។

យើងគួរសំគាល់ជាអាទិ៍ថាមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតនេះជាជំនួយដ៏សប្បុរសរបស់សហភាពសូវៀត ដែលជាមហាប្រទេសសង្គមនិយម ចំពោះប្រទេសកម្ពុជា ហើយជាជំនួយក្នុងក្របខ័ណ្ឌពង្រីកសាធារណសុខាភិបាល តាមគោលការណ៍សន្តិភាព

អព្យាក្រឹត មិនមែនជាជំនួយ ដើម្បីពង្រីកផែនការសង្គ្រាម ឬជាជំនួយ ដើម្បីទាញយកទៅវិញ នូវហិតប្រយោជន៍ណាមួយឡើយ ។

### ពាក្យលំបាក

សតិអារម្មណ៍ = ន. ចិត្ត,គំនិត (Esprit, mémoire) ។

មគ្គុទ្ទេសក៍ ឬ មគ្គទេសក៍ = ន. អ្នកដឹកនាំ , អ្នកនាំផ្លូវ (Guide) ។

អគ្គមគ្គទេសក៍ =អ្នកដឹកនាំដែលធំជាងគេ ។

សហភាពសង្គមនិយមសូវៀត = មហាប្រទេសសង្គមនិយម គឺប្រទេស ដែលរួមគ្នាចំនួន ១៥ រដ្ឋមានរដ្ឋអ៊ុ-ក្រែន,រុស្ស៊ីជាដើម ។ ប្រទេសនេះបានកាន់លទ្ធិសង្គមនិយមមុនគេបង្អស់ លើសាកលលោក គឺកាន់លទ្ធិសង្គមនិយមតាំងពី គ.ស ១៩១៧ ដោយការបដិវត្តន៍ដែលដឹកនាំដោយ

លោក ឡេនីន ។ រដ្ឋាភិបាលកណ្ដាល

នៃសហភាព សូវៀត គឺរដ្ឋាភិបាលរុស្ស៊ី

(ក្រុងមូស្គូ) ។ (Union République Socialiste

Soviétique) ។

ទស្សនកិច្ច = ន. ការធ្វើដំណើរទៅទស្សនាប្រទេសនា ៗ ។

វីរបុរស = ន. អ្នកខ្លាំងពូកែដែលមានឈ្មោះល្បីល្បាញក្នុងការ

បំរើប្រទេសជាតិ (Héros) ។

រដ្ឋបុរស = ន. អ្នកកាន់កាប់កិច្ចការធំ ៗ របស់រដ្ឋ (Homme-

d'Etat) ។

សក្ខីភាព = ន. ភាពដែលកំណត់យកជាគ្រឿងសំគាល់, យក

ជាសាក្សី (Témoignage) ។

វិស្វករ = ន. អ្នកស្ទាត់ជំនាញខាងមុខងាររបច្ចេកទេស មាន

ការសំណាងជាដើម (Ingénieur) ។

សម្ពោធន៍ = ន.ពិធីធ្វើបុណ្យយ៉ាងឱឡារិក (Inauguration) ។

គណៈប្រតិភូ = ន. ក្រុមអ្នកដំណាង (Délégation) ។

ព្រះរាជាធិបតីភាព = ន. (ព្រះរាជ + អធិបតី + ការ) ភាពដែល
ដែលជាធំ; ភាពជាប្រធាន (ព្រះរាជាទ្រង់ជា
ប្រធាន) (Présidence) ។

សាធារណសុខាភិបាល = ន. (សាធារណ + សុខ + អភិបាល) ការ
ថែរក្សានូវសេចក្ដីសុខជាសាធារណៈ គឺការ
រក្សាសុខភាពរបស់ប្រជាជនទូទៅ (Santé
Publique) ។

បីតិសោមនស្ស = ន. សេចក្ដីត្រេកអរ, រីករាយ ។

អតិបរមា = គុ. ដែលច្រើនក្រៃលែង (Maximum) ។

សប្បុរស = គុ. ល្អ, ប្រសើរ, ត្រឹមត្រូវ, ស្មោះត្រង់ ។
ជំនួយសប្បុរស = ជំនួយដ៏ស្មោះ ។

ហិតប្រយោជន៍ = ន. ប្រយោជន៍ ដែលទាញយកពីជំនួយណាមួយឬទាញយកពីវត្ថុអ្វីមួយ ។

វេវចនស័ព្ទ

ប្រជាជន- ប្រជារាស្ត្រ- ប្រជាពលរដ្ឋ- បណ្ដាជន ។

កម្មករ- ពលករ- គូលី ។

សទិសស័ព្ទ

| កម្ម-កាំ |
|---|

កម្ម=(ម.ថ.កាំ)(ជាពាក្យបាលី) ន. អំពើ, ការប្រព្រឹត្ត ។

ពាក្យដែលផ្ដើមឡើងពី កម្ម គឺ៖

កម្មករ = ន. អ្នកប្រកបការងារដោយកម្លាំង គឺអ្នកស៊ីឈ្នួលពួកមេទុន ដែលត្រូវពួកមេទុនរឹបជាន់កម្លាំងរបស់ខ្លួន ( Ouvrier ) ។

កម្មវិបាក = ន. ផលដែលកើតឡើងពីការប្រព្រឹត្ត ។

កម្មបថ = ផ្លូវបុគ្គននៃកម្ម ។ ។ល។

កាំ = ន. (ជាពាក្យខ្មែរសុទ្ធ) អ្វីៗ ដែលរៀបជាជាន់, ជាថ្នាក់ សំរាប់ទល់, សំរាប់ទ្រ : កាំកង់, កាំរទេះ ---- ។

## រាង - រៀង

រាង = កិ-ប្ក-គុ. ចាល, រអា, លែងចង់, លែងត្រូវការទៀត : រាងចាល, ខ្ញុំរាងហើយ ---- ។

រាង = ន. សណ្ឋាន, ទ្រង់ទ្រាយ : រូបរាង; រាងរៅ; រាងក្រអាញ; រាងស្ដើង --- ។

រាង = ន. ផ្ទាំងរនាបឬស្សីពាសស្រទបចេក ដាក់លើគែមទូក មានបន្ទេរឲ្យផ្អៀងមកខាងក្នុងទូក : ដេញរាង ។

រៀង = កិ-ឬ-កិ-វិ. ដាក់តាមលំដាប់, ធ្វើឲ្យត្រូវលំដាប់, ឲ្យត្រូវរបៀប, ឲ្យត្រូវជួរ, រៀងលេខ, ដាក់រៀងគ្នា, តរៀងទៅ - - - ។

អត្ថាភិវុឌ្ឍ

មគ្គទេសក៍ ឬ មគ្គុទ្ទេសក៍ ឬ មគ្គុទ្ទេស ឬ មគ្គទេស ។ សក្ខី ឬ សាក្សី ។ សម្រេច ឬ សំរេច ។ សន្មតិ ឬ សម្មតិ ។ ភាទិ ឬ ភាទ៌ ។

ចំណាំ

**សម្ពោធន៍-សម្ពោធ**

ពាក្យទាំងពីរនេះជាសន្តានពាក្យមាន ន័យដូចគ្នា តែមួយជានាមស័ព្ទ មួយជាគុណស័ព្ទឬកិរិយាស័ព្ទ ។

សម្ពោធន៍ = (ជានាមស័ព្ទ) ពិធីធ្វើបុណ្យយ៉ាងឧឡារិក ។

សម្ពោធ = (ជាកិរិយាស័ព្ទ) ធ្វើបុណ្យយ៉ាងឧឡារិក ។

## មគ្គុទ្ទេសក៍-មគ្គុទ្ទេស

ពាក្យមគ្គុទ្ទេសក៍ឬមគ្គុទ្ទេសនេះសុទ្ធតែជានាមស័ព្ទ ដូចគ្នាទាំងអស់គ្មានប្រើជាគុណស័ព្ទឬកិរិយាស័ព្ទទេ ។ ហេតុនេះគេអាចសរសេរជា មគ្គទេសឬមគ្គុទ្ទេស ក៏បានសរសេរជា មគ្គទេសក៍ឬមគ្គុទ្ទេសក៍ ក៏បាន ។

### សំណួរ

១ – ចូរពន្យល់ពាក្យ : មគ្គុទ្ទេសក៍, សហភាពសូវៀត, សង្គមនិយម, សាធារណសុខាភិបាល ។ 11

២ – ចូររកវេវចនស័ព្ទនៃពាក្យ : ស្ថាបនា ។

៣ – ចូររកសទិសស័ព្ទនៃពាក្យ : រៀន ។

៤ – ចូរសម្ពន្ធប្រយោគទី ១ នៃអត្ថបទនេះ ។

៥ – ហេតុអ្វីបានជាអ្នកនិពន្ធអត្ថបទនេះហ៊ានអះអាង ថា ជំនួយរបស់សូវៀតជាជំនួយ ដ៏សប្បុរស ក្នុងគោលការណ៍ សន្តិភាព អព្យាក្រឹត ?

## សេចក្តីថ្លែងការណ៍រួមនៃប្រទេសកម្ពុជា និងប្រទេសចិនប្រជាមានិត

តាមសេចក្តីអញ្ជើញនៃប្រធានាធិបតី សាធារណរដ្ឋចិនប្រជាមានិត សម្តេចព្រះប្រមុខរដ្ឋយើងទ្រង់បានស្តេចយាងទៅដល់សាធារណរដ្ឋចិនប្រជាមានិតកន្លងថ្ងៃទី ១៩ ធ្នូ ១៩៦០ ដើម្បីទ្រង់ធ្វើទស្សនកិច្ចជាផ្លូវការ ។

កន្លងព្រះរាជដំណើរនេះ សម្តេចទ្រង់បានប្តូរទស្សនៈជាមួយនឹងឯ.ឧ. លីវចាវជី កន្លងការពិភាក្សាលើបញ្ហាដែលមានប្រយោជន៍រួមដល់ប្រទេសកម្ពុជា នឹងប្រទេសចិន ដែលយើងសូមដកស្រង់ដោយអន្លើដូចតទៅ :

គូសញ្ញាទាំងពីរបានកំណត់ដោយពេញចិត្តថា កិច្ចទស្សនាទៅវិញទៅមកជាច្រើនលើកច្រើនគ្រា ដែលអ្នកដឹកនាំរដ្ឋនៃប្រទេសទាំងពីរបានធ្វើកន្លងប៉ុន្មានឆ្នាំក្រោយនេះ ជាកិច្ចមួយសំខាន់បំផុតខាងការពង្រីកយ៉ាងខ្ជាប់ខ្ជួន ដល់ការប្រស្រ័យទាក់ទង

ជាមិត្តភាព និងដល់សហប្រតិបត្តិការរវាងប្រទេសទាំងពីរ ។ បំណងសេដ្ឋកិច្ចនិងពាណិជ្ជកម្មរវាងប្រទេសទាំងពីរកើតមានកាន់តែជិតស្និទ្ធឡើង ៗ ការប្តូរខាងវប្បធម៌និងសិល្បក៏មានកាន់តែញឹកញាប់ ហើយការប្រស្រ័យទាក់ទងជាមិត្តភាព និងជាអ្នកនៅជិតខាងគ្នាដោយសុខដុម រវាងប្រទេសទាំងពីរដោយតាំងនៅលើគោលការណ៍ទាំងប្រាំនៃសហវិជ្ជមានដោយសន្តិសុខ និងតាមគំនិតនៃសន្និសិទ្ធបានឌុង បានទ្រទ្រង់ដល់ការលំបាកកន្លងកាលៈទេសៈ ហើយបានទទួលការសរសើរយ៉ាងទូលំទូលាយខាងផ្លូវអន្តរជាតិ ដែលជាឧទាហរណ៍មួយយ៉ាងប្រសើរខាងសហ-វិជ្ជមានដោយសន្តិភាព រវាងប្រទេស ដែលមានរបៀបគ្រប់គ្រងសង្គមជាតិខុសគ្នា ៗ ... គូសញ្ញាចិនគោរព និងទ្រទ្រង់យ៉ាងពេញបន្ទុក ដល់នយោបាយសន្តិភាព អព្យាក្រិតភាព ឯករាជភាព និងអធិបតេយ្យភាព ដែលរាជរដ្ឋាភិបាលកម្ពុជាអនុវត្ត... ។

## ពន្យល់ពាក្យ

សាធារណរដ្ឋ = រដ្ឋដែលគ្មាន ព្រះមហាក្សត្រ គ្រងរាជ្យ (République) ។

ទស្សនៈ = ន. មតិ, យោបល់, សេចក្ដីយល់ឃើញ (Opinion, point de vue) ។

ពិភាក្សា = កិ. ជជែកវែកញែក, ជជែកប្ដូរយោបល់គ្នា (Débattre; Discuter) ។

សហប្រតិបត្តិការ = ន. កិច្ចការដែលត្រូវធ្វើរួមគ្នា, ប្រតិបត្តិការរួមគ្នា (Coopération) ។

សេដ្ឋកិច្ច = ន. មុខរបរដែលមានប្រយោជន៍សំខាន់បំផុតនៃប្រទេសនិមួយៗ (Economie) ។

ពាណិជ្ជកម្ម = ន. មុខរបរខាងជំនួញ (Commerce) ។

វប្បធម៌ = ន. ការបណ្ដុះបណ្ដាលឲ្យលូតលាស់ខាងចំណេះវិជ្ជា ក្បួនច្បាប់ផ្សេងៗ (Culture) ។

សុខដុម ឬ សុខដុមរមនា = ន. ការនៅផ្គុំគ្នា ឬនៅមូលគ្នាជាសុខឥតមានសៅហ្មង ។

សហវិជ្ជមានដោយសន្តិសុខ = ន. ភាពជាអ្នកមានការរស់នៅជាមួយគ្នាដោយសុខសាន្ត, ការរស់នៅដោយរួមគ្នាជាសុខសាន្ត (Coexistence pacifique) ។

សន្និសីទ = ន. ការរួមប្រជុំដើម្បីថ្លែងការអ្វីមួយ (Conférence) ។

កាលៈទេសៈ = ន. ពេលវេលា ។

អន្តរជាតិ = ន. ជាតិនានា, ជាតិទូទៅ (International) ។

សន្តិភាព = ន. ភាពនៃការរស់នៅដោយសុខសាន្តត្រាណ ប្រាសចាកនូវការបង្ហូរឈាម (Paix) ។

ឧទាហរណ៍ =ន. ការលើកឡើងឲ្យឃើញ , ការនាំមកពន្យល់

បុចផ្ទុលឲ្យឃើញ, ក័ស្តុតាង, បែបយ៉ាង, គំរូយ៉ាង

(Exemple) ។

អព្យាក្រិតភាព=ន. ភាពដែលនៅចំកណ្តាល គឺមិនចូលខាង

សង្គមនិយមបុចក្រុតត្តិនិយម (Neutralité) ។

អធិបតេយ្យ ឬ អធិបតេយភាព = ន. ភាពដែលជាធំ

(Souveraineté) ។

អនុវត្ត=កិ. ប្រព្រឹត្តតាម,ធ្វើតាម,ប្រតិបត្តិតាម (Appliquer) ។

ប្រើជាភាមស័ព្ទ: អនុវត្តន៍ ។

វេវចនស័ព្ទ

ឧទាហរណ៍ - គំរូយ៉ាង-គំរូ ។

សន្តូនា-កិតាក្យា-បូរ:យោបល់-ជដៃកវៃកញែក។

# សទិសស័ព្ទ

## ក-ការ-ការណ៍-កាណិ

ក = ន. បំពង់សម្រាប់ដាក់ទឹក៖ កាទឹកកា ។

ក = កិ. សរសេរចុះឈ្មោះអ្នកដែលនឹងទទួលសំបុត្រនៅលើស្រោមសំបុត្រដែលនឹងផ្ញើទៅ៖ កាខ្នងសំបុត្រ ។

កាណិ = (ម.ជ.ក) (រ.ស) ត្របៀក ។ ព្រះកាណ៌ = ត្របៀកស្តេច ។

ការ = កិ. មូរសរសៃសូត្រ ឬ សរសៃអម្បោះដោយខ្នារ = ការសូត្រ, ការអម្បោះ ... ។

ការ = កិ. បិទបាំង, រាំងរ, ឃាត់ខាំង = ការពារខ្លួន, ការពារសត្រូវ ... ។

ការ = ន. កិច្ចឬអំពើដែលត្រូវធ្វើ = ធ្វើការ, មានការ, ការអ្វីខ្លះ ?

ការ = ន. កិច្ចដែលត្រូវធ្វើតាមមុខងាររបស់ខ្លួន = ធ្វើការ-ងារ, មានការងារ ... ។

ការណ៍ = ន. ហេតុដំណើរ = ទាស់ការណ៍, ហេតុ-ការណ៍, ព្រឹត្តិការណ៍ ... ។

អក្ខរាវិរុទ្ធ

សុខដុម ឬ សុខដុមរមនា ឬ សុខដុំ ។

សិល្បៈ ឬ សិប្បៈ ។

អព្យាក្រឹត្យ ឬ អព្យាក្រឹតភាព ។

ឯកភាជ្យ ឬ ឯកភាជភាព ។

អធិបតេយ្យ ឬ អធិបតេយភាព ។

## អំពីមូសិកទន្តនិងត្រីស័ព្ទ

មូសិកទន្ត = " " សម្រាប់ប្រើ បំបែរសំឡេងព្យញ្ជនៈ

ឃោសៈខ្លះ ឲ្យមានសូរស័ព្ទទៅជាអឃោសៈ។

មូសិកទន្តនេះមានអំណាចប្រើបានចំពោះតែអក្សរ ៧
តួប៉ុណ្ណោះគឺ៖ ង, ញ, ម, យ, រ, វ, ប ។

កាលបើមូសិកទន្តនៅពីលើហើយ ព្យញ្ជនៈ ទាំង ៧
តួនេះ មានសំឡេងអឃោសៈវិញគឺ ៖

ង៉, ញ៉, ម៉, យ៉, រ៉, វ៉, ប៉ ។

ចំណាំ

## សិល្បៈ-សិល្បករ

ពាក្យ « សិល្ប » នេះបើប្រើដាច់តែឯង ត្រូវសរសេរជា "សិល្បៈ" ឧ - ខ្ញុំរៀនសិល្បៈ, សិល្បៈខ្មែរ... ។ បើប្រើនៅភ្ជាប់ពីខាងដើមសព្ទឯទៀតត្រូវលុបយុគលពិន្ទុចេញ ដូចជា សិល្បករ, សិល្បការ, សិល្បការី, សិល្បវិទ ... ។

# អព្យាក្រឹត-អព្យាក្រិត្យភាព

ពាក្យ « អព្យាក្រិត្យ » នេះមានប្រើជានាមសព្ទផង ជាគុណសព្ទផង ។ បើប្រើជាគុណសព្ទ ត្រូវសរសេរជា « អព្យាក្រឹត » ។ ដូចជា: ប្រទេសអព្យាក្រឹត, នយោបាយអព្យាក្រឹត . . . ។ បើប្រើជានាមសព្ទត្រូវសរសេរជា « អព្យាក្រិត្យ » ។ ដូចជា: ប្រទេសកម្ពុជាកាន់អព្យាក្រិត្យ, អព្យាក្រិត្យប្រទេសស្វីស... ។ ចំពោះពាក្យ « អព្យាក្រិត្យ » ដែលជានាមសព្ទនេះ គេអាចថែមពាក្យ « ភាព » មួយទៀតក៏បាន ប៉ុន្តែបើកាលណាមានពាក្យ « ភាព » នៅខាងចុងយើងត្រូវលុបជើងយ « ្យ » ចេញ អព្យាក្រិតភាព ។

## សំនួរ

១– ចូរពន្យល់ពាក្យ : សហវិជ្ជមានដោយសន្តិសុខ, សហប្រតិបត្តិការ, សុខដុមរមនា, អធិបតេយភាព ។

២– ចូររកវេវចនសព្ទនៃពាក្យ : សន្តិសុខ ។

៣– ចូររកសទិសសព្ទនៃពាក្យ : ការ ។

៤– ចូរពន្យល់អំពីឧត្តមគតិនៃអត្ថបទនេះ ។

# សន្ធិសញ្ញាមេត្រីភាពខ្មែរចិន

កាលពីថ្ងៃទី ១៩ ខែធ្នូ ១៩៦០ នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា និង នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋចិនប្រជាមានិតបានចុះហត្ថលេខាលើសន្ធិសញ្ញាមួយ ដែលមានសេចក្ដីដូចតទៅ ៖

ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋចិនប្រជាមានិត នឹងផ្គត់ផ្គង់រវាងគ្នានឹងគ្នានូវសន្តិភាពជាអចិន្ត្រៃយ៍ព្រមទាំងពង្រីក នឹងពង្រឹងនូវកិច្ចប្រស្រ័យទាក់ទងជាមិត្តភាព រវាងគូសញ្ញាទាំងពីរ ។ ឧត្តមភាគីគូសញ្ញាម្នាក់ៗ សន្យាថានឹងគោរពដល់អធិបតេយភាព ឯករាជភាព និងបូរណភាព នៃដែនដីនៃគូសញ្ញាផងខ្លួន, សន្យាថា មិនប្រព្រឹត្តអំពើឈ្លានពានលើគូសញ្ញាផងខ្លួនហើយ មិនចូលរួមក្នុងសម្ពន្ធយោធាប្រឆាំងនឹងគូសញ្ញាផងខ្លួន ។

ឧត្តមភាគីគូសញ្ញាទាំងពីរ នឹងពង្រីកហើយនឹងពង្រឹងនូវចំណងសេដ្ឋកិច្ចនិងវប្បធម៌រវាងប្រទេសរៀងខ្លួនទាំងពីរស្របតាមគោលការណ៍សមភាព និងអត្ថប្រយោជន៍ទៅវិញទៅមក ហើយនឹងគោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃប្រទេស ។

អធិករណ៍ ឬវិវាទទាំងឡាយណា ដែលអាចនឹងកើតឡើងពីការបកស្រាយ ឬ ការអនុវត្តន៍នៃសន្ធិសញ្ញានេះ ឬ ពីការបកស្រាយ ឬ ការអនុវត្តន៍នៃមាត្រាណាមួយ ឬ ច្រើនក្តីនៃសន្ធិសញ្ញានេះនឹងត្រូវដោះស្រាយដោយការចរចាតាមផ្លូវទូតធម្មតា ។

សន្ធិសញ្ញានេះនឹងត្រូវទទួលការសច្ចាប័នតាមច្បាប់រដ្ឋធម្មនុញ្ញរបស់ឧត្តមភាគីគូសញ្ញារៀងខ្លួន ។ សន្ធិសញ្ញានេះនឹងដាក់ឲ្យអនុវត្តចាប់តាំងពីកាលបរិច្ឆេទដែលបានប្តូរទៅវិញទៅមកនូវលិខិតនៃសច្ចាប័នដែលនឹងធ្វើនៅក្រុងភ្នំពេញក្នុងពេលយ៉ាងខ្លីបំផុត ។ សន្ធិសញ្ញានេះនឹងទុកនៅជាធរមានបញ្ញត្តិដរាបល័ក្គណា បើឧត្តមភាគីគូសញ្ញាណាមួយ ពុំបានប្រកាសបដិសេធចោលដោយជូនដំណឹងជាមុនមួយឆ្នាំ ។

## ពន្យល់ពាក្យ

សន្ធិសញ្ញា = ន . សេចក្តីសំគាល់ជាលក្ខណ៍, សញ្ញាសំគាល់ជាគោលចំពោះគ្នានឹងគ្នា (Traité) ។

មេត្រីភាព = ន. ភាពរាប់រកគ្នា , ភាពរាប់អានគ្នាទៅវិញទៅមក (Amitié) ។

នាយករដ្ឋមន្ត្រី = ន. រដ្ឋមន្ត្រីទី ១ , អ្នកកាន់កាប់កិច្ចការធំរបស់គណៈរដ្ឋាភិបាល (Président du Conseil des Ministres) ។

អចិន្ត្រៃយ = គុ. ដែលមិនចេះអស់មិនចេះហើយ , ដែលរកទីបំផុតគ្មាន ។

ប្រស័យ = ន. សេចក្ដីស្រឡាញ់, រាប់អាន, សេចក្ដីគោរព ; ដំណើរត្រូវអធ្យាស្រ័យគ្នា ។

បូរណភាព = ន. ភាពដែលពេញបរិបូណ៌ ; ភាពដែលពេញគ្រប់គ្រាន់ (Intégrité) ។

សម្ពន្ធយោជា = ន. ការទាក់ទងគ្នាខាងកន័ទេព ។

សមភាព = ន. ភាពស្មើគ្នា (Egalité) ។

អត្ថប្រយោជន៍ = ន. ប្រយោជន៍ធំល្អ, ធំសំខាន់ ។

អធិករណ៍ = ន. ការទាស់ទែងខ្វែងគំនិតគ្នា (Conflit) ។

សច្ចាប័ន = ន. ការយល់ស្របឥតល្អៀង, ការសំដែងសេចក្ដីយល់ព្រមដោះស្មោះចំពោះ (Ratification) ។

រដ្ឋធម្មនុញ្ញ ឬ រដ្ឋធម្មនូញ = ន. ច្បាប់ស្ដីពីការគ្រប់គ្រងប្រទេសនីមួយៗ (Constitution) ។

កាលបរិច្ឆេទ = ន. ពេលដែលមានកំណត់ទុក ។

ធរមានបញ្ញតិ = ន. បញ្ញតិច្បាប់ឬបទបញ្ជា ដែលគេកំពុងតែឲ្យប្រើប្រាស់, ច្បាប់ដែលគេនៅតែប្រើ (Loi en vigueur) ។

វេវចនស័ព្ទ

នាយករដ្ឋមន្ត្រី - រដ្ឋមន្ត្រីទី១ ។

ឈ្មានពាន - ជ្រៀតជ្រែក - ចុករុក ។

សទិសស័ព្ទ

## ន័យ - ន័យ

ន័យ = ពាក្យប្រើក្លាយមកពី ភ.បាលីនិងសំស្ក្រឹត នយ ជានាមស័ព្ទ ការណែនាំ, អធិប្បាយ, សេចក្ដីពន្យល់, ហេតុ, ទំនង, លំនាំ (Sens) = ន័យប្រៀប, មានន័យ.... ។

ន៏ = អា-និ. ជាពាក្យខ្មែរសុទ្ធ សម្រាប់ប្រើជំនួសពាក្យ របស់=គោលការណ៍បន្ទុសង្គ្រាម នៃចក្រពត្តិនិយម គឺគោលការណ៍បន្ទុសង្គ្រាមរបស់ ចក្រពត្តិនិយម ។

## មាន-មៀន

មាន = កិ. បាន, គប, ប្រកបដោយ, កើត, បរិបូណ៌ដោយ, គង់នៅ, ស្ថិតនៅ ...= មានគ្រូន, មានវិជ្ជា, មនុស្សត្រូវមានសីលធម៌ ។ 12

ពាក្យផ្ទុយគឺ គ្មាន ។

មៀន = ន. ឈ្មោះឈើមួយយ៉ាងដែលជាដំណាំស្រុក មាន ផ្លែជាបន្លែម = ដើមមៀន, ផ្លែមៀន ។

មៀន — ន. បន្ទំវែងស្រោបគល់ដងកាំបិតឬ ផ្គាក់ ឲ្យជាប់មាំ ត្រង់ទីកបន្សា = មៀនកាំបិត ។

អត្ថាវិរុទ្ធ

អាណាចក្កឬអាណាចក្រ ។ សម្ពន្ធយោគ ឬ សម្ព័ន្ធយោគ ។ បូរណភាព ឬ សំបូរណភាព ។

## អំពីមូសិកទន្តនិងត្រីស័ព្ទ (គ)

ត្រីស័ព្ទ " ៊ " សម្រាប់ប្រើបំបែរសំឡេងអក្សរ ដែលជាអឃោសៈខ្លះឲ្យមានសំឡេងឃោសៈវិញ ។ ត្រីស័ព្ទនេះត្រូវប្រើតែលើអក្សរបួនតួប៉ុណ្ណោះគឺ : ប៊,ស៊,ហ៊,អ៊ ។ កាលបើត្រីស័ព្ទអាស្រ័យ

នៅលើអក្សរទាំងបួនតួនោះហើយ អក្សរនោះ
ក៏ប្រែជាមានសំឡេងជាឃោសៈ គឺធំ គ្រលរ
ទៅវិញ ។ ប៊ិ, ស៊ិ, ហ៊ិ, អ៊ិ, ។

បំណាំ – ក) តួអក្សរដែលមានមូសិកទន្តឬត្រីស័ព្ទហើយ មាន
ស្រៈពីលើតួទៀតដូចជាស្រៈ( ិ ី ឹ ឺ, ើ ំ )
ក្នុងវេយ្យាករណ៍ឲ្យផ្លាស់មូសិកទន្តឬ ត្រីស័ព្ទ
ជាបុះជើងវិញ ។

ឧទាហរណ៍:–

ស៊ី-តាប៊ី( គេមិនសរសេរ ស៊ី, តាប៊ី ដូច្នេះទេ ។

១) ក្នុងពាក្យពីរព្យាង្គ បើកាលណាតួសំឡេងព្យាង្គ
ដើមបង្អោនស័ព្ទទៅលើតួព្យាង្គខាងចុង តួអក្សរ
ព្យាង្គចុងមិនត្រូវមានមូសិកទន្ត ឬ ត្រីស័ព្ទទេ ។

ឧទាហរណ៍

ស្រមោល (មិនត្រូវសរសេរស្រម៉ោលទេ) ។

ក្រមរ, ក្រមារ ( „ ក្រម៉រ ឬ ក្រម៉ារ „ ) ។

ដំបាន ( „ ដំហ៊ាន " ) ។

ចំណាំ

ឯករាជ - ឯករាជ្យ

ពាក្យទាំងពីរនេះមានន័យដូចគ្នា តែមួយប្រើជាគុណស័ព្ទ មួយប្រើជានាមស័ព្ទ ។

ឯករាជ = ជាគុណស័ព្ទ មិនត្រូវដាក់ជើង យ " ្យ " នៅពីក្រោមតួ ជ ទេ ។ ឧ. កម្ពុជា ជាប្រទេស ឯករាជ ។

ឯករាជ្យ = ជានាមស័ព្ទ ត្រូវដាក់ជើង យ " ្យ " នៅពីក្រោមតួ ជ = ឯករាជ្យ ឧ. កម្ពុជា

បាន ឯករាជ្យ... ឯករាជ្យ នៃ
ប្រទេសកម្ពុជាត្រូវបានកន្លងឆ្នាំ . . . ។

## អធិបតេយ្យ-អធិបតេយភាព

ពាក្យទាំងពីរនេះមានន័យដូចគ្នា ហើយក៏ជានាមស័ព្ទ ដូចគ្នាដែរអាចឲ្យយើងប្រើផ្លាស់ប្ដូរគ្នាបាន ។ ប៉ុន្តែត្រូវចំណាំចំពោះអក្ខរាវិរុទ្ធ នៃពាក្យទាំងពីរនេះដូចតទៅ ៖

អធិបតេយ្យ សម្រាប់ប្រើដាច់តែឯង ។ បើថែមពាក្យ "ភាព" មកទៀតត្រូវលុបជើង យ "្យ" ដែលនៅពីក្រោមអក្សរ យ ចេញ គឺត្រូវសរសេរជា អធិតេយភាព ។

សំនួរ

១ – ចូរពន្យល់ពាក្យ : សម្ពន្ធយោធា, សមភាព, ស្ថាប័ន, រដ្ឋមន្ត្រី ។

២ – ចូររកវេវចនស័ព្ទនៃពាក្យៈ មេត្រីភាព ។

៣ - ចូររកសទិសស័ព្ទនៃពាក្យ : គូ ។

៤ – ចូរស្រង់នាមតាំងអស់ក្នុងអត្ថបទនេះ ។

៥ – ហេតុអ្វីបានជាប្រទេសកម្ពុជា នឹងប្រទេស ចិនចុះសន្ធិសញ្ញាមេត្រីភាពរវាងគ្នានឹងគ្នា ?

# សិល្បៈនិងជីវភាពមនុស្សជាតិ

សិល្បៈ ជាមែកធាងមួយរបស់ វប្បធម៌ ។ ដូច្នេះ, យើងមិនត្រូវរាប់សិល្បៈថា គ្រាន់តែជាគ្រឿងលំអផល់ភ្នែក ឬ គ្រាន់តែជាទីសំចតមួយដ៏ស្រួលក្រៃពេក សម្រាប់មនុស្សដែលឃ្លាតពីការតស៊ូឡើយ ។ យើងត្រូវ បដិសេធ គំនិតយល់របៀប ហ្នឹង ចោលចេញព្រោះគំនិតនេះ ជាគំនិតរបស់ពួកចក្រពត្តិ និងនាយទុនលោភកាម, ហើយគំនិតនេះប្រឆាំងនឹងប្រវត្តិសាស្ត្រ មនុស្សជាតិផ្ទុយនឹងផលប្រយោជន៍សង្គម ។ យើងមុខជាអាចយល់បានដោយច្បាស់លាស់ អំពីមុខការនៃសិល្បៈ ក្នុងការរៀបចំអារ្យធម៌ បំរើសង្គមមនុស្ស បើយើងក្រឡេកមើលប្រវត្តិសង្គមមនុស្ស នៅក្នុងយុគសិលាបុរាណ,យុគនវសិលា និងយុគតៗ មកទៀត ។ មុនកំណើតវិទ្យាសាស្ត្រមុនមានអក្សរ ហើយប្រហែលជាមុនមានភាសា ត្រឹមត្រូវទៀតផង សិល្បៈ

បានជួយដោះទុក្ខមនុស្សនៅចំពោះមុខ ភយន្តរាយ និងអាថ៌កំបាំង ។ សិល្បៈសំដែងសេចក្តីក្លាហានរបស់មនុស្ស ប្រាជ្ញារបស់មនុស្សក្នុងការស្វែងរក និងរៀបចំ សម្ភារៈ ។ សិល្បៈបានសំដែង មនោសញ្ចេតនា, វេទយិតភាព ឆន្ទៈ និងសំដែងកម្លាំងជឿនលឿនរបស់មនុស្ស មុនជំបូងបង្អស់ ។ ដូច្នេះ, សិល្បៈជាមេបណ្តុះគំនិតមនុស្ស ។ ស្នាដៃ សិល្បករបាននាំមកឲ្យមនុស្សនូវការពិតត្រឹមត្រូវក្នុងសម័យ របស់ខ្លួនដើម្បីឲ្យមនុស្សទាំងឡាយកើតមានប្រាជ្ញាស្មារតី, មានការត្រិះរិះច្រើន, បេះរកមធ្យោបាយ ដោះស្រាយបញ្ហាជីវិត ឲ្យបានអភិរម្យជាងដើមទៅទៀត ។

## ពន្យល់ពាក្យ

សិល្បៈ = ន. ចំណេះខាងភ្លេង តន្ត្រីយ៍ និងការរចនាវិចិត្រផ្សេងៗ (Art) ។

បដិសេធ = កិ. ឃាត់, ហាម, លើកចោលចុ ទាត់ចោល

ផែនយកជាការ ៗ ក្នុងអត្ថបទនេះគឺ ចាត់ទោល ៗ

បក្រពត្តិនិយម = ន. ពួកចោរប្លន់ប្រទេស ដែលនិយមបង្កបង្កើតសង្គ្រាម (Impérialiste) ៗ

នាយទុន = ន. អ្នកដែលមានប្រាក់ធ្វើដើមទុនសម្រាប់យកទៅរកស៊ីកេងយកកម្រៃពីកម្លាំងកាយនឹងញើសរបស់អ្នកដទៃ ដូចជារកស៊ីចងការប្រាក់, ធ្វើកុងស៊ីបញ្ចាំជាដើម (Capitaliste) ៗ

យុគសិលាបរមបុរាណ = ន. សម័យដ៏យូរលង់ណាស់មកហើយ ៗ

យុគនវសិលា=ន.សម័យថ្មីក្នុងយុគថ្ម,សម័យមុនគ្រិស្តសករាជ

អាថ៌កំបាំង = រឿងរ៉ាវដែលជាការសម្ងាត់ (Secret) ៗ

វេទយិតភាព=ន. ការដឹងឈឺចាប់, ដឹងថាព្រួយថាសប្បាយ ៗ

ឆន្ទៈ = ន. បំណង,បំណន់ ។

អភិរម្យ = ន.សេចក្តីសប្បាយរីករាយក្រៃលែង, សេចក្តីរីករាយ
យ៉ាងខ្លាំង ។

វេវចនសព្ទ

កាល-សម័យ-ពេល-វេលា-រយៈ ។

នាយទុន-គហបតី-សេដ្ឋី-មូលធនិក ។

សទិសសព្ទ

**សាសន៍-សាស្ត្រ-សះ**

សាសន៍ = (ម.ថ.សាស់) ន. សាសនា: សាសៈព្រះពុទ្ធ
ព្រះពុទ្ធសាសន៍ ។

សាស្ត្រ = (ម.ថ.សាស់) (ពាក្យក្លាយមកពីពាក្យ សស្ត្រ) ។
ប្រើចំពោះតែ មុខសាស្ត្រ: មុខរបួសដែល
មុតដោយគ្រឿងសស្ត្រា ។

ស៊ះ = កិ. ជាដំបៅ, បាត់ដំបៅ : សះដំបៅ, ដំបៅសះ ។

## ព្រួស-ព្រោះ

ព្រួស = កិ. បញ្ចេញទឹកឬទឹកមាត់ពីក្នុងមាត់ឲ្យខ្ចាយព្រោង ដោយកម្លាំងខ្យល់ : ព្រួសទឹក, ព្រួសទឹកមាត់ ។

ព្រោះ = កិ. បាចគ្រាប់ពូជល្អិតៗមានគ្រាប់ស្ពៃ, ល្ង, ថ្នាំ, ស្រូវ ជាដើមដើម្បីឲ្យដុះលូតលាស់ឡើង : សាបព្រោះ, ព្រោះស្រូវ ។

ព្រោះ = គា.និ. ហេតុ, ត្បិត : ព្រោះតែ, រឿងពុំនេះ ព្រោះខ្ជិល --- ។

(១) អត្ថាភិវុឌ្ឍ

សិល្បៈឬសិប្បៈ ។ អារ្យធម៌ឬអរិយធម៌ ។

បរមបុរាណឬបរមបូរាណ ។ កម្លាំងឬកំឡាំង ។

# រស្សសញ្ញា–បន្តក់

បំណាំ – ក ) បន្តក់ ( ់ ) កាត់សព្ទវែងជាសព្ទខ្លី ។

ឧទាហរណ៍

ក –> កន់ ។ បាប –> បាប់ ។

ខ ) បន្តក់ប្រើលើពាក្យខ្មែរ ដែលត្រូវសំឡេងកើតពី ស្រះ "អ" និងស្រះ "អា" ហើយត្រូវប្រកបជាអក្សរ

ក, ង, ប, ញ, ត, ន, ម, ល, ស, ។

ឧទាហរណ៍ :

ក = សក ▸ សក់

សាក ▸ សាក់

ង = កង ▸ កង់

សាង ▸ សាំង (១)

ប = បប ▸ បប់

បាប ▸ បាប់

ញ = កញ > កញ់

កាញ > កាញ់

ត = សត > សត់

កាត > កាត់

ន = គន > គន់

គាន > គាន់

ប = លប > លប់

កាប > កាប់

ល = កល > កល់

ទាល > ទាល់

ស = កស > កស់

ប្បាស > ប្បាស់ ។ ល ។

(១) – ចំពោះស្រៈ "អា" ប្រកបនឹងខ្យល់ "ង" ដើម្បីធ្វើឲ្យខ្លី គេមិនត្រូវប្រើស្យេសញ្ញាទេ គឺត្រូវប្រើនិគ្គហិត ( ° ) ជំនួសវិញ ។

ឧទាហរណ៍

សាំង-កាំង-ខាំង-ឃាំង-ឆ្នាំង-ខ្លាំង-បាំង-ប្រាំង-ប្លាំង ។ល។

ឃ — ក្នុងពាក្យបាលីឬសំស្រ្កឹត ដែលខ្មែរយើងយកមកប្រើ មិនមានសញ្ញាបន្តក់ទេ ។

ឧទាហរណ៍

កុសល,ផល,សកល,លាមក,ធនជាន,ជន,បុរស ។ល។

សំនួរ

១ – ចូរពន្យល់ពាក្យ=នាយទុន, យុគសិលាបរមបុរាណ,វេទយិតភាព, អភិរម្យ ។

២ – ចូររកវេវចនស័ព្ទនៃពាក្យ : នាយទុន ។

៣ – ចូររកសទិសស័ព្ទនៃពាក្យ : សះ ។

៤ – ចូរសម្ពន្ធប្រយោគទី ១ នៃអត្ថបទនេះ ។

៥ – ចូររកឧត្តមគតិនៃអ្នកនិពន្ធអត្ថបទនេះ ។

# អ្នកនិពន្ធនិងអក្សរសាស្ត្រ

នៅក្នុងប្រទេសបក្រពត្តិនិយម អាណានិគមនិយម និង ប្រជាធិបតេយ្យអភិជនទាំងឡាយលើសកលលោក អក្សរសាស្ត្របានបែកចេញជាពីរពួកផ្សេងគ្នា គឺអក្សរសាស្ត្រប្រតិកិរិយា និង អក្សរសាស្ត្រជឿនលឿនបដិវត្តន៍ ។

អក្សរសាស្ត្រទាំងពីរនេះបានផុសចេញពីមជ្ឈដ្ឋានផ្សេងគ្នា មានទស្សនៈខុសគ្នា ហើយជាបដិបក្ខភាពមិនអាចបន្ធូរបន្ថយ បានរវាងគ្នានិងគ្នាផង ។

អក្សរសាស្ត្រ ប្រតិកិរិយាផុសចេញពីការនិពន្ធ ដ៏ខ្វះវិចារណញាណរបស់អ្នកនិពន្ធប្រតិកិរិយា ។ អក្សរសាស្ត្រនេះ បានគាំទ្រផលប្រយោជន៍របស់ពួកមូលធនិកជាប់មុខមួយក្ដាប់ - ហើយបំផ្លាញផលប្រយោជន៍រួមរបស់វណ្ណៈអធនមួយចំនួនធំ ។ អ្នកនិពន្ធប្រតិកិរិយាដែលជាមនុស្សមានឋានៈខ្ពស់ ឬ ដែលបាន ទទួលជំនួយយ៉ាងសុកសម្ភ អំពីពួកបក្រពត្តិ និងពួកមូលធនិក

បាននាំគ្នាសរសេរលើកដំកើងតែវណ្ណៈគហបតី និងបោកប្រាស់ប្រជាជនឲ្យស៊ូគ្រប់រើនាយទុនយ៉ាងផ្តាច់មុខ ។

បំណែកអក្សរសាស្ត្រជឿនលឿននិងបដិវត្តន៍ បានផុសចេញៈដោយសុទ្ធចិត្តពីមនោគតិដ៏ខ្ពង់ខ្ពស់ របស់អ្នកនិពន្ធជឿនលឿននិងបដិវត្តន៍ ។ អក្សរសាស្ត្រនេះ បានគាំទ្រយ៉ាងពេញទំហឹងនូវផលប្រយោជន៍ របស់ប្រជាជន បានប្រយុទ្ធប្រឆាំងនឹងការរើសអើងពណ៌សម្បុរនិងការប្រកាន់ឋានៈវណ្ណៈ ហើយបានការពារសន្តិភាពសកលយ៉ាងមុតមាំ ។

អ្នកនិពន្ធគួរតែយល់ឲ្យច្បាស់ថា "អក្សរសាស្ត្រជាសំនួនវោហារនៃគតិសាស្ត្រ ដែលបកស្រាយគ្រប់ចេតនាសម្ពន្ធរបស់សង្គម និងជាពន្លឺនៃមូលដ្ឋានសេដ្ឋកិច្ច និងជាសតិបរិក្ខាក្នុងការប្រយុទ្ធរវាងវណ្ណៈ„ ហើយ "ករណីយកិច្ច និងកាតព្វកិច្ចរបស់អ្នកនិពន្ធ គឺដឹកនាំប្រជាជនឆ្ពោះទៅកាន់សេចក្តីចំរើន មិនមែនបណ្តោយឲ្យគេដឹកនាំ ដើម្បីបំផ្លាញផលប្រយោជន៍ប្រជាជនឡើយ" ។

## ពន្យល់ពាក្យ

បក្រពត្តិនិយម = (មើលសេចក្ដីពន្យល់ក្នុងអត្ថបទបន្ទាប់) ។

អាណានិគម = ន. ពួកចោរប្លន់ប្រទេសមួយផ្នែកដែលនិយម
ដើរជិះជាន់ប្រទេសគេ, និយមយកប្រទេស
គេដាក់ជាចំណុះខ្លួន ។ ពួកអាណានិគម
ក៏ដូចជាពួកបក្រពត្តិនិយមដែរ ។

ប្រជាធិបតេយ្យ = ន. លទ្ធិមួយដែលលើកដំកើងរាស្ត្រជាធំគឺ
រាស្ត្រជាអ្នកចាត់ចែងកាត់តែងច្បាប់សម្រាប់រដ្ឋ និង
សម្រេចកិច្ចការនយោបាយរបស់រដ្ឋ ។ ប្រជាធិ-
បតេយ្យអភិជន គឺប្រជាធិបតេយ្យក្លែងក្លាយមិន
បរិសុទ្ធ ដែលលើកដំកើងតែពួកអ្នកមាននិងពួក 13
នាយទុន (Démocratie bourgeoise) ។

ប្រតិកិរិយា=គុ. ដែលប្រឆាំងនឹងសេចក្ដីពិតៗ អក្សរសាស្ត្រ

ប្រតិកិរិយា = អក្សរសាស្ត្រដែលប្រឆាំងនឹងសេចក្ដីពិត, ដែលប្រឆាំងនឹងកម្លាំងជឿនលឿនរបស់ប្រជាជន ។ (Littérature réactionnaire) ។

អក្សរសាស្ត្រជឿនលឿនបដិវត្តន៍ = អក្សរសាស្ត្រដែលចំរើនជឿនលឿន, ដែលនិយាយអំពីជីវភាពពិតប្រាកដ របស់ប្រជាជននឹងដឹកនាំប្រជាជនឆ្ពោះទៅកាន់សេចក្ដីចំរើនរុងរឿង (Littérature progressiste) ។

មជ្ឈដ្ឋាន = ន. ទីកន្លែងកណ្ដាល (Centre) ។

បដិបក្ខភាព = ន. ភាពដែលផ្ទុយ, ដែលប្រឆាំង, ដែលជាសត្រូវ (Contraste) ។

មូលធនិកផ្តាច់មុខ = ន. អ្នកមានធនធានផ្តាច់មុខ (Capitaliste monopole) ។

វណ្ណៈអធន = ន. វណ្ណៈ ដែលក្រខ្សត់គ្មានទ្រព្យសម្បត្តិ ( Protétariat) ។

សំនួនវោហារ = ន. ពាក្យសំដី, លំនាំសេចក្តី, សំដីដ៏គ្រោះក្រាយ ។

គតិសាស្ត្រ = ន.វិជ្ជាខាងគំនិត, ដំណើរនៃគំនិត (Idiologie)

របនាសម្ពន្ធ = ន. ផ្នែកតាំងឡាយក្នុងសង្គម គឺវណ្ណៈផ្សេង ៗ ក្នុងសង្គម (Superstructure) ។

សតិបរិក្ខា = ន. ការផ្គត់ផ្គង់ខាងស្មារតី, ការអប់រំឲ្យមានប្រាជ្ញាស្មារតី ។

មូលដ្ឋាន = ន. ដើមកំណើត, ទីតាំងដំបូង (Base) ។

ភារកិច្ច = ន.កិច្ចការដែលត្រូវបំពេញខានពុំបាន (Devoir) ។

វេវចនស័ព្ទ

គំនិត-មនោគតិ ។

គាំទ្រ-គាំពារ-ការពារ ។

សទិសស័ព្ទ

**ធន-ធន់-ធុន**

ធន= (ម.ប.ធន់) ជាពាក្យបាលីនិងសំស្ក្រឹត គឺ ទ្រព្យ, សម្បត្តិ:
ទ្រព្យធន, ធនធាន, មូលធន ។

ធន់ = គុ. (ពាក្យខ្មែរសុទ្ធ) ដែលទ្រាំ, ដែលអំណត់: ធន់ទ្រាំ,
អត់ធន់ ... ។

ធុន = ន. (ជាពាក្យខ្មែរសុទ្ធ) បែប, យ៉ាង: ធុនធំ, ធុនតូច,
ធុនទាប, ធុនកណ្ដាល ... ។

អក្ខរាវិរុទ្ធ

សកលលោក ឬ សាកលលោក ។ មជ្ឈមដ្ឋាន ឬ
មជ្ឈដ្ឋាន ។

បដិបក្ខ ឬ ប្រតិបក្ស ។ វណ្ណ ឬ វណ្ណៈ ។

សំយោគសញ្ញា

ចំណាំ ក - សំយោគសញ្ញា សំអៀងសព្ទបាលីឬសំស្រ្កឹត ឲ្យ
មកជាភាសាខ្មែរ

ឧទាហរណ៍ :
ភ័យ-ក្ស័យ-ជ័យ-ជិតាស្រ័យ-ជិនាម័យ-ជលន័យន៍-ត្រ័យ
បរិ-ត្រ័យរត្ន - ទន្តម័យ - ទព្វិកភ័យ - ប្រេតវ័ន ភារិន្យ
បនិស្ស័យ-បុប្ផរិក័តិ ។ ល ។

១) សំយោគសញ្ញាប្រើលើពាក្យខ្មែរខ្លះ ដូចពាក្យ ៖
ទំព័រ-ញ័រ ។

ចំណាំ

បដិវត្តន៍-បដិវត្ត

ពាក្យទាំងពីរនេះ ជាសទ្ទានពាក្យ មានន័យ

ដូចគ្នា តែមួយជានាមស័ព្ទ មួយជាកិរិយាស័ព្ទ ។

បដិវត្តន៍ = ជានាមស័ព្ទ មានន័យថា: ការកែប្រែទម្រង់ចាស់ទៅជាថ្មី, ការបះបោរ ប្រឆាំងនឹងអំណាចណាមួយ ។

ឧទា. ការបដិវត្តន៍ របស់ប្រជាជនកាន់តែរីកដុះដាលឡើងរៀងរាល់ថ្ងៃ ប្រឆាំងនឹងការជ្រៀតជ្រែក ព្រមទាំងការបង្កើនសង្គ្រាមរបស់ពួកចក្រពត្តិនិយម និងពួកអាណានិគមនិយម

(Révolution) ។

បដិវត្ត = ជាកិរិយាស័ព្ទ ប្រឆាំងតបតនឹងអំណាចណាមួយ :

ប្រជាជននាំគ្នា បដិវត្ត គ្រប់ទិសដំបន់ ... ។

ប៉ុន្តែគេមិនសូវប្រើ ជាកិរិយាស័ព្ទទេ គឺប្រើ ប្រើតែជានាមស័ព្ទ ។ គេប្រើនិយាយថា : ប្រជាជននាំគ្នាធ្វើការបដិវត្តន៍ ... ។

## សំណួរ

១–ចូរពន្យល់ពាក្យៈ អក្សរសាស្ត្រប្រតិកិរិយា សតិបរិក្ខា, មូលធនិកផ្ដាច់មុខ, រចនាសម្ពន្ធ ។

២–ចូររកសទិសសព្ទនៃពាក្យៈ ធន ។

៣–ចូរស្រង់កិរិយាសព្ទ ទាំងឡាយក្នុងអត្ថបទនេះ ។

៤–ចូររកឧត្ដមគតិរបស់អ្នកនិពន្ធអត្ថបទនេះ ។

## ភារកិច្ចនៃសារពតិមាន

សារពត៌មាន មានភារកិច្ចខាងសំដែងនូវឆន្ទៈ នឹងយោបល់របស់ប្រជាជន ហើយពិសេសទៅទៀតសារពត៌មានបាន បំពងសំឡេងក្រុមបក្សពួកវណ្ណៈធំ ៗ ក្នុងសង្គម ៗ ហេតុនេះ សារពត៌មាន ដឹកនាំប្រជាជនទៅរកប្រយោជន៍ផ្សេង ៗ មានអាក្រក់នឹងល្អ ៗ សារពត៌មានបានបំពេញភារៈខាងលើទាំងពីរនេះ ជាដាច់ខាត ៗ

អ្នកសារពត៌មាន ត្រូវនិយាយ, សរសេរតែរឿង " សច្ចនិយម ,, ហើយដឹកនាំប្រជាជន នឹងប្រទេសជាតិឆ្ពោះទៅកាន់វឌ្ឍនភាព, សន្តិភាព, អធិបតេយភាព នឹងបូរណភាព ។ តែអ្នកសារពត៌មាន មិនមែនសុទ្ធតែមានសមានចិត្តល្អត្រឹមត្រូវទាំងអស់ទេ ព្រោះក្នុងសង្គមនិមួយ ៗ រមែងមានមនុស្សគិតដល់ផលប្រយោជន៍ផ្សេងគ្នា ៗ ហេតុនេះគេតែងឃើញសារពត៌មានបែង

ចែកចេញជាពីរពួក គឺសារពត៌មានអយុត្តិធម៌ និងសារពត៌មានយុត្តិធម៌ ។

សារពត៌មានអយុត្តិធម៌ ប្រវត្តិសាស្ត្រសកលបានចែងទុកជាគស្តាងមកថា សារពត៌មានជំពូកនេះច្រើនកើតឡើង ដោយរហស្សប្រាយរបស់ពួកអ្នកជិះជាន់គេ ពោលគឺពួកអាណានិគមនិងចក្រពត្តិនិយម ។ សារពត៌មានអយុត្តិធម៌ផ្សាយដំណឹងអ្វីមិនសូវពិតឡើយ គឺច្រើនតែបន្លំ បន្ទុះ ប្រមាថ មាក់ងាយការតាមតាររបស់ប្រជាជនហើយលើកដំកើងអួតបំផ្លើស តែអំពីក្រុមខ្លួន ។

សារពត៌មានយុត្តិធម៌ សារពត៌មាននេះ ផ្សាយតែរឿងពិតដែលកើតមានឡើងយ៉ាងប្រត្យក្សក្នុងសង្គម គឺបើឃើញប្រជាជនសប្បាយថាសប្បាយ.ឃើញវេទនាថាវេទនា, ឃើញល្អថាល្អ, ឃើញអាក្រក់ថាអាក្រក់, ហើយពន្យល់ហេតុផលវិបាកគ្រប់យ៉ាង

ដែលជាឧបសគ្គរបស់ប្រជាជន ព្រមទាំងជួយរកមធ្យោបាយដឹកនាំប្រជាជនក្នុងការដោះស្រាយឧបសគ្គ ដំបងែ្រឧបទ្រព របស់ខ្លួនផង ៗ ក្នុងរបបប្រជាធិបតេយ្យត្រឹមត្រូវ សារព័ត៌មានយុត្តិធម៌ ត្រូវតែបានទទួលការឧបត្ថម្ភយ៉ាងពេញទំហឹង ដោយសុទ្ធិដ្ឋិនិយមអំពីប្រជាជននឹងរដ្ឋាភិបាល មិនមែនត្រូវគំរាមកំហែងដោយទុទិដ្ឋិនិយមឡើយ ៗ

ឯសារព័ត៌មានអយុត្តិធម៌ ត្រូវតែទទួលនូវការផ្ដន្ទាទោសយ៉ាងធ្ងន់អំពីប្រជាជននឹងរដ្ឋាភិបាលប្រជាជន ដោយគ្មានយោគយល់លើកលែងជាដាច់ខាត ៗ

ពន្យល់ពាក្យ

ភារកិច្ច = (ម.ប.ភារៈកិច) ន. កិច្ចការដែលជាមុខងារត្រូវបំពេញ ៗ

សារព័ត៌មាន = កាសែត (journal) ៗ អ្នកសារព័ត៌មាន (Le journaliste) ៗ

សច្ចនិយម = ន. ការនិយមរឿងពិត, ការនិយាយតែអំពីរឿង
ពិត, សេចក្ដីពិត (Réalité) ។

វិឌ្ឍនភាព = (សូមមើលសេចក្ដីពន្យល់ខាងដើម) ។

អធិបតេយភាព = (សូមមើលសេចក្ដីពន្យល់ខាងដើម) ។

សមានចិត្ត = ន. សន្ដានចិត្ត ។

យុត្តិធម៌ = ន. សេចក្ដីត្រឹមត្រូវតាមច្បាប់, ឥតវៀចវេរ
(juste, justice) ។

អយុត្តិធម៌ = ន. សេចក្ដីមិនត្រឹមត្រូវ, សេចក្ដីវៀចវេរ
(Injuste, Injustice) ។

ប្រវត្តិសាស្ត្រសកល = ន. កំណត់រឿងរ៉ាវដែលកើតឡើងក្នុង
សកលលោក (Histoire du monde) ។

រហស្សុបាយ = (< រហស្ស=ការសម្ងាត់ + ឧបាយ) ន. ឧបាយ
សម្ងាត់, កិច្ចកលកំបាំង, ល្បិចសម្ងាត់ ។

បំផ្លើស = កិ. និយាយអួតលើសពីការពិត ។

ឧបសគ្គ = ន. ការជំទាស់, ការពារាំងផ្លូវដំណើរ (Obstacle)

ការឧបត្ថម្ភ = ន. ការទំនុកបំរុង, ការគាំទ្រ ។

ដោយសុទ្ធិដ្ឋិនិយម = ដោយគំនិតស្មោះត្រង់, ដោយស្មោះ

អស់ពីដួងចិត្ត, ដោយធម្មៈបរិសុទ្ធ ។

ដោយទុទ្ធិដ្ឋិនិយម=ដោយធម្មៈ,មិនបរិសុទ្ធ,ដោយវៀចវេរ ។

រដ្ឋាភិបាលប្រជាជន = រដ្ឋាភិបាល ដែលលើកដំកើនប្រជា

ជនជាធំ ។

ប្រែព ធស័ព

កាសែត - សារពត៌មាន ។

ធម្មៈ - បំណាន - បំណាន់ ។

## សទិសស័ព្ទ

### ពី – ពីរ

ពី = និ, សាន. អំពី, ខាង, ឯ: មកពីណា? ខាងពីណា,

មកពីធ្វើការ ។

ពីរ = ប.សំ ចំនួនមួយគួបគ្នា គឺ មួយ នឹង មួយ ( ២ ) ។

## អក្ខរាវិរុទ្ធ

ប្រវត្តិសាស្ត្រសកល ឬ ប្រវត្តិសាស្ត្រសាកល ។

### ពិត

ពាក្យនេះសរសេរបានតែមួយយ៉ាងគឺ " ពិត "

គ្មានពាក្យ " ពិទ ឬ ពិធ " ដូច្នេះទេ ។

ពាក្យ " ពិត " នេះមាន ២ ម៉ាត់គឺ ៖

ពិត = កិ. ប្រាប់, ឲ្យដំណឹង = ទូលពិត, ពិតដំណឹង ។

ពិត = កិ. យកខ្លួនផ្អែកប៉ះ ផ្ទប់ដោយប្រឹងពេញ

កម្លាំង = ពិតជិតជញ្ជាំង, គោ
ផ្អើលពិតក្ខការនេះ ។

ពិត = និ. មែន, ប្រាកដ, ទៀង : ពិតមែន ។

ពិត = ន. ឈ្មោះប្រដាប់សរសេរឬគូរ, ដក់ ។

## អំពីអស្តា “ ៎ ”

ចំណាំ = អស្តាប្រើបានតែលើ “ក” និង “ជ” ជានិបាតស័ព្ទ ។

ឧទាហរណ៍:

ព្រះជ៎មានបុណ្យ ។ ខ្ញុំក៏ទៅដែរ ។ល។ ល្អជ៎ប្រពៃ ។ ប៉ុន្តែអស្តាប្រើលើ “ ន ” និង “ ហ ” ដែរ ដែលជាពាក្យឧទានស័ព្ទ

ឧទាហរណ៍:

ឱហ៎! នុ៎ះ ហ៎! ន៎! ឃើញទេ!! ។

ចំណាំ

## សប្ប:-សប្បនិយម

ពាក្យ " សប្ប: " នេះបើប្រើដាច់តែឯង ឬប្រើនៅចុងសព្ទដទៃទៀត ត្រូវសរសេរជា " សប្ប: " គឺត្រូវមានយុគលពិន្ទុនៅពីក្រោយដូចជា: ខ្ញុំកាន់សប្ប:, ធម៌សប្ប:...។

បើប្រើនៅខាងដើមសព្ទដទៃ ត្រូវសរសេរជា « សប្ប » គឺត្រូវលុបយុគលពិន្ទុចេញដូចជា: សប្បធម៌, សប្បនិយម។

### សំនួរ

១ - ចូរពន្យល់ពាក្យ: សប្បនិយម, រហស្សបាយ, ដោយសុទិដ្ឋិនិយម, រដ្ឋាភិបាលប្រជាជន ។

២ - ចូរសម្អូនប្រយោគទី ១ នៃអត្ថបទនេះ ។

៣ - ចូររកវេវចនសព្ទនៃពាក្យ: សារពត៌មាន ។

៤-ហេតុអ្វីបានជាគេហៅថា រដ្ឋាភិបាលប្រជាជន? តើរដ្ឋាភិបាលមានប៉ុន្មានយ៉ាង? រដ្ឋាភិបាលអ្វីខ្លះ?

# ឯករាជ្យ

រដ្ឋ គឺ ជាទីប្រជុំជននៃមនុស្សពួកមួយ ដែលអាស្រ័យនៅរួមគ្នាក្នុងអាណាខេត្ត មានកំណត់ទៅ ដោយព្រំប្រទេស ខណ្ឌសីមា ៗ រដ្ឋមាន អង្គការនីតិបញ្ញត្តិ (រដ្ឋសភា) អង្គការ នីតិប្រតិបត្តិ (រដ្ឋាភិបាល), អង្គការ តុលាការ (ពួកចៅក្រម) សង្ខេបមក, រដ្ឋគឺជាអង្គការដែលកាន់ សិទ្ធិព្រមទាំងអំណាចនឹងកម្លាំង ដើម្បីគ្រប់គ្រងសង្គមនីមួយៗ តាមក្របខណ្ឌ នៃរបបឯណាមួយ ៗ

រដ្ឋឯករាជ មានការគ្រប់គ្រងរួមនៅក្នុង រដ្ឋាភិបាល តែមួយ ដោយរដ្ឋាភិបាលជាអ្នកស្ដែងនូវអំណាចអធិបតេយ្យ សម្រាប់កិច្ចការខាងក្នុងនឹងកិច្ចការខាងក្រៅ ៗ កិច្ចការទាំងឡាយទាំងអស់ក្នុងប្រទេស ដូចជា នយោបាយសេដ្ឋកិច្ច វប្បធម៌ កងទ័ពនគរបាល ។ល។ ត្រូវនៅក្រោមការដឹកនាំរបស់រដ្ឋាភិបាលជាតិ, ហៅថាមានអធិបតេយ្យ ក្នុងកិច្ចការខាងក្នុង ។

មាន សេរីភាព ក្នុងការទទួលស្គាល់ នឹងក្នុងការចុះហត្ថលេខា លើ សន្ធិសញ្ញា ជាមិត្តភាព ឬលើ កិច្ចសន្យា អ្វីផ្សេងទៀត រវាងប្រទេសទាំងឡាយក្នុងសកលលោក នឹងក្នុង ហៅថា អធិបតេយ្យក្នុងកិច្ចការខាងក្រៅ ។

គឹម-សែត

## ពន្យល់ពាក្យ

ឯករាជ្យ = ន. រាជ្យនៃស្ដេចតែមួយ ។ ដែលមានស្វេតច្ឆត្រតែមួយ គឺ មានក្សត្រទ្រង់រាជ្យតែមួយ (Indépendence)

អង្គការនីតិបញ្ញត្តិ = ន. សភាតំណាងរាស្ត្រ, សភាតែងច្បាប់សម្រាប់ស្រុក ។ គឺជាអង្គការបង្គាប់បញ្ជាឲ្យគេធ្វើតាមច្បាប់ដែលខ្លួនបានតែងឡើង ។

អង្គការនីតិប្រតិបត្តិ = ន. រដ្ឋាភិបាល ។ គណៈរដ្ឋមន្ត្រីដែល 14
ត្រូវអនុវត្តតាមច្បាប់ដែលសភាតំណាងរាស្ត្របានតែងឡើង ។

អង្គការតុលាការ = ន. ក្រុមចៅក្រម ។ គឺជាក្រសួងជំនុំជំរះ កាត់ក្ដីតាមច្បាប់ ។

លទ្ធិ = ន. របបគ្រប់គ្រងប្រទេស ។ លទ្ធិឯកាធិបតេយ្យ, លទ្ធិប្រជាធិបតេយ្យ, លទ្ធិសង្គមនិយម ។

រដ្ឋាភិបាល = ន. សមាសភាពនៃគណៈរដ្ឋមន្ត្រី ។ ក្រុមរដ្ឋមន្ត្រី ដែលជាអ្នកទទួលសេចក្ដីទុកចិត្ត ពីរដ្ឋសភាឲ្យ ពេញមុខដឹកនាំប្រទេសជាតិ ទៅកាន់សេចក្ដី ចំរើនរុងរឿង ។ (Gouvernement)

អធិបតេយ្យ = ន. អំណាច ។ មានអធិបតេយ្យ គឺ មានអំណាច គ្រប់គ្រាន់ឥតមានអ្នកណាមកត្រួតត្រា បង្គាប់ បញ្ជាឲ្យធ្វើតាមទៀតទេ ។

ក្របខណ្ឌ = ន. រង្វង់ច្បាប់ (Cadre) ។ ចូលក្របខណ្ឌ គឺមានសិទ្ធិពេញលេញក្នុងមុខការ ។

នយោបាយ = ន. មធ្យោបាយដ៏ល្អិត សម្រាប់ស្វែងរកនូវផលប្រយោជន៍គ្រប់បែបយ៉ាង (Politique)។

សេដ្ឋកិច្ច =ន. ប្រាក់កាស-ធនធាន-ទ្រព្យសម្បត្តិ ។ សេដ្ឋកិច្ចជាតិ គឺទ្រព្យសម្បត្តិរបស់ជាតិ (Economie)។

វប្បធម៌ = ន. មធ្យោបាយស្វែងរកនូវសោភ័ណនិងសុភមង្គលជូនមនុស្សជាតិ (Culture) ។

សេរីភាព = ន. អំណាចធ្វើការអ្វីៗ តាមទំនើងចិត្តកុំឲ្យតែប៉ះពាល់ដល់អំណាច(សិទ្ធិ)អ្នកដទៃ (Liberté)។

សន្ធិសញ្ញា = ន. ការសន្យាគ្នា, ការសន្យាជាមេត្រីនឹងគ្នា, សំបុត្រសន្យាគ្នាទៅវិញទៅមក ។ ហៅថា: សន្ធានសញ្ញាក៏បាន (Traité) ។

កិច្ចសន្យា = ន. ការដែលសន្យាគ្នា, ការយល់ព្រមព្រៀងគ្នានឹងធ្វើកិច្ចការអ្វីមួយ (Contrat) ។

អាណាំខេត្ត = ន. ខេត្តដែនដែលនៅក្នុងអំណាចការគ្រប់

គ្រងនៃមហាក្សត្រ ឬរដ្ឋបាលមួយ ៗ ៗ ប្រើ

ជា: អាណាខេត្តក៏បាន ៗ

ខណ្ឌសីមា = ន. ពាក្យប្រើក្នុងវិន័យពុទ្ធសាសនា ប៉ុន្តែនៅទី

នេះបានន័យថា: ព្រំប្រទល់ ៗ

សទិសស័ព្ទ

| រាប-រាជ-រាជ្យ |
|---|

រាប = ន. ជាពាក្យខ្មែរសុទ្ធ រាយស្មើ, ដក់ស្មើ, សាយរាយស្មើ :

ទឹករាបពេញស្រែ ៗ

រាជ = ន. (ជាពាក្យបាលី, សំស្ក្រឹតជារាជន៑) ស្តេច : ព្រះរាជា,

រាជធានី, រាជបុត្រ ៗ

រាជ្យ= (ម.ច.រាជ) ន. ជាពាក្យបាលី; សំស្ក្រឹតជា:រដ្ឋ ភាវៈជាព្រះ

រាជា, ការគ្រប់គ្រងផែនដី : សោយរាជ្យ

ដណ្តើមរាជ្យ... ៗ

រាជី = ន. ឈ្មោះត្រី មួយយ៉ាង : ត្រីរាជ ... ៗ

## អក្ខរាវិរុទ្ធ

### ព្យញ្ជនៈ "ផ" ក្នុងពាក្យពីរព្យាង្គ

ក្នុងពាក្យពីរព្យាង្គ ព្យញ្ជនៈ "ផ" គ្មានប្រើតម្រួតទេ គឺប្រើសុទ្ធតែព្យាង្គរាយ ។

ឧទាហរណ៍:

កំផែង, បំផុះ, កំផើម ។

ហេតុនេះមិនត្រូវសរសេរជា: កម្ផើម, បម្ផុះ, កម្ផែង យ៉ាងនេះទេ ។

### សំណួរ

១ – ចូរពន្យល់ពាក្យ : អង្គការនីតិបញ្ញត្តិ, រដ្ឋាភិបាល, នយោបាយ, ខណ្ឌសីមា ។

២ – ចូររកវេវចនសព្ទនៃពាក្យ : រដ្ឋ ។

៣ – ចូររកសទិសសព្ទនៃពាក្យ : អង់ ។

៤ – ចូររកឧត្តមគតិនៃអត្ថបទនេះ ។

# លទ្ធិប្រជាធិបតេយ្យ

ប្រជាធិបតេយ្យនេះ ជាអភិធេយ្យនៃលទ្ធិមួយ ប្រកបដោយសីលធម៌ បើកឲ្យប្រជាជនមានសិទ្ធិនិងសេរីភាពបរិបូណ៌ក្នុងការប្រើរបៀបគ្រប់គ្រងរដ្ឋដោយរដ្ឋសភា ។ រដ្ឋសភាគឺទីប្រជុំអ្នកដំណាងរាស្ត្រ ដែលរាស្ត្របោះឆ្នោតទុកចិត្តឲ្យធ្វើជាអ្នកទុកចិត្តឲ្យជាអ្នកស្ដីការរដ្ឋជំនួសខ្លួន យកមតិតំណាងរាស្ត្រភាគច្រើនជាប្រមាណរដ្ឋសភាជាអ្នកតែងច្បាប់គ្រប់យ៉ាង ។ វេលាធ្វើច្បាប់ណាមួយតែងមានញត្តិជាពាក្យសមាជិករដ្ឋសភាមួយរូប ថ្លែងដំរាបសភាតំណាងរាស្ត្រ ឲ្យជ្រាបទូទៅ បើរដ្ឋសភាមានមតិព្រមព្រៀងគ្នាជាឯកច្ឆន្ទ ឬភាគច្រើន ទើបទុកជាបានការ ។

មនុស្សក្នុងលោកនេះ តែងតែនិយមរាប់អានលទ្ធិប្រជាធិបតេយ្យ ព្រោះជាបិយលទ្ធិមួយ មានរបៀបគ្រប់គ្រងរដ្ឋដ៏វិសេសទាន់សម័យ ដែលធ្វើឲ្យមនុស្ស ឬពលរដ្ឋមានសេរីភាព សមភាព ភាតរភាពស្មើគ្នា ដូចគ្នាទាំងអស់ មិនឲ្យពលរដ្ឋប្រើ

អំណាចរំលោភលើសិទ្ធិនិងសេរីភាពរបស់គ្នានិងគ្នា ឲ្យគោរពសិទ្ធិនិងសេរីភាពរបស់គ្នាទៅវិញទៅមក ។

លទ្ធិប្រជាធិបតេយ្យ គឺអំណាចគ្រប់គ្រងប្រទេសលើពលរដ្ឋទូទៅ ឬនិងពោលម្យ៉ាងទៀតថា រដ្ឋាភិបាលប្រជាធិបតេយ្យ គឺរដ្ឋាភិបាលប្រជាជន ដើម្បីប្រជាជន ។

គៀង-សូត្រ

## ពន្យល់ពាក្យ

**លទ្ធិប្រជាធិបតេយ្យ** = (សូមមើលសេចក្តីពន្យល់ក្នុងអត្ថបទមុន ៗ) ។

**អធិបតេយ្យ** = ន. ឈ្មោះ, ពាក្យជាគ្រឿងសំគាល់ ។

**សីលធម៌** = ន. ច្បាប់ហ៊ឹកហ៊ឺនបរិយាឲ្យបានត្រឹមត្រូវ គឺមិនឲ្យប្រព្រឹត្តនូវអំពើអាក្រក់ដូចជារំលោភដំណើរជាន់គ្នា, ព្យាបាទគ្នា ដោយយកម្ចាំងទ្រព្យធនជាដើម (Moralité) ។

រដ្ឋសភា = ន. ទីប្រជុំនៃអ្នកតំណាងរាស្ត្រ, ក្រុមអ្នកតំណាងរាស្ត្រ (Assemblée nationale) ។

មតិ = ន. យោបល់, គោលបំណង, ទស្សនៈ (Opinion) ។

មតិសេរី (Libre opinion) ។

ញត្តិ = (ម.ប.ញ័តតិឬញ័ត) ន. លិខិតថ្លែងពីទឹកចិត្តរបស់ពលរដ្ឋម្នាក់ ឬ ច្រើននាក់ ក្នុងការបញ្ចេញនូវគោលបំណងណាមួយដែលខ្លួនត្រូវការ (Motion) ។

ឯកច្ឆន្ទ = ន. គោលបំណងតែមួយ, មតិដែលស្របគ្នា តែមួយ (Unanimité) ។

បិយលទ្ធិ = ន. លទ្ធិល្អប្រសើរក្រៃលែង, លទ្ធិដែលផ្តល់នូវគុណប្រយោជន៍ដល់ប្រជាជន ។

សមភាព = ន. ភាពស្មើគ្នា, ភាពស្មើមុខគ្នា (Egalité) ។

ភាតរភាព = ន. ភាពជាបងប្អូននឹងគ្នា, ការរាប់រកគ្នាជាបងប្អូន (Fraternité) ។

រដ្ឋាភិបាលប្រជាធិបតេយ្យ=រដ្ឋាភិបាលដែលអនុវត្តលទ្ធិប្រជាធិបតេយ្យដ៏ត្រឹមត្រូវ ។

វេវចនសព្ទ

រំលោភ បំពានបំពារ-សង្កត់សង្កិន-ជិះជាន់ ។

សទិសសព្ទ

ពល-ពុល

ពល =(ម.ថ ពល់) ន.ជាពាក្យបាលីនិងសំស្ក្រឹតគឺ កម្លាំង:ពលរដ្ឋ ៗ សេនា,ទាហាន,កងទ័ព : ក្សុំពល, លើកពល,កោណ្ឌាពល,ពលថ្មើរជើង . . . ។

ពល =(ម.ថ.ពល់) ន. ពួកជនពូជស្បូវ ដែលសម្រាប់ពួកអ្នកមានវណ្ណៈខ្ពស់ ប្រើការជាកម្លាំងផ្សេង ៗ ក្នុងសង្គមសក្តិភូមិ: ពលសេះ,ពលខែវ.. ។

ពុរ ឬ ពុល = គុ. ដែលជោជ្រាយសាច់ដោយប៉ះ,ទង្គិច,ប្រទាច់: ពុរសាច់,ផ្លែឈើពុរ... ។

ពុល = គុ. ដែលមានពិស អាចបណ្ដាលឲ្យរង៉ាប់រងើ, ឲ្យក្អួតចង្អោរ បណ្ដាលឲ្យស្លាប់ក៏មាន : ថ្នាំពុល, ផ្សិតពុល, ក្រៀងពុល ... ។

## ប៉ុន្មាន-ប្រមាណ

ប៉ុន្មាន = និ. ពាក្យសម្រាប់សួរឲ្យដឹងចំនួន : មនុស្សប៉ុន្មាននាក់? ថ្ងៃប៉ុន្មាន?

ប្រមាណ = ន. ការរាប់, ការស្ទង់, គ្នេរ, ស្មានចំនួន : ប្រមាណប្រហែលម៉ោង ៩, មិនស្គាល់ប្រមាណខ្លួន ... ។

### អក្ខរាវិរុទ្ធ

អតិថេយ្យ ឬ អតិថៃយ ។ សិរីភាព ឬ សេរីភាព ។
ដំណាង ឬ តំណាង ។ បិយលទ្ធិ ឬ ប្រិយលទ្ធិ ។

## ព្យញ្ជនៈ "ម" ក្នុងពាក្យប្រើនព្យាង្គ

បំណាំ = ក្នុងពាក្យប្រើនព្យាង្គ ព្យញ្ជនៈ "ម" ប្រើជាអក្សរពេញតួក៏បាន ផ្លាស់ជានិគ្គហិតវិញក៏បាន ។

ឧទាហរណ៍ :

បម្លាយឬបំឡាយ សម្លាញ់ឬសំឡាញ់ សម្លឬសំឡ ។

### សំនួរ

១–ចូរពន្យល់ពាក្យ : វជ្ជសកា , ឯកឆន្ទ , បរិយលទ្ធិ, វជ្ជាភិបាលប្រជាជន ។

២–ចូររកវេវចនសព្ទនៃពាក្យ : រំលោភ ។

៣ ចូរសម្គូនពាក្យ: ប្រជាធិបតេយ្យ (ក្នុង ឃ្លា ទី ១ នៃអត្ថបទនេះ) ។

៤ ចូរបញ្ជាក់ អំពីឧត្តមគតិ នៃអ្នកនិពន្ធអត្ថបទនេះ?

៥–អ្នកស្រឡាញ់លទ្ធិ ប្រជាធិបតេយ្យឬទេ? ព្រោះអ្វី ?

# បុណ្យពិពរណ៍ជាតិកសិកម្ម

ទោះជាការរស់នៅមានស្ថានភាពយ៉ាងណាក៏ដោយ, ប្រជាជាតិខ្មែររស់នៅបាន អាស្រ័យដោយផលិតផលនៃកសិកម្ម ។ កសិកម្មបូរាណ បានផ្តល់ឲ្យបុព្វបុរសខ្មែរនូវកម្លាំងពលំ ដែលអាចកសាងបានមហាប្រាសាទនគរវត្ត នឹងផ្តល់ឲ្យប្រជាជាតិខ្មែរបច្ចុប្បន្ន នូវពលសម្បទាគ្រប់គ្រាន់ អាចដណ្តើមយកបានឯករាជ្យខាងនយោបាយរបស់ខ្លួន ពីកណ្តាប់ដៃអាណានិគមនិយមមកវិញក្នុងពាក់កណ្តាលសតវត្សរ៍ទី ២០ នេះ ។

អំណើះតទៅ, បើកសិករខ្មែរបានទទួលដោយពេញលេញនូវផលិតផលកសិកម្មដែលខ្លួនបានធ្វើ, ដែលខ្លួនបាននាំគ្នាទៅបង្ហូរញើសខួបប្រាំងខួបវស្សា, នោះជីវភាពកសិករ នឹងបានធូរធាជាច្រើនកំរិតថែមទៀត ហើយប្រជាជាតិខ្មែរ នឹងបានឯករាជ្យខាងសេដ្ឋកិច្ចយ៉ាងរឹងប៉ឹង ។ ឫសគល់នៃសេដ្ឋកិច្ចរបស់យើងគឺកសិកម្មនេះឯង ។

កាលពីថ្ងៃ ២៥ កុម្ភៈ ១៩៦១ ពិពរណ៍កសិកម្មបានបើកឡើងក្នុងវាលព្រះមេរុនៃរាជធានីភ្នំពេញ ។ ប្រជាជនខ្មែរគ្រប់ជាន់ថ្នាក់បាននាំគ្នាមកទស្សនាយ៉ាងកុះករ ដើម្បីឲ្យបានស្គាល់នូវតម្លៃនៃការងាររបស់កសិករ ដែលជាអ្នកបង្កើតរាល់ទីជម្ម ជាតិការបសាបការ ដើម្បីចិញ្ចឹមមនុស្សប្រាំលាននាក់ក្នុងព្រះរាជអាណាចក្រ ។ ពិសេសទៅទៀត ក្នុងមណ្ឌលពិពរណ៍កសិកម្មនេះទស្សនិកជនជាច្រើនបាននាំគ្នាពិនិត្យមើលការប្រឡងប្រដែងរូបគោមគោដែលកសិករទាំងឡាយ ពេញចិត្តជាអនេកប្បការ ព្រោះគោនេះហើយដែលជាមូលដ្ឋាននៃកសិកម្មរបស់ខ្មែរ ។

ពន្យល់ពាក្យ

ពិពរណ៍ = ន. ការតាំងដើម្បីបង្ហាញវត្ថុផ្សេង ៗ (Exposition)

កសិកម្ម = ន. មុខរបរ ឬ កិច្ចការខាងធ្វើស្រែចំការ ឬ ដាំដំណាំផ្សេង ៗ (Agriculture) ។

ស្ថានភាព = ន. ការតាំងនៅ , ឋានៈដែលកំពុងរស់នៅ (Situation, position)

ផលិតផល = ន. ផលានុផលគ្រប់យ៉ាងដែលបានកើតឡើងពី

កិច្ចការណាមួយ (Produit) ។

ពលសម្បទា= ន. កម្លាំងដ៏បរិបូណ៌, កម្លាំងដែលអាចសម្រេច

បាននូវកិច្ចការណាមួយ ។

ជីវភាព =ន. ដំណើរនៃការរស់នៅ (Vie) កំរិតជីវភាព

(Niveau de vie) ។

សេដ្ឋកិច្ច =ន. មុខរបរដែលមានប្រយោជន៍សំខាន់បំផុតសម្រាប់

ប្រទេសនីមួយ ៗ (Economie) ។

រាជធានី = ន. ទីក្រុងធំរបស់ប្រទេសនីមួយ ៗ ដែលព្រះមហា

ក្សត្រគង់នៅ (Capitale) ។

ទស្សនា = កិ. គយគន់, សម្លឹងមើល, ពិនិត្យមើល ។

ធម្មជាតិកាចសាហាវ = ធម្មជាតិដែលធ្វើឲ្យមនុស្សមានការ

លំបាកដូចជាថ្ងៃក្តៅ, ភ្លៀង, ខ្យល់ជាដើម ។

មណ្ឌល = ន. ខ័ណ្ឌភូមិភាគស្រុក, ដំបន់ (Circonscription) ។

ទស្សនិកជន = ន. អ្នកពិនិត្យមើល ។

កសិករ = ន. អ្នកធ្វើស្រែចំការនិងដាំដំណាំផ្សេង ៗ (Agriculteur) ។

អនេកប្បការ = គុ. ដែលច្រើនក្រៃលែង, ដែលច្រើនលើសលុបពុំអាចនឹងពណ៌នាបាន ។

មូលដ្ឋាន = ន. ដើមកំណើត, ទីតាំងដំបូង (Base) ។

ឯករាជ្យខាងនយោបាយ = នយោបាយដែលបានទទួលនូវសេរីភាពគ្រប់គ្រាន់ដោយការគ្រប់គ្រងខ្លួនឯង គឺនយោបាយដែលមិននៅក្រោមអំណាចផ្ដាច់ការរបស់ជាតិដទៃ (Indépendance en matière politique) ។

វេវចនស័ព្ទ

ប្រជាការស្ត្រ-ប្រជាជន-ប្រជាពលរដ្ឋ ។

ឫសគល់-ដើមកំណើត-មូលដ្ឋាន ។

សទិសស័ព្ទ

| ទល់-ទុល-ទ្រ |
|---|

ទល់ = កិ. យាំងទុក្ខារ:, បស្ការ:, គឺយាំងការពារមិនឲ្យដើរឡប់: ទល់ពោះ, ទល់លាមក; ទល់ខ្យល់ . . . ។

ទល់ឬទ្រ = កិ. ទ្រពីក្រោមឲ្យមាំឲ្យរឹងប៉ឹងដោយចន្ទល់ : ទលផ្ទះ ។

ទល = កិ. ក្រិក្រ,ខ្វះខាត : ទលក្រ . . . ។

ទុល = កិ. ប៉ោងឡើង, ពោរកំពុងឡើង, ខ្ពស់ ហើបឡើង ចោះទុល ។

ទុល = ន. ពោះត្រីប្រាបត្រីពោ : ទុលត្រីប្រា ។

## ទស-ទស់-ទោះ

ទស់ = កិ. ពំនដោយឆ្នស់ : ឆស់ឆ្នស់, ឆស់ទឹកឲ្យចាល់ ។

ទស = (ម.ជ.ទស់) ន. ចំនួនដប់ (១០) ។ ទ្វារឆសមាស ។

ពាក្យដែលផ្ដើមឡើងពី ទស គឺ

ទសកណ្ឋ, ទសធម្ម, ទសបារមី, ទសពល, ទសពិធ,

ទសមុខ ។ល។

ទោះ = និ. ទុកជា, បើជា, បើទុកជា : ទោះល្អឬអាក្រក់ ។

អក្ខរាវិរុទ្ធ

សតវត្សឬសតវត្សរ៍ ។ បុរាណឬបូរាណ ។

តម្លៃឬតំឡៃ ឬដម្លៃ ។ ធម្មជាតឬធម្មជាតិ ។

រហាស់ ឬ រហ័ស ។ សំឡាញ់ ឬ សម្លាញ់

## នាមក្រិត-កិរិយាក្រិត

ពាក្យជាកិរិយាសព្ទឬជាគុណសព្ទ ដែលអាចបែកក្លាយ 15
ចេញទៅជានាមសព្ទដោយវិធីឥត្ថាស ហៅថាក្រិត្រ ។

ឧទាហរណ៍ : កំហឹង > ខឹង ។

កំហឹង គឺនាមក្រិត ខឹង គឺកិរិយាក្រិត

បំណាំ – កន្លែងពេលសរសេរតាមសូត្រ ត្រូវប្រុងប្រយ័ត្នចំពោះពាក្យដែលជានាមក្រិតឬកិរិយាក្រិតនេះ ។ បើពាក្យណាមួយមាន "រ" កន្ទុយកិរិយាសព្ទ ត្រូវតែមាន "រ" កន្ទុយនាមសព្ទដែរ។

ឧទាហរណ៍ :

| កិរិយាសព្ទ | នាមសព្ទ |
|---|---|
| កៀរ | កំនៀរ |
| គោរ | កំណោរ |
| គរ | គំនរ |
| គូរ | គំនូរ |
| បៀរ | បំនៀរ |
| ឈរ | ជំហរ |
| ដើរ | ដំណើរ |
| សួរ | សំនួរ ។ល។ |

### ចំណាំ

**កម្លាំងពលំ**

ពាក្យ កម្លាំង នឹងពលំ នេះមានន័យដូចគ្នា ប៉ុន្តែខ្មែរយើងច្រើនយកមកប្រើផ្សំគ្នាជា៖ កម្លាំងពលំ តែម្តង ។

### សំនួរ

១ – ចូរពន្យល់ពាក្យ ៖ ស្ថានភាព, ផលិតផល, ទស្សនិកជន, ឯករាជ្យខាងសេដ្ឋកិច្ច ។

២ – ចូរស្រង់នាមទាំងអស់ក្នុងអត្ថបទនេះ ។

៤ – ចូរសម្ពន្ធប្រយោគចុងក្រោយបង្អស់នៃអត្ថបទនេះ ។

៥ – ចូរអធិប្បាយអំពីផលប្រយោជន៍ ដែលកើតឡើងពីបុណ្យពិពរណ៍កសិកម្ម ។

# បុណ្យសិទ្ធិមនុស្ស

តាំងតាំងពីឆ្នាំ ១៩៥១ មក ប្រទេសកម្ពុជាបានទំលាប់ធ្វើបុណ្យរំលឹកដល់សេចក្ដីថ្លៃងជាសកលនូវសិទ្ធិមនុស្ស ។

តែយើងយល់ថា គួរណាស់តែប្រជាជនយើងទូទៅយល់ច្បាស់នូវដម្លៃនៃសិទ្ធិនេះដ៏ជ្រាលជ្រៅ ។

សិទ្ធិមនុស្ស មិនមែនកើតឡើងដោយងាយ ៗ ទេ ។ សិទ្ធិមនុស្សជាលទ្ធផលនៃការតស៊ូបង្ហូរ ឈាម ញើស ខាតបង់អាយុជីវិតមនុស្សរាប់លាននាក់ ។ សិទ្ធិមនុស្សជាលទ្ធផលនៃការតស៊ូយូរអង្វែងណាស់ ។ ប្រវត្តិសាស្ត្រមនុស្សជាតិសឲ្យឃើញថា តាំងពីបុរាណកាលមក មនុស្សយើងតែងតស៊ូទាមទារយកសិទ្ធិមនុស្សជាលំដាប់, មនុស្សយើងតែងចង់បានសេរីភាព, សមភាពជានិច្ច ។

នៅសម័យទាសភាពនិយម មនុស្សយើងឥតមានសិទ្ធិ, ឥតមានសេរីភាពសោះ ។ ក្នុងសម័យនោះម្ចាស់គេអាចលក់ដូរ, កាប់មនុស្សខ្សត់ខ្សោយបានតាមអំពើចិត្ត ។

នៅក្នុងសង្គមទុននិយម ពួកមេទុន, និងពួកចក្រពត្តិនិយម តែងធ្វើបាបបង្ខំឲ្យកម្មករនិងកសិករទន់ខ្សោយ ដែលជាជនភាគច្រើនឲ្យស្ថិតនៅក្រោមការជិះជាន់ញាំញីនៃជនភាគតិច, មហាជនតែងមានឋានៈអន់ខ្សោយជាទីបំផុត, ជនទាំងនោះគ្មានស្គាល់បំណេះវិជ្ជាបរិបូណ៌ទេ ព្រោះការរស់នៅមិនដែលបានគ្រប់គ្រាន់សោះ ។

ការខ្វះសិទ្ធិ និងសមភាព, សេរីភាពទាំងនេះបានបណ្តាលឲ្យការរំដើបរំជួលបដិវត្តន៍ កើតឡើងមិនចេះអស់មិនចេះហើយរឿងរហូតមក ។ ទាំងនេះជាសក្ខីភាពសឲ្យឃើញថាមនុស្សមែងស្រឡាញ់សេរីភាពជាងអ្វីទាំងអស់ ហើយសុខចិត្តស៊ូប្តូរផ្តាច់ដើម្បីប្រយុទ្ធដណ្តើមយកសេរីភាពដោយគ្មានគិតដល់ជីវិតន្តកាយសោះឡើយ ។

ពាក្យលំពាក្យ

បុណ្យសិទ្ធិមនុស្ស = ថ្ងៃបុណ្យដែលពល់ប្រទេសក្នុងសាកល

លោកបានធ្វើឡើងរៀងរាល់ឆ្នាំ ដើម្បីរំលឹកនូវការតស៊ូ នៃមនុស្សក្នុងការទាមទារយកសិទ្ធិរបស់ខ្លួន (Journée de Droit de l'Homme) ។

លទ្ធផល = ន. ផលដែលបានសម្រេច ក្រោយពីការបំពេញមុខការណាមួយ (Résultat) ។

បុរាណកាល = ន. ពេលដ៏យូរអង្វែងណាស់មកហើយ ។

សមភាព = ន. ភាពស្មើគ្នា, ភាពរស់នៅស្មើមុខគ្នា គឺគ្មានការរំលោភជិះជាន់គ្នា, គ្មានការប្រកាន់វណ្ណៈឋានៈរវាងគ្នានឹងគ្នា (Egalité) ។

សម័យទាសភាពនិយម = ពេលដែលពួកនាយទុននិយមទិញមនុស្សយកមកធ្វើជាខ្ញុំកញ្ជះបាតជើងរបស់ខ្លួន ។

សង្គមទុននិយម = ន. សង្គមដែលពួកសេដ្ឋីនិយមយកប្រាក់កាសរបស់ខ្លួនមកទិញផ្ដាច់នូវកម្លាំងកាយនិងកម្លាំងចិត្តរបស់កម្មករ - ពលករ ។

បក្រពត្តិនិយម = ( សូមមើលសេចក្ដីពន្យល់ខាងដើម ) ។

រំដួលបដិវត្តន៍ = ការបះបោរ ; ការកែទម្រង់ចាស់ជាថ្មីដែលបណ្ដាលឲ្យមានការរំដើបរំដួល ។

សេរីភាព = (សូមមើលសេចក្ដីពន្យល់ខាងដើម) ។

សក្ខីភាព = ន. ភាពជាសាក្សី, ជាកស្ដុតាង ។

ជីវិតក្ខយ = ន. ការវិនាសជីវិត, ហេតុដែលនាំឲ្យស្លាប់ ។

វេវចនស័ព្ទ

ជីវិតក្ខយ - មរណភាព - ស្លាប់ ។

បរិបូណ៌ - គ្រប់គ្រាន់ - សព្វគ្រប់ - ពោរពេញ ។

សទិសស័ព្ទ

## លាន - លៀន

លាន = ប. សំ. ចំនួន ១០ សែន ( ១.០០០.០០០ ) ។ ប្រាក់ ១ លាន; ត្រូវឆ្នោត ១ លាន ។

លាន = ន. ទីដីរាលរលីង : ទីលាន, លានបោកស្រូវ, ព្រះលាន ... ។

លៀន = កិ. លេចចេញក្រៅ : លៀនអណ្ដាត, ក្អែកលៀន, ដំបៅលៀន ... ។

ទន់ - ទុន

ទន់ = គុ. មិនមែនរឹង គឺ ដែលបត់បែន, ពត់ប្របាច់ ប្របល់បាន: ទន់ភ្លន់, ទន់ខ្សោយ, ដីកក់ទន់ ។

ទុន = ន. ប្រាក់ដើម ឬ របស់ដើមសម្រាប់យកទៅប្រើប្រាស់ឲ្យបានបំណេញចូលមកវិញ : ប្រាក់ទុន, ដើមទុន, អាត្មកាមេទុន ... ។

ក - ក៏ - ករ

ក = ន. ឈ្មោះអវយវៈ ដែលតពីក្បាលទៅស្មា : កដៃ, កជើង, កដប .. ។

ក = កិ. តាំងផ្ដើម, តាំងធ្វើ : កសាង, កកើត,

កបេតិយ, កភូមិ, កកែ, កឆ្នាំង ... ។

ក៏ = និ. ពាក្យជាសន្ធានសំរាប់និយាយតប្រយោគដោយឡែក

មានសំឡេងទី : ខ្ញុំក៏ទៅ, អ្នកក៏ទៅ ... ។

ករ = ន. ដៃ : លើកករប្រណម្យ ... ។

## អក្ខរាវិរុទ្ធ

ទម្លាប់ ឬ ទំលាប់ ។ ដឡៃ ឬ ដំឡៃ ឬ តំឡៃ ។

បុរាណកាល ឬ បូរាណកាល ។

## ពាក្យដែលត្រូវអានផ្ទួន អាមេណ្ឌិតសញ្ញា

ពាក្យដែលត្រូវអានផ្ទួន គឺអានពីរដង គេមិនសរសេរផ្ទួនគ្នាតែពាក្យដដែលនោះទេ គេត្រូវដាក់អាមេណ្ឌិតសញ្ញា ( ៗ ) (ខ្មែរយើងហៅលេខទោ) ទៅក្រោយពាក្យនោះវិញ ។

ឧទាហរណ៍

ធំ ៗ- ចាស់ ៗ- ក្មេង ៗ- ប្រុស ៗ- ស្រី ៗ- ទីទៃ ៗ-

ឯងត្រូវធ្វើឲ្យ ហើយ ៗ បន្តទៅទៀត – ។ល។ ...

ប៉ុន្តែកន្ទពាក្យបាលីដែលយើងប្រើសព្វថ្ងៃនេះ គេមិនដាក់

គាមេណ្ឌិតសញ្ញាខាងក្រោយដូចពាក្យខ្មែរទេ ។

ពាក្យទាំងនេះ គឺ ៖

១- នានា- ដំណើងនានាប្រទេស ។

២- គាថាគាថា ។ល។

សំណួរ

១– ចូរពន្យល់ពាក្យ : សទិ្ធមនុស្ស, ប្រវត្តិសាស្ត្រមនុស្ស ជាតិ, សម័យទាសភាពនិយម, ការរំដួលបដិវត្តន៍ ។

២– ចូររកវេវចនស័ព្ទនៃពាក្យគស៊ូ ។

៣- ចូរស្រង់គុណនាមទាំងអស់ក្នុងអត្ថបទនេះ ។

៤- ចូរសម្ពន្ធប្រយោគ : សិទ្ធិមនុស្សមិនមែនកើតឡើង ដោយងាយ ៗ ទេ ។

៥- អ្នកស្រឡាញ់សិទ្ធិមនុស្ស ឬ ទេ ? ព្រោះអ្វី ?

# មនុស្សធម៌

មនុស្សធម៌មានន័យថា ( មនុស្សត្រឹមត្រូវតាមច្បាប់ ) គឺមនុស្សប្រព្រឹត្តត្រឹមត្រូវតាមច្បាប់សម្រាប់មនុស្ស ដែលធម្មជាតិតម្រូវឲ្យមកស្រាប់ យ៉ាងហោចណាស់គឺអ្នកមនុស្សធម៌ត្រូវមានបសន្នចិត្ត ទទួលស្គាល់នឹងគោរព សិទ្ធិសារវន្តរបស់មនុស្សដែលបាតុភូតសង្គមសាកលបានផ្តល់ឲ្យហើយ កាលពីថ្ងៃ ១០ ធ្នូ ១៩៤៨ នៅទីក្រុងប៉ារីស ។ អ្នកមនុស្សធម៌; គ្រប់ អហោរាត្រ, ទោះគិតទោះនិយាយ ទោះធ្វើសព្វកិច្ចការអ្វី សុទ្ធតែសំដៅបំរើសង្គមមនុស្ស ពុំដែលប្រមាថកាតទានជន ឥស្សរិយឬគិតប្រវ័ញ្ចអញ្ញត្តបុគ្គល ណាម្នាក់ឡើយ ។ អ្នកមនុស្សធម៌ដែលបរិបូណ៌ហើយដោយ លជ្ឈីភាព មិនព្រមបណ្តោយឲ្យចិត្ត អន្យត្រិយសំដីអប្បាវ័ទ ញ៉ាំញ៉ីខ្លួនឯងទាល់តែសោះ ។ ជានិរន្តរ៍, ចិត្តគិតតែសម្មាទ្រឹស្តិ សំដីនិយាយតែ សម្មាវាទ អំពើធ្វើតែ សម្មាកម្ម,

នេះជាបឋមលក្ខណៈ ហើយចាំបាច់បំផុតរបស់អ្នកមនុស្សធម៌ក្នុងការបំរើសង្គមមនុស្ស ។ ផ្ទុយពីនេះវិញគឺ អមនុស្សធម៌; អ្នកអមនុស្សធម៌បើគិតៗតែបំផ្លាញគេ, បើនិយាយៗតែបោកបញ្ឆោតគេ , បើធ្វើៗតែអំពើជាន់កគេលើកលែងតែគ្រួសារខ្លួន , នេះជាបុព្វចរិតរបស់អមនុស្សធម៌ ។

ពិសេសបំផុត , ព្រោះតែការអាណិតអនាថ ដ៏ខ្លោចផ្សា បំពោះប្រជាជនដែលត្រូវអមនុស្សធម៌កទ្រឹសបុស្សា ស្វរជនបំភាន់ស្មារតីបំបិទសិទ្ធិសេរី បំផ្លាញសន្តិភាព បំផ្លាញសុភមង្គល , អ្នកមនុស្សធម៌ដេកសម្ងំសេពសុខម្នាក់ឯងមិនកើត វះវ៉ៃមអំពាវនាវស្រែកអាក្រោសបបួលគ្រប់ស្រទាប់អ្នករងគ្រោះទោះតិចច្រើន ឲ្យរហ័សរហួនក្រោកឡើងសាមគ្គីពួកដៃគ្នាជាសមិទ្ធិភាព ប្ដេជ្ញាតស៊ូមិនរញ្ញាក ពុះពារឧបសគ្គគ្រប់យ៉ាង ដើម្បីបុព្វហេតុសន្តិភាព ដើម្បីសិទ្ធិសេរីភាពបរិបូណ៌ ដើម្បី

ការងារអត្ថិរូប៍ ដើម្បីជីវភាពអត្ថិរម្យ នឹងសុភមង្គលដ៏ត្រចះ
ត្រចង់សុទ្ធសាធ ។

ពាក្យលំពាក្យ

មនុស្សធម៌ = ន. ធម៌ ដ៏ប្រពៃសម្រាប់មនុស្ស គឺការមិនជិះ
ជាន់មនុស្សផងគ្នា (Humanité) ។

បសន្នចិត្ត = ន. ចិត្តជ្រះថ្លា, ចិត្តល្អ ។

សិទ្ធិសារវន្ត = ន. សិទ្ធិមានខ្លឹមសារ, សិទ្ធិសំខាន់ ៗ,
សិទ្ធិចាំបាច់, សិទ្ធិខានមិនបាន ។

បាតុភូតសង្គម = ន. ហេតុកេតុអ្វី ដែលលេចធ្លោឡើង ។
បាតុភូតធម្មជាតិ ដូចជា : ភ្លៀងធ្លាក់ជាដើម ។
បាតុភូត សង្គមដូចជា ស្រុកអត់បាយ ជាដើម
(Phénomène) ។

អហោរាត្រ = ន. ថ្ងៃនឹងយប់ (២៤ម៉ោង) ។

អល្បវិទូ = ន. អ្នកគ្មានចំណេះវិជ្ជា, អ្នកមានចំណេះវិជ្ជាតិច, អ្នកមានចំណេះវិជ្ជាស្ដួចស្ដើង ។

អព្យត្តបុគ្គល = ន. បុគ្គលដែលមិនសូវឈ្លាសវៃ ។

លជ្ជីភាព = ន. ភាពអៀនខ្មាស ។

ចិត្តអធ្យតិរ្យ ន. ចិត្តអាក្រក់ឃោរឃៅក្រៃលែង ។ គេតែងនិយាយថានាយទុនជាមនុស្ស មានចិត្ត អធ្យ-តិរ្យ ។

សំដីអប្បាវិទ = ន. សំដីអួតអាង, គឺសំដីអួតអាងថាខ្លួនឯងគ្រាន់បើជាងអ្នកដទៃ ។

សម្មាទិដ្ឋិ = ន. ទិដ្ឋិត្រឹមត្រូវ, គតិត្រូវ, ក្បួនដឹកនាំត្រូវ, ពាក្យបង្ហាញផ្លូវត្រូវ ។

សម្មាវាទ = ន. ពាក្យពិត, ពាក្យត្រឹមត្រូវ ។

សុភមង្គល = មនុញ្ញផល ដែលជាទីគាប់ចិត្ត ក្រៃលែង, សេច

ក្តីសុខ, ការប្រាសចាកវៀង លំបាកវេទនា
ផ្សេងៗ (Bonheur) ។

ប្រវ័ញ្ច = កិ. លួច, បន្លំ, កែបំបាត់ ។ ឈ្មួញប្រវ័ញ្ច : ឈ្មួញរកស៊ីតាមរបៀបទុច្ចរិត ។

សម្មាកម្ម = ន. ការងារត្រូវ, អំពើត្រឹមត្រូវ ។

បឋមលក្ខណៈ = ន. លក្ខណៈដំបូង ។

បុព្វចរិត = ន. ចរិតដំបូង, ហេតុដំបូងនៃចរិយា ។

សិនិទ្ធភាព = ន. ភាពជាទីស្និទ្ធស្នាលក្រៃលែង ។

អភិវឌ្ឍ = ន. ការលូតលាស់ឆាប់, ការចំរើនលោតផ្លោះ ។

វេវចនស័ព្ទ

សកលលោក-ពិភពលោក-ផែនដី-វសុធា ។

សទិសស័ព្ទ

| ពារ - ពៀរ |
|---|

ពារ = កិ· (បាលីឬសំស្ក្រឹត វារ «ឃាត់,រាំង,ទទឹងទាស់» ប៉ះលើឬប៉ះ

ត្រូវតាំងស្រេច : ពាររបង, ដើរពារ កល់ឈើ ... ។ ពារលើគ្រោះកាប ប្រទះលើគ្រោះកាច ។ ការពារ ; ពាំង, ទប់ទល់ ។

ពារ = ន. ( បាលីឬសំស្ក្រឹតជា វារ: ) ថ្ងៃ ។ ពារពុធ គឺថ្ងៃពុធ ។

ពៀរ = ន. ( សំ. វៃរ, ម. វេរ) ចំណងចិត្តក្រោធដែលចង ដោយព្យាបាទបំរុងនឹងសងសឹកវិញ, ចំណង ជាសត្រូវ : ចងពៀរ, ស្រាយពៀរ ។

## លក្ស-ល័ខ-លក្សណ៍-លក្ខណ៍-លាក់

លក្ខលក្ស = (ម.ច.ល័ក.ខ:ឬ.ក្ស:) ន. ជាពាក្យបាលីឬសំស្ក្រឹត សេចក្ដីសំគាល់, ទីសំគាល់, គ្រឿងកំណត់ 16
ពប់ ... ។ លក្ខមូល = ដម្លៃ ១ សែន ។

លក្ខណ៍ ឬ លក្ស្មណ៍ = (ម.ជ.ល័ក) ន. លក្ខណៈ : មនុស្ស ខាតលក្ខណ៍, ស្រីគ្រប់លក្ស្មណ៍ ។

ល័ក្ខ ឬ ល័ខ = (ម.ជ.ឡាក់) សំស្ក្រឹតជា លក្តក, អលក្ត, លាក្ស បាលីជា លាខា, អលត្តក ) ជ័រខ្នះមានពណ៌ ផ្សេងៗ សម្រាប់ជ្រលក់ក្រណាត់, សូត្រ, អម្បោះជាដើម : ល័ក្ខខៀវ, ល័ក្ខក្រហម, ល័ក្ខជុំកាងជ័, កាកល័ក្ខ..។

លក្ស្មណៈ ឬ លក្ស្មណ៍ = ន. ឈ្មោះព្រះអនុជ នៃព្រះរាមក្នុង រឿងរាមកេរ្តិ៍ : ព្រះរាម ព្រះលក្ស្មណ៍ ។

លាក់ = កិ. ជាពាក្យខ្មែរសុទ្ធ ធ្វើឲ្យមានគន្ទាក់ : លាក់ឈើ ។ បិទបាំង , បំបាំង ឬ ទុកមិនឲ្យគេឃើញ : លាក់របស់, លាក់ខ្លួន, ចក្រពត្តិ លាក់ពុត ។

អក្ខរាវិរុទ្ធ

ធម្មជាតឬធម្មជាតិ ។ សម្ព័ន្ធឬសំព័ន្ធ ។

## អំពីអញ្ញត្រសព្ទ

គ្រប់តែភាសាតែងតែមានសព្ទដោយឡែក គឺសព្ទដែលអានខុសពីការអាន ដែលហៅថា "អញ្ញត្រសព្ទ" នោះជាធម្មតា ។

ក្នុងភាសាខ្មែរយើង ពាក្យអញ្ញត្រសព្ទ មានដូចតទៅ ៖

| | | | |
|---|---|---|---|
| អ្នក | អានថា | = | នាក់ |
| អញ | ,, | = | អាញ់ |
| សេចក្តី | ,, | = | សាចក្តី |
| ចេដ្ឋា | ,, | = | ដាច់ញ៉ា |
| ស្តេច | ,, | = | ស្តាច់ |
| សម្តេច | ,, | = | សំដាច់ |

ស្រេប អានថា = ស្រាប់

សម្រេប ,, = សម្រាប់

ហោង " = អ្ហង

ដ្បេះ " = ដ្បិះ

ដ្បោះ " = ដ្បោសប្តូដ្បុះ ។

សំណួរ

១ – ចូរពន្យល់ពាក្យ : សទ្ទិសាវន្ត, អព្យក្ត បុគ្គល, សម្មាទ្រឹស្តិ, សទិទ្ធភាព ។

២ – ចូររកវេវចនស័ព្ទនៃពាក្យ : ច្បាប់ ។

៣ – ចូររកសទិសស័ព្ទនៃពាក្យ : នោះ ។

៤ – ចូរពន្យល់ អំពីគោលបំណងរបស់អ្នកនិពន្ធក្នុងការសរសេរអត្ថបទនេះ ។

# វឌ្ឍនធម៌

សេចក្ដីចំរើនដោយទ្រព្យសម្បត្តិ ដោយចំណេះវិជ្ជា ឬដោយវត្ថុណាមួយ សុទ្ធតែជាឥដ្ឋារម្មណ៍ គឺអារម្មណ៍ជាទីប្រាថ្នា ជាទីពេញចិត្តរបស់ប្រជាជនទាំងអស់ក្នុងលោក ឥតមាននរណាម្នាក់ស្អប់ខ្ពើមបដិសេធចោលសេចក្ដីចំរើនឡើយ ។ ពាក្យថា "សេចក្ដីចំរើន" នេះ ត្រូវនឹងពាក្យបាលីថា "វឌ្ឍនធម៌ ឬ វុឌ្ឍិធម៌" ប្រែថា "សេចក្ដីចំរើន" ហេតុការណ៍ជាគ្រឿងចំរើន វត្ថុជាគ្រឿងលូតលាស់ផុះផាល ឬជាវត្ថុផ្សេងៗដែលមិនធ្លាប់មាន មិនធ្លាប់ឃើញ ហើយស្រាប់តែមានឡើង កើតឡើង ឃើញប្រាកដដែលអាចទាយបានថា "បុគ្គលអ្នកមានសេចក្ដីចំរើន ឬ ប្រទេសមានសេចក្ដីចំរើន" ។ ចំពោះបុគ្គលក្ដី ចំពោះប្រទេសក្ដី ដែលទើបតែមានសេចក្ដីចំរើនដោយភោគ-សម្ប័ទ មិនឈប់នៅនឹងដដែល ឬមិនឈរទ្រឹងគាំងនៅដដែលៗ គឺចេះតែលូតលាស់លឿនរីកឡើងៗ ហៅថា "វឌ្ឍនធម៌" ។

ពាក្យថា “វឌ្ឍនធម៌„ នេះ ជាពាក្យបាលីក៏ពិតមែន តែប្រជាជនជាតិខ្មែររបស់យើងក្តី អ្នកប្រទេសថៃក្តី តែងនិយមយកមកប្រើជាញឹកញយណាស់ហើយ ។ ពាក្យនេះឈ្មោះថាជាគ្រាមភាសា ដោយស៊ប់សួនណាស់ហើយ មួយទៀតពាក្យនេះ អ្នកប្រទេសដែលចេះបាលី តែងលើកដំកើងថាជាពាក្យប្រសើរខ្ពង់ខ្ពស់ថ្លៃថ្នូរជាទីបំផុត ។

ស្វរ-ឃាយ

## ពន្យល់ពាក្យ

វឌ្ឍនធម៌ = ( សូមមើលសេចក្តីពន្យល់ខាងដើម ) ។

ឥដ្ឋារម្មណ៍ = ( < ឥដ្ឋ + អារម្មណ៍ ) ន. អារម្មណ៍ដែលត្រូវចិត្ត, អារម្មណ៍ដែលត្រូវតាមបំណងរបស់ខ្លួន ។

បដិសេធចោល = ទាត់ចោល, លើកលែងចោល, បោះបង់ចោល, ឈប់យកជាការ ។

បុគ្គល = ន. មនុស្ស ។

ប្រជាជន = ន. ប្រជាពលរដ្ឋ, រាស្ត្រ (Peuple) ។

ភោគសម្បទ៍ = ន ទ្រព្យសម្បត្តិ, ការបរិបូណ៌ដោយទ្រព្យធន ។

គ្រាមភាសា = ន. ភាសាអ្នកស្រុក ។

វេវចនស័ព្ទ

ប្រទេស-ស្រុក-ដែន-នគរ ។

ទ្រព្យសម្បត្តិ-ទ្រព្យធន-ធនធាន ។

សទិសស័ព្ទ

| ដុស-ដុះ |
|---|

ដុស = កិ. ខាត់, រំលីង, ពួត, ជំរះដោយសាប៊ូ : ដុសក្អែល, ដុសខោអាវ ។ ដុសខាត់ : ខាត់ជំរះឲ្យស្អាត, ឲ្យរលីង ។

ដុះ = កិ. ចាប់កើត, កកើតមានពន្លក, មានដើមឡើង : ស្រូវដុះ, ពោតដុះ ។ ចំរើនឡើង : ដីដុះ ។

ដុះដាល = កិ. លូតលាស់, ចំរើនឡើង ។

## ចូរ-ចូល

ចូរ = កិ. ទុ. ពាក្យបង្គាប់ឲ្យប្រព្រឹត្តតាម, ឲ្យព្រមតាម : ចូរខំរៀន, ចូរខំធ្វើការ ។

ចូល = កិ. ដើរពីក្រៅទៅក្នុង : ចូលក្នុងផ្ទះ, ចូលក្នុងរោងល្ខោន ។

មកពីខាងអាយទៅកាន់ឯខាងនាយ ឬ មកពីខាងនាយទៅកាន់ខាងអាយ : ចូលចាប់, ចូលលុក, ទឹកចូលព្រែក ... ។

លះបង់ពីម្ខាងទៅរកម្ខាង: ចូលបក្សពួកនេះ, ចូលក្រុមនោះ ។

ប្ដូរខ្លួនជាអ្នកជឿស៊ប់តាមសាសនា : ចូលពុទ្ធសាសនា, ចូលសាសន៍ពុទ្ធ-រ័តន៍ ... ។

ចូរកុំច្រឡំនឹងពាក្យមួយម៉ាត់ទៀតគឺ :

ប្ញូរ = កិ. ធ្វើឲ្យមានស្នាមដោយចូត ឬ គូសនឹងដែក ឬ នឹងក្រ-
បកជាដើម ។ ពាក្យនេះត្រូវអានថា "បូរ" មិនមែន
អានថា "បូល" ដូចពាក្យ "បូរ" ខាងលើទេ ។

អត្ថាភិវុឌ្ឍ

វឌ្ឍនធម៌ ឬ វុឌ្ឍិធម៌ ។ ជម្ពើន ឬ ដំកើន ។

## អំពីអក្សរជើងជើងទាំងឡាយ

អក្សរជើងជើងទាំងឡាយមានដូចតទៅ៖

ក្ង ក្ដ ក្ប ក្ព ក្ញ ក្ម ក្រ ក្វ ក្ជ ក្យ ក្អ - ខ្ច ខ្ស

ខ្ល ខ្ដ ខ្ប ខ្ព ខ្ទ ខ្ម ខ្ញ ខ្វ ខ្ជ ខ្យ - គ្ព គ្ម គ្រ គ្ង -

ឃ្ល ឃ្ព ឃ្ម ឃ្វ ឃ្ង - ប្ញ ប្យ ប្រ ឆ្ក ឆ្គ ឆ្ង ឆ្ដ

ឆ្ព ឆ្ទ ឆ្ម ឆ្វ ឆ្ង ឆ្អ ជ្រ ជ្ង - ឈ្ង ឈ្ព ឈ្ម

ឈ្វ ឈ្ង - ណ្ហ - ត្ព ត្ញ ត្ម ត្រ ត្វ ត្ង ត្អ -- ថ្ក

ថ្គ ថ្ង ថ្ន ថ្ត ថ្ម ថ្ល ថ្វ – ទ្រ ទ្វ – ធ្ង ធ្ន ធ្ម ធ្យ ធ្ល
ធ្វ – ន្រ – ប្ដ ប្រ ប្ល – ផ្ក ផ្គ ផ្ង ផ្ច ផ្ញ ផ្ដ ផ្ទ ផ្ន
ផ្ល ផ្យ ផ្ស – ព្ន ព្យ ព្រ ព្ល ព្ស – ភ្ង ភ្ជ ភ្ញ ភ្ន ភ្រ
ភ្ល ម្ក ម្ខ ម៉្ង ម្ច ម្ឆ ម៉្ញ ម្ដ ម្ទ ម្ន ម៉្យ ម្រ ម្វ ម៉្ល ម្ប
ម្ហ ម្អ – ល្ក ល្គ ល្ង ល្ឈ ល្ត ល្ម ល្វ ល្ហ ល្អ –
ស្ក ស្គ ស្ញ ស្ដ ស្ដ្រ ស្ណ ស្ទ ស្ន ស៊្ប ស្ប ស្ត
ស្ម ស្យ ស្រ ស្ល ស្វ ស្អ - ហ្ន ហ្ម ហ្រ ហ្ល ហ្វ

## សំណួរ

១– ចូរពន្យល់ពាក្យ : ឥដ្ឋារម្មណ៍, គ្រាមភាសា, ភោគសម្បទ, បដិសេធ ។

២– ចូររកវេវចនស័ព្ទនៃពាក្យ : វឌ្ឍនធម៌ ។

៣– ចូរសម្ពន្ធប្រយោគទី ១ នៃអត្ថបទនេះ ។

៤– ចូរស្រង់នាមស័ព្ទទាំងអស់ក្នុងអត្ថបទនេះ ។

# សង្គហធម៌

ក្នុងលោកយើងនេះ, មនុស្សយើងនៅត្រមង់ត្រមោចកណ្ដែងកណ្ដោចទោលតែឯកឯងមិនបានទេ, ត្រូវតែមានមិត្តភក្ដិជួយទុក្ខធុរៈគ្នាទៅវិញទៅមក ទើបបានសេចក្ដីសុខនិរទុក្ខនិរភ័យ ប្រាសចាកឧបទ្រពចង្រៃអពមង្គលគ្រប់ប្រការ ។ ការកៀរគរប្រមូលផ្ដុំឃុំមនុស្សជាតិ ឲ្យព្រមព្រៀងមូលមិត្តសាមគ្គីស្រុះស្រួលអើកអើនទឹងគ្នា មានអធ្យាស្រ័យស្របគ្នាឥតរង្កៀស, អ្នកប្រាជ្ញមានគំនិតឈ្លាសវៃបានសំដែងថា ត្រូវធ្វើតាមគន្លងធម៌ដ៏ឧត្ដមសមតាមព្រះបរមពុទ្ធោវាទនៃព្រះសិទ្ធាថ៌គោតមដែលទ្រង់សម្ដែងប្រោសមាណពព្រាហ្មណបុត្ត ក្នុងគម្ពីរសុត្តន្តបិដក ព្រោះទ្រង់ចង់អប់រំពុទ្ធសាសនិក ទាំងបព្វជិត ទាំងគ្រហស្ថ ឲ្យមានសោមនស្សចេតនាប្រតិបត្តិជាធម៌ ញុំាងសត្វឲ្យមានសមានបួន ស្មោះស្មានសាទររាប់រកគ្នា ដោយស្មោះអស់ពីចិត្តឥតកលមាយា មិនប្រមាទពាធជនគ្នា ដោយអំពើទុច្ចរិតផ្សេង ៗ ។

ព្រោះហេតុនោះ, សង្គហធម៌ហ្នឹងឯង ទើបឈ្មោះថាជាបវេណីធម៌សំរាប់ប្រជាករសង្គ្រោះស្រោចស្រង់ យឹតយោងគ្នាទៅវិញទៅមក ដូចជា មាតាបិតានឹងបុត្តធីតា; គ្រូបាធ្យាយនឹងសិស្សគណ, ប្រពន្ធនឹងប្ដី, បព្វជិតនឹងគ្រហស្ថជាដើម សុទ្ធតែត្រូវមានការឧបត្ថម្ភទំនុកបំរុងគ្នា តាមសមគួរដល់កិច្ចធុរៈ នឹងកាលៈទេសៈ ។

ពួកជនអ្នកបានបំពេញនូវសង្គហកម្ម ជួយឧបត្ថម្ភគ្នាបាននាមប្រាកដជាបុព្វការី ទោះបីជាបុរសឬស្ត្រីឈ្មោះថាជាអ្នកសមគួរ នឹងទទួលនូវសក្ការៈ នឹងគ្រឿងបូជារបស់កតញ្ញូកតវេទិតជនព្រមទាំងជាអ្នកគួរដល់ការរាប់អានលើកតម្កើងគុណឋានៈដ៏ខ្ពង់ខ្ពស់មានកិត្តិសព្ទពីរោះពីសាផ្សព្វផ្សាយទូទៅកាន់ទិសានុទិស ។

សង្គហធម៌ទាំង ៤ ប្រការគឺ ទានៈ, បិយវាចា, អត្ថចរិយានឹងសមានត្តតា អ្នកប្រាជ្ញប្រៀបឧបមាថា ដូចជាប្រែកទប់នៃរទេះកាលបើធម៌ទាំងឡាយនេះ មានក្នុងលោកដរាបណា ដរាបនោះ

មនុស្សនិករទើបឈ្មោះថាប្រព្រឹត្តទៅបាន ឥតមានទោសបានអ្វីឡើយ ។

វិញ្ញាសាប្រឡងចេញពី ពុទ្ធិកបឋមសិក្សា (១២.១១.៥៩)

## ពន្យល់ពាក្យ

សង្គហធម៌ = ន. ធម៌សង្គ្រោះ, ការជួយសង្គ្រោះគ្នា ។

ត្រមង់ត្រមោប = ន. តែម្នាក់ឯង, តែមួយគត់ ។

ផ្ទុរៈ = ន. ការរស់ ។

និរទុក្ខ = គុ. ដែលឥតទុក្ខព្រួយ, ដែលប្រាសចាកនូវសេចក្តីទុក្ខព្រួយ ។

ឧបទ្រព = ន. ចង្រៃ, គ្រោះកាច, គ្រោះកាក្រក់, ហេតុកាក្រក់, អពមង្គល ។

អពមង្គល = ន. ការមិនបានប្រកបដោយសេចក្តីសុខ, ការជួបប្រទះនឹងសេចក្តីទុក្ខ (Malheur) ។

រអឹករអឺន = គុ. ដែលត្រូវមាត់, ត្រូវពាក្យគ្នា ។

អធ្យាស្រ័យ = ន. បំណង, បំណុចចិត្ត ។

ពុទ្ធវាទ = ន. ពាក្យទូន្មានរបស់ព្រះពុទ្ធ ។

សិទ្ធាបិ = ន. អ្នកមានបំណងសម្រេចហើយ គឺជាព្រះនាម
របស់ព្រះពុទ្ធ ។

មាណព = ន. ប្រុសកម្លោះ ។

អប់រំ = កិ. ហាត់ចិត្ត, បង្វឹកចិត្ត, ណែនាំចិត្ត ។

បព្វជិត = ន. អ្នកបួស, ព្រះសង្ឃ ។

គ្រហស្ថ = ន. អ្នកមិនបួស, ឧបាសក ។

សមានច្ឆន្ទ = ន. បំណងស្មើគ្នា, អ្នកដែលមានបំណងស្មើ
គ្នា ។

ប្រមាទពាធជិត្ន = ប្រមាទដល់អាយុជីវិត, ការប៉ុនប៉ងបំផ្លាញ
អាយុជីវិត ។

បវេណិធម៌ = ន. ធម៌ដែលជាទំនៀម ។

បុព្វការី = ន. អ្នកមានគុណដំបូង គឺមាតាបិតា ។

កតញ្ញូកតវេទិតជន = អ្នកដឹងគុណចំពោះមនុស្ស ដែលមានគុណលើខ្លួន ។

បិយវាចា = ន. ពាក្យសំដីល្អ ។

អត្ថចរិយា = ន. ចរិយាល្អ, ថ្លៃថ្នូរ, ត្រឹមត្រូវ ។

វិទ្ទំសបាន = ន. ការក្ដៅក្រហាយ, ដំណើរមោះហ្មង, ការទាស់ទែងខ្វែងគំនិតគ្នា ។

វេវចនស័ព្ទ

តែលតោល-ត្រមង់ត្រមោច-កណ្ដោច-កណ្ដែន ។

ឧត្តម-ខ្ពង់ខ្ពស់-ថ្លៃថ្នូរ ។

## សទិសស័ព្ទ

**ទុក - ទុក្ខ**

ទុក = កិ. ដាក់វត្ថុអ្វីក្នុងទីណាមួយដើម្បីឲ្យគង់នៅ ឬ រក្សាអ្វី ៗ ដើម្បីឲ្យគង់ : ទុកទ្រព្យ ។ បំរុងឲ្យ, ផ្គង់ឲ្យ : ទុកប្រាក់បំរុងឲ្យ ។

ទុកចិត្ត = កិ. ភ្ជាប់សេចក្ដីសង្ឃឹមទៅលើអ្នកឯណាមួយ : ខ្ញុំទុកចិត្តអ្នក ។

ទុកជា = និ. ទោះជា, ទោះបើ, សូម្បី, ទោះបីបើ : ទុកជាលំបាកយ៉ាងណា ក៏យើងត្រូវតែពុះពារ . . ។

ទុក្ខ (ម.ព.ទុក) (ជាពាក្យបាលី, សំស្ក្រឹតជា ទុះខ) និ. សេចក្ដីព្រួយលំបាក (កាយនិងចិត្ត) : កើតទុក្ខ, ទុក្ខសោក, ទុក្ខព្រួយ ព្រោះអត់ឃ្លាន ... ។

ទុក្ខក្ខន្ធ = ន. គំនរទុក្ខ, កងទុក្ខ. ទីប្រជុំនៃសេចក្ដីទុក្ខគ្រប់យ៉ាង ។

ទុក្ខនិរោធ = ន. សេចក្ដីរលត់ទុក្ខ, ទីរលត់ទុក្ខ ។

ទុក្ខបរិញ្ញា = ន. សេចក្ដីកំណត់ដឹងនូវទុក្ខ, ការកំណត់បានថាជាទុក្ខ ; ប្រាជ្ញាដែលសំគាល់យល់ថា ជាទុក្ខ ។ល។

## កល-កល់-កលហ

កល = (មថ.កល់) ឧបាយយ៉ាងល្អិត, ល្បិច : ឧបាយកល, ចាញ់កលគេ ។

កល់ = កិ. ទ្រពីក្រោម, សែមពីក្រោម ដើម្បីឲ្យស្មើ មិនឲ្យលៀន ឬ ដើម្បីឲ្យហើបខ្ពស់ឡើង : កល់ជើងតុ... ។ 17

កលហ = ន. (ជាពាក្យបាលីឬសំស្ក្រឹត) ជម្លោះ : កើតមាន

កាលហាធិជ័ន្នា គឺ កើតមានជម្លោះនឹង

គ្នា ។

ចូរកុំច្រឡំនឹងពាក្យមួយម៉ាត់ទៀតគឺ :

កល្ប = ន. កាលដែលតាំងនៅយូរអង្វែង ។ ពាក្យនេះត្រូវអានថា

"កាល់" មិនមែនអានថា "កល់" ទេ ។

អត្ថាភិវុទ្ធិ

សម្តែង ឬ សំដែង ។ សម្រាប់ ឬ សំរាប់ ។

បវេណី ឬ ប្រពៃណី ។ តម្កើង ឬ តំកើង ឬ ដម្កើង-

ឬ ដំកើង ។

## ស្រះពិសេសដែលប្រើជាអញ្ញត្រស័ព្ទ

ស្រះពិសេសដែលប្រើជាអញ្ញត្រស័ព្ទមាន ១១ តួគឺ ៖

ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ ឳ

ស្រះពិសេសមិនមែនប្រើបានក្នុងពាក្យទូទៅឡើយ វៀរ

លែងតែពាក្យខ្លះ ៗ ដែលត្រូវប្រើប៉ុណ្ណោះ ។

ខាងក្រោមនេះយើងលើកយកពាក្យខ្លះ ដែលធ្លាប់ប្រើជានិច្ចរាល់ថ្ងៃ មកឲ្យសិស្សរៀនសំគាល់ចំណាំទុក ។

## ស្រៈ " ឥ " អានថាអិ៖

ឥច្ឆា - ឥដ្ឋាម្ភរណ៍ - ឥត្ថី - ឥធលោក - ឥសី - ឥស្សរិយ ឥទ្ធិ ឥទ្ធានុភាព - ឥណ ។ល។

## ស្រៈ " ឥ " អានថាអិ៖

ឥណ្ឌូចិន-ឥន្ទធនូ-ឥន្ទជិត-ឥណ្ឌៀ-ឥត-ឥន្ទ្រី ឥរិយាបថ ។

## ស្រៈ " ឥ " អានថាអី៖

ឥឡូវ - ឥឡូវនេះ - ឥស្សូរ ។

## សំណួរ

១– ចូរពន្យល់ពាក្យ : សង្គហធម៌, និរទុក្ខ, សមានចិត្ត, កតញ្ញូកតវេទិតជន ។

២– ចូររកវេវចនស័ព្ទនៃពាក្យ : អពមង្គល ។

៣– ចូររកឧត្តមគតិនៃអត្ថបទនេះ ។

# ស្រុកកូសាំងស៊ីន

ស្រុកកូសាំងស៊ីនជារដ្ឋមួយ ស្ថិតនៅទក្ខិណទិសនៃសហ-រដ្ឋឥណ្ឌូចិន ដែលជារដ្ឋមួយរបស់ខ្មែរកាលពីអតីតកាល ។ រដ្ឋនេះខ្មែរយើងធ្លាប់ហៅថា « កម្ពុជាក្រោម ឬ កម្ពុជាលិចទឹក » ពីព្រោះតាមអ្នកប្រវត្តិសាស្ត្រថា : ជារដ្ឋមួយទំនាបហើយធ្វើរបរស្រែបានផលស្រូវជាអនេកអនន្ត ។ ដំណាំស្រូវ ជាផលិតផលរបស់រដ្ឋនេះ ។ រដ្ឋនេះ, ធ្លាក់ទៅជាអាណានិគមនៃបរជាតិចំនួនច្រើនសតវត្សណាស់ហើយ គឺតាំងពីរជ្ជកាលព្រះបាទជ័យជេដ្ឋាទី ២ ព្រះចៅក្រុងកម្ពុជា គ.ស. ១៦២០ ។ ក្សត្រនេះទ្រង់សព្វព្រះរាជ-ហឫទ័យ នឹងក្សត្រីស្តេចកោជី (យួន) ដែលប្រហែលព្រះនាងមានព្រះរូបឆោម នឹងទ្រង់ជាស្ត្រីប្រកបដោយបញ្ចពិធកល្យាណី គួរជាទីប្រិមប្រិយនៃព្រះមហាក្សត្រខ្មែរ នាងល្អប្រៀបដូចជាទន់សុវណ្ណផ្កាលាឬ? តាំងអំពីនោះមក, ជាតិកោជី ដែលជាជាតិធ្លាប់សឹកសង្គ្រាមដែរ មានអំណាចនឹងសេរីភាពមកស្ថិតតាំងទីលំនៅ

ប្រកបដោយអាជីវប្បវត្តិដោយសន្តិភាពនៅកូសាំងស៊ីន រដ្ឋច្រើនកុះករនៅរាជធានីនគរនេះ គឺព្រៃនគរ ។

កូសាំងស៊ីនរដ្ឋ ជារដ្ឋមួយស្តុកស្តម្ភគម្ភីរភាពដោយវត្ថុធម្មជាតិ, ជាកែវមណីដ៏មានរស្មីនៅបូព៌ានៃអាស៊ីទ្វីប, ជាជ្រុកស្រូវដែលនាំចេញមិនចេះរលស់បីដូចជាទឹកនព្វមហាសមុទ្រដងមិនរីងឬស្រកស្រុត ដើម្បីចិញ្ចឹមមនុស្សក្នុងលោក ។ ដូច្នេះ, ស្រុកកូសាំងស៊ីន ទុកជាកម្លាំងនៃផ្លូវសេដ្ឋកិច្ចនៃពិភពលោក ដែលមានរាជធានីព្រៃនគរ ជាកំពង់ជំនួញយ៉ាងឯកនៅបូព៌ាប្រទេស ។

គៀង-ស្វត្រ

## ពន្យល់ពាក្យ

ទក្ខិណទិស = ន. ទិសខាងស្តាំ គឺទិសខាងត្បូង ។

សហរដ្ឋ = ន. រដ្ឋច្រើនដែលរួមគ្នាតែមួយ (Etats Unis) ។

អ្នកប្រវត្តិសាស្ត្រ = ន. អ្នកកត់ត្រារឿងរ៉ាវ របស់ប្រទេស (Historien) ។

អនេកអគ្ឃ = គុ. ច្រើនលើសលុប, ច្រើនសំបើម, ច្រើនឥតគណនា, ច្រើនកាត់ថ្លៃពុំបាន ។

ផលិតផល = ន. ផលានុផល, ផលដែលកើតឡើង ពីផលិតកម្ម (Produit) ។

បរជាតិ = ន. ជាតិដទៃ, ជាតិដែលមិនមែនជាជាតិយើង ។

រជ្ជកាល = ន. ពេលដែលព្រះមហាក្សត្រអង្គនីមួយ ៗ គ្រងរាជ្យ (Règne) ។

បញ្ចពិធកល្យាណី = ន. ស្រីដែលមានលំអ ៥ យ៉ាងគឺលំអសក់, លំអបបូរមាត់, លំអធ្មេញ, លំអសម្បុរ, លំអវ័យ ។

ប្រិមប្រិយ = គុ. ដែលគួរឲ្យស្រឡាញ់, ដែលជាទីស្រឡាញ់, ដែលជាទីពេញចិត្ត ។

សុវណ្ណផ្កាលា = ( < សុវណ្ណ: មាស + ផ្កាលា: ពន្លឺព្រោងព្រាត )

ន. ពន្លឺដែលភ្លឺព្រោងព្រាតដូចជាមាស ។

អាជីវប្បវត្តិ = ន. ដំណើរប្រព្រឹត្តទៅនៃជីវិត ឬ មុខរបរសម្រាប់

ចិញ្ចឹមជីវិត ។

រាជធានី = ន. ទីក្រុងធំ ដែលព្រះមហាក្សត្រ ទ្រង់គង់នៅ

(Capitale) ។

សុកសុម្ភ = គុ. ដែលម៉ាំមួន, ដែលរឹងប៉ឹង ។

គម្ពីរភាព = ន. ភាពជ្រាលជ្រៅ, ភាពដ៏ម៉ាំមួន ។

មណី = ន. កែវ ។

រស្មី = ន. ពន្លឺ ។

ចតុមហាសមុទ្រ ( < ចតុ = ប្រាំបួន + មហា: ធំ + សមុទ្រ ) ន.

សមុទ្រធំៗ ទាំងប្រាំបួន ។

បូព៌ាប្រទេស = ន. ប្រទេសប៉ែកខាងកើត ។

វេវចនស័ព្ទ

សមុទ្ទ-សាគរ-ជលសារ ។

ស្តេច-ក្សត្រ-ព្រះរាជា-ព្រះនរបតី-ព្រះភូមិន្ទ-
ព្រះភូធរ ។

សទិសស័ព្ទ

**កំពង់-កំពុង**

កំពង់ ឬ កម្ពង់ = ន. ទីកន្លែងនៅមាត់ទឹក ដែលអ្នកដំណើរចុះឡើងឬចតទូកជាដើម : កំពង់ផែ, កំពង់ទឹក, កំពង់ទូក, កំពង់សោម...។

បញ្ចុះកំពង់ = ន. ជាពាក្យប្រើគោះបោះបោកគីស៊ី ។

កំពុង ឬ កម្ពុង (ម.ជ.កំពង់) គុ. អ្វីៗ ដែលកំពូលកណ្តាលឡើងមិនរាបស្មើ៖ពេញកំពុង, ដ្ឋាល់កំពុង ។

កំពុង = និ. កាលក្នុង, កាលដែលជាប់នៅក្នុងរវាង : កំពុងធ្វើការ, កំពុងតែរៀនសូត្រ ... ។

## ឯក - អែក

ឯក = (ម.ជ.អែក) សំ.បា. (ជាពាក្យបាលីនិងសំស្ក្រឹត) មួយ, ម្នាក់ ។
គុ. ដែលមានតែមួយ ឬតែម្នាក់, ឥតមានពីរ; ទីមួយ; លេខមួយ, ឧត្តម, ប្រសើរ ... : ល្អឯកា, ប្រសើរឯកា, ឯកាឯង ... ។

ពាក្យដែលផ្ដើមឡើងពី « ឯក » គឺ:

ឯកអគ្គ = អ្នកដែលមានខ្លួនប្រសើរបំផុត ។

ឯកកោលាហល = ដំណើរជ្រួលជ្រើមព្រមគ្នា ។

ឯកបថ = ដែលមានផ្លូវឬគន្លងតែមួយ ។

ឯករាត្រី = មួយយប់ ។

ឯកឧត្តម = អ្នកដែលធំជាងគេក្នុងមុខដំណែងណាមួយ ។ល។

អៃកឬឯក = ន. ប្រដាប់មួយយ៉ាង មានដងសណ្ឋានស្រដៀង
នឹងដងធ្នូ មានស្នាបតែមួយ សម្រាប់ដាក់
ភ្ជាប់នឹងក្បាលខ្វែងពួង : អែកខ្វែង ។
គួរសរសេរជា "អៃក" តែម្យ៉ាងយ៉ាងនេះដើម្បីកុំឲ្យ
ច្រឡំនឹងពាក្យ ឯក ខាងលើ ។

អក្ខរាវិរុទ្ធ

ទក្ខិណទិស ឬ ទិសទក្សិណ ។ ប្រិមប្រិយ ឬ
ប្រេមប្រិយ ។

សមុទ្ទ ឬ សមុទ្រ ។ កម្លាំង ឬ កំឡាំង ។

## ស្រះពិសេសដែលប្រើជាអញ្ញត្រស័ព្ទ (គ)

ស្រៈ "ឱ" អានជា អ៊ុ ៖

ឱកាស, ឱក្រិដ្ឋ, ឱឡារ, ឱណ្ណាលោម, ឱបុល, ឱត្តម, ឱត្តរ
ឱត្តុង្គ, ឱត្យាគ, ឱទរ, ឱទារ, ឱទាហរណ៍, ឱទ្ទន, ឱទ្ទម, ឱទ្ទិស

ឧទ្ធរណ៍, ឧទ្យាន, ឧបករណ៍, ឧបការ, ឧបការី, ឧបកិច្ច, ឧបជ្ឈាយ៍, ឧបដ្ឋាក, ឧបដ្ឋាន, ឧបដ្ឋាយិកា, ឧបត្ថម្ភ, ឧបទិស, ឧបទេស, ឧបទ្រព, ឧបនាយក, ឧបនាយិកា, ឧបនិស្ស័យ, ឧបភោគ, ឧបមា, ឧបមេយ្យ, ឧបយុវរាជ, ឧបយោគ, ឧបនាថ, ឧបសគ្គ, ឧបសម្បទា, ឧបហេតុ, ឧបាយកល, ឧបាសក, ឧបាសិកា, ឧបោសថ, ឧប្បត្តិ, ឧរគ្គ, ឧរា, ឧល្លោកន:, ឧស្សាហ៍, ឧស្សាហកម្ម, ឧឡារិក ។

ចំណាំ

## កំពុង ឬ កម្ពុង - កំពុង

ពាក្យ កំពុង ដែលជាគុណស័ព្ទហើយដែលមានន័យថា : អ៊ើ ៗ ដែលកំពូតកណ្ដាលឡើងមិនរាបស្មើ ដូចជា : ពេញកំពុង, ថ្ពាល់កំពុង គេអាចសរសេរជា កម្ពុង ក៏បាន ។

តែពាក្យ កំពុង ដែលជានិបាតស័ព្ទ គឺ: កាលក្នុង, កាលដែលជាប់នៅក្នុងរវាង ដូចជា : កំពុងធ្វើការ, កំពុងរៀនសូត្រ គេពុំអាចសរសេរជា កម្ពុង ទេ គឺសរសេរបានតែម្យ៉ាងជា កំពុង ។

## សំនួរ

១ – ចូរពន្យល់ពាក្យ : បញ្ចពិធកល្យាណី, សន្តិភាព, គម្ពីរភាព, អាជីវប្បវត្តិ ។

២ – ចូររកវេវចនសព្ទនៃពាក្យ : សង្គ្រាម ។

៣ – ចូររកសទិសសព្ទនៃពាក្យ : កំពុង ។

៤ – ចូរសម្ពន្ធប្រយោគទី ១ នៃអត្ថបទនេះ ។

៥ – ហេតុអ្វីបានជាដែនកូសាំងស៊ីន បានទៅជាសម្បត្តិរបស់យួន ? អ្នកស្តាយស្រណោះឬទេ ? ព្រោះអ្វី ?

# ជីវិតសាបសូន្យក្នុងអាថ៌កំបាំងលើនាវា

ព្រះទិនករនៅប៉ប្រះមាត់ព្រៃ ពុំទាន់អស្ដង្គតនៅឡើយទេ ។ អរុណរង្សីនៅភ្លឺប្រាល ចាំងមកលើព្រះរាជធានីជាទីអវសាន ។ មេឃស្រឡះថ្លាយង់រកពពកមួយដុំគ្មាន ស្រមោលធម្មជាតិធ្មុះចូលទៅក្នុងគង្គា ឃើញវែងអន្លាយហើយខ្មៅស្លុងៗ ។

គ្រឡាហោមគង់ អង្គុយនៅត្រមោចឯកឯងលើនាវាមានទឹកមុខក្រៀមក្រំជាពន្ទឹក ខំប្រឹងសម្លឹងមើលទៅត្រើយខាងលិចឃើញប៉មកំពែងព្រះបរមរាជវាំង និងប្រាង្គប្រាសាទភ្លឺចិញ្ចាចវិចិត្រដោយក្បាច់រចនាផ្សេងៗ មានបែបតាពងនិងកំពូលមណ្ឌបខ្ពស់ត្រដែតទៅលើ ។

កប៉ាល់បើកឃ្លាតពីវត្តឧណ្ណាលោម ឆ្ពោះត្រង់ទៅឯជើង ហើយៗ ព្រះសុរិយាក៏លិចស្រិចបាត់ទៅ ពេលព្រលប់ខិតចូលមកដល់ភ្លាម ធ្វើឲ្យស្រអាប់គ្រប់ទិសមួយរំពេច ។ មិនយូរប៉ុន្មាន

យប់ងងឹត  ក៏ចូលមកគ្រដាងគ្រប់លើផែនពសុធា  មើលអ្វីលែងឃើញទាំងអស់ ។

មុខគួរឲ្យសង្វេគពន់ពេក នៅលើកប៉ាល់ ក្រឡាហោមគង់ ដៃទាំងពីរជាប់ខ្នោះ ខំត្រដរដ្គងឡើងនូវអញ្ជលីក្រាបថ្វាយបង្គំលា ព្រះបរមរាជាពីចម្ងាយ ។ សេចក្ដីស្នេហាជាតិ មាតុភូមិ និងព្រះមហាក្សត្រិយ៍ នៅតែជិតជាប់ក្នុងដួងចិត្តបណ្ឌិតនេះជាដរាប ពុំមានប្រាសចាកទៅណាបន្តិច ។ ក្រឡាហោមគង់ លើកដៃប្រណម្យដោយលំបាក  ទឹកភ្នែកហូរសស្រាក់ធ្លាក់មកលើដើមទ្រូងសង្រេងសង្រៃអន្គួយសញ្ជឹងគិតថា : " ខ្លួនអាត្មាអញ ទៀងជាស្លាប់នឹងដៃបារាំងក្នុងគ្រានេះហើយ ។ ប្រហែលជា ឆ្អឹងអញពុំបានជ្រាបផងទេ ។ គំនិតនេះ ជាសេចក្ដីព្យាបាទរបស់ជាតិបរទេសធ្វើដោយអាថ៌កំបាំង មិនឲ្យអ្នកណាដឹង ។ សញ្ជឹងគិតដូច្នេះហើយ  ក្រឡាហោមគង់ ក៏ឆ្លៀតឱកាសប្រសិទ្ធពរថ្វាយបន្តិច ៗ ចំពោះព្រះភូសក្កថា : សូមព្រះអង្គស្ថិតនៅក្នុងសិរីរាជសម្បត្តិប្រកបដោយសុខុមាលភាព  និងវឌ្ឍនភាពដ៏រុងរឿង

គរៀនទៅ ។ ខ្ញុំទទួលព្រះបន្ទូលជាខ្ញុំ ពុំបាននៅយកអាសា ព្រះអង្គទៀតទេ មុខជានិកសប្រាសចាកពីព្រះអង្គក្នុងពេលឥឡូវ នេះហើយ ។

ប្រឡងសញ្ញាប័ត្របឋមសិក្សា (២០.៦.៦០)

ពន្យល់ពាក្យ

សាបសូន្យ = គុ. បាត់បង់, វិនាស ។ ជីវិតសាបសូន្យ គឺ ស្លាប់ ។

អាថ៌កំបាំង = ន. កិច្ចការសម្ងាត់ ដែលគ្មានអ្នកណាដឹង ព្ (Secret) ។

ព្រះទិនករ = ព្រះអាទិត្យ, ថ្ងៃ (Soleil) ។

អស្តង្គត = កិ. ឬ គុ. ដែលលិចបាត់ទៅហើយ ។ ព្រះអាទិត្យ អស្តង្គត គឺ ថ្ងៃលិច ។

អវសាន = ន. ទីបំផុត, ទីបប់, ចុងក្រោយ, ចុងបំផុត ។ ជាទីអវសាន គឺ នៅគ្រាក្រោយបំផុត ។

ប្រាង្គ = ន. ប្រាសាទដែលមានកំពូលខ្ពស់ ។

មណ្ឌប = ន. ផាក់, រោងលាតដែលសម្រាប់ប្រើមួយដងមួយ

កាល ។ ខ្មែរយើងច្រើនប្រើចំពោះ ប្រាសាទតូច

ដែលមានកំពូលសណ្ឋានដូចមកុដ ។

ដែនពសុធា = ន. ផែនដី ។

អញ្ជលី = ន. ការផ្គុំម្រាមដៃទាំង ១០ ឡើងសំពះគោរព ។

ព្រះភូសក្ក = ន. ព្រះរាជា, ស្ដេច ។

សិរីរាជសម្បត្តិ = ន. រាជសម្បត្តិដែលប្រកបដោយសេរីគ្នា

ឥតមកពីណាឡើយ ។

សុខមាលភាព = ន. ការប្រកបដោយសេចក្ដីសុខគ្រប់ប្រកា

(Bien-être) ។

អរុណរង្សី = ន. ( < អរុណ = ព្រះអាទិត្យ + រង្សី = ពន្លឺ )

ពន្លឺព្រះអាទិត្យ ។

វេវចនសព្ទ

ទិវាករ - ទិនករ - សុរិយា - ប្រភាករ - អរុណ

អាទិត្យ - ថ្ងៃ -

រង្សី - រស្មី - ពន្លឺ ។

សទិសសព្ទ

| អា–អារ–អាឃិ–អាថិ–អារ្យ អា! |
|---|

អា = ប្ុ.ស ពាក្យតាបឥតគួរសមសម្រាប់និយាយទៅរកមនុស្ស

ប្រុស = អាណា ? អាសុខ, អាឈ្លូត

អាតាញ្ញះចក្រាពត្តិ . . . ។

អា = គុ. ដែលមានគូរស្រករតែឥតមានកូនសោះ : ស្រីអា,

មេគោអា, អានាំផ្តុំពីរជាគាំប្ដីប្រពន្ធ ៗ 18

អា៎! ឧ. ជា ១. ពាក្យលាន់មាត់ដោយការងឿងឆ្ងល់, ដោយ

កន្តប្រឡំ, ដោយមានសូន : អា ! អ៊ូហ្វា !.

(Ah!) ។

អាបិ = ន. ( បាលី : អត្ថ, សំស្ក្រឹត : អថិ ) កិច្ចការដ៏ជ្រាលជ្រៅ ដែលជាសម្ងាត់ : ធម៌អាថ៌, អាថ៌កំបាំង . . . ។

អារ = កិ. កាត់, បំបែក, ច្រៀក, កាត់ផ្តាច់, គម្រឹមដោយរណារ: អារឈើ, អារបំបែក, អារគម្រឹម

អារ កូដ = ន. ស្ពាន ។

អាយ៌ = ( < ម. អគ្ប, សំ. អាយ៌ ) គុ. ដែល មានដម្លៃ, ថ្លៃ, ថ្លៃថ្លា : សម្តេចព្រះអយ៌អគ្គមហេសី

អារ្យ = (ម.ថ.អារយៈ) គុ. ប្រសើរ, ខ្ពង់ខ្ពស់ : អារ្យធម៌ ។

## ប្រសិទ្ធ - ប្រសិទ្ធិ

ប្រសិទ្ធ = ( ម.ថ. - សុិត ) កិ. ( ជាពាក្យសំស្ក្រឹត; បាលីជា បសិទ្ធ ) ធ្វើឲ្យសម្រេច, ធ្វើឲ្យពូកែ, ឲ្យមានសេរី

ជោគជ័យ : ប្រសិទ្ធពរ ៤ ប្រការ...។

សរសេរជា ប្រសិទ្ធិ ក៏បាន ។

ប្រសិទ្ធិ៍ = (ម.ថ.សិត) ន. ឈ្មោះកុំមួយកន្លែងត្រកណ្ដាលនៅខាង

ទិសពាយ័ព្យក្រុងភ្នំពេញ : ភុំប្រសិទ្ធ... ។

អត្ថាភិវុឌ្ឍ

ស្រិម ឬ ស្រឹម ។ រាជព័ង ឬ រាជវ័ង ។

អញ្ចលិ ឬ អញ្ចលី ។ សិរីរាជសម្បត្តិ ឬ

សេរីរាជសម្បត្តិ ។

| ស្រៈពិសេសដែលប្រើជាអញ្ញត្រស័ព្ទ |
|---|

(តបទ)

ស្រៈ " ឱ " អានថាអូរ ៖

ឪពុក, ឪទិន, ឪម៉ាល់, ឪឡឹក, ឪឡុង, ឪឡោក ។

ស្រៈ " ឫ " ៖

ឫក, ឫកពា, ឫស, ឫស្សី, ឫទ្ធិ,

## ស្រៈ " ឬ "

ឫទេ ? មានដែរឬ ?

## ស្រៈ " ឮ "

ខ្ញុំស្ដាប់ឮ , ឮសូរ ។

## ស្រៈ " ឯ " អានជាអែ

ឯកច្ឆន្ទ , ឯកចិត្ត, ឯកជន, ឯកទេស, ឯកស័ក, ឯករំ,
ឯកអគ្គរាជទូត , ឯកឧត្ដម, ឯង, ឯណេះ , ឯណោះ , ឯនាយ,

## ស្រៈ " ឰ " អានជាអៃ :

ឰដ៏ , ឰសូរ្យ , ឰការែន ,

## ស្រៈ " ឱ " អានជាអោ ៖

ឱកាស , ឱង្ការ , ឱទ្យាន , ឱក , ឱក់ទ , ឱសថ , ឱរស,
ឱស្រព ។

## សំណួរ

១– ចូរពន្យល់ពាក្យ : អស្តង្គត, មណ្ឌប, សុខុមាលភាព, អរុណរង្សី ។

២ – ចូររកវេវចនស័ព្ទនៃពាក្យ : ព្រះអាទិត្យ ។

៣ – ចូរសម្ពន្ធពាក្យ : ព្រះទិនករ ( ក្នុងឃ្លាទី ១) ។

៤ – ចូរអធិប្បាយអំពីគំនិតស្នេហា ជាតិរបស់ក្រឡាហោមគង់ ។

# បុណ្យភ្ជុំបិណ្ឌ

បុណ្យភ្ជុំបិណ្ឌ ជាបុណ្យដែលខ្មែរទាំងប្រទេស បាន
គ្រប់គ្នាឥតមានខាន ដើម្បីឧទ្ទិសរំលឹកដល់បុព្វបុរស និងញា
សាលោហិត ដែលបានទៅកាន់បរលោក ៗ បុណ្យនេះធ្វើបា
តែដប់ប្រាំថ្ងៃគត់ គឺថ្ងៃមួយរោចខែភទ្របទ ទៅទល់នឹង
ដាច់ខែ ៗ

ឧត្តមកិច្ចនេះ ពលរដ្ឋខ្មែរបានប្រកាន់តាំងពីបុរាណកាល
រៀងមក ព្រោះខ្មែរគ្រប់រូបគោរពអ្នកមានគុណ គោរពព្រះពុ
សាសនា ដែលជាសាសនារបស់រដ្ឋ មានសាមគ្គីធម៌រាប់រក
ដោយស្និទ្ធស្នាលក្នុងពិធីភ្ជុំបិណ្ឌនេះ ៗ

នៅគ្រប់តែវត្តអារាមក្នុងព្រះរាជាណាចក្រ ឧបាស
ឧបាសិកា ពុំគ្រាន់តែឧទ្ទិសដល់បុព្វការីបុគ្គលទាំងឡាយរប
ប៉ុណ្ណោះទេ ថែមទាំងឧទ្ទិសដល់ដួងវិញ្ញាណនៃខេមរកុមារ និងខេម
ជន អ្នកស្នេហាជាតិទាំងឡាយ ដែលបានទទួលមរណភា

នាសបរក្កមិ ក្នុងការបំរើមាតុប្រទេស និងឧទ្ទិសដល់វិញ្ញាណក្ខន្ធនៃអ្នកនិពន្ធនិងអ្នកកវីខ្មែរនានា ដែលបានបំរើអក្សរសាស្ត្រនិងវប្បធម៌ជាតិឲ្យមានកេរ្តិ៍ដំណែលឲ្យរុងរឿងស្តុកស្តម្ភជាភិយ្យោភាព ។

គំនរបុណ្យដែលកើតឡើងអំពីអាមិសទាននិងធម្មទាន ក្នុងបុណ្យកុំបិណ្ឌនេះ ពលរដ្ឋខ្មែរទាំងមូលបានឧទ្ទិសថ្វាយព្រះករុណាជាម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះមហាក្សត្រិយានី សូមព្រះអង្គទ្រង់ស្ថិតជាបរមសុខ ឈ្នះអស់មារសត្រូវ ហើយសូមកុសលទាំងនេះ ជួយដឹកនាំចិត្តជាតិខ្មែរ ឲ្យតែតែស្រឡាញ់ជាតិដោយស្វាមីភក្តិ ។

ជាពិសេស សូមឥដ្ឋមនុញ្ញផលនេះ ជួយប្រាន ជួយកំចាត់អំពើបំផ្លាញជាតិ ឲ្យវិនាសសាបសូន្យហើយបើវិនាសសាបសូន្យ ហើយសូមឲ្យសាមគ្គីធម៌ គង់វង់បុងបរិបូណ៌ ហាក់ដូចជាខ្សែវេញជាធ្លុងមួយ ។

ប្រឡងសញ្ញាប័ត្រមធ្យមសិក្សា (២៨.៣.៦០)

## ពន្យល់ពាក្យ

ឧទ្ទិស = កិ. បញ្ជូនកាផ្សាយផលបុណ្យចំពោះទៅអ្នកដែលធ្វើមរណកាលទៅហើយ ។

បុព្វបុរស = ន. បុរសជាន់ដើម, មនុស្សចាស់ជំនាន់មុន, ជីដូនជីតា ។

ញាតិសាលោហិត = ន. សាច់ញាតិ, បងប្អូនទាំងឡាយ ។

បរលោក = ន. លោកឯនាយ គឺកំណើតឯនាយដែលមិនមែនជាកំណើតសព្វថ្ងៃនេះ ហើយដែលយើងពុំដែលបានដឹង, បានស្គាល់ដល់ម្ដងណាសោះ ។

ឧត្តមកិច្ច = ន. កិច្ចការដ៏ប្រសើរ, ដ៏ខ្ពង់ខ្ពស់ ។

សាមគ្គីធម៌ = ន. ការព្រមព្រៀងគ្នា, ការស្រុះស្រួលមូលគំនិតគ្នា, ការពួតដៃគ្នាជាធ្លុងមួយ (Solidarité) ។

បុព្វការីបុគ្គល = ( < បុព្វ=មុន + ការី + បុគ្គល ) ន. អ្នកមាន
គុណដំបូង គឺមាតាបិតា ។

ខេមរភូមិន្ទ = ( < ខេមរ: ខ្មែរ + ភូមិន្ទ: ស្តេច ) ន. កងទ័ពខ្មែរ
ដែលស្ថិតនៅក្រោមអំណាចនៃព្រះរាជា គឺកង
ទ័ពខ្មែរសព្វថ្ងៃនេះ (Armée RoyaleKhmère ។
សរសេរកាត់ថា ខ.ភ.ម (ARK)

សមរភូមិ = ន. ទីចម្បាំង, លានសម្រាប់ច្បាំង, កន្លែងប្រយុទ្ធ
គ្នា ( (Champ de bataille ) ។

មាតុប្រទេស = ( < មាតុ: ម្តាយ + ប្រទេស ) ន. ប្រទេសដ៏ជា
ទីមានគុណប្រៀបដូចជាម្តាយ ។

វិញ្ញាណក្ខន្ធ = ន. ប្រជុំវិញ្ញាណ, គំនរវិញ្ញាណ ( Mémoire) ។
ពាក្យនេះច្រើនប្រើចំពោះតែបុគ្គលដែលស្លាប់ទៅហើយ ។

អ្នកនិពន្ធ = ន. អ្នកសរសេរ, តែងរឿងផ្សេងៗ (Ecrivain) ។

អ្នកករី = ន. អ្នកតែងកំណាព្យ (poète) ។

ភិយ្យោភាព = ន. (< ភិយ្យោ : ច្រើន + ភាវ) ដំណើរច្រើន

ក្រៃលែង, ភាវៈច្រើនលើសលប់ ។

អាមិសទាន = ន, ការឲ្យទានជាវត្ថុផ្សេង ៗ ។

ធម្មទាន = ន. ការឲ្យធម៌គឺការសំដែង, និយាយ, បង្រៀនធម៌ ។

ស្វាមីភក្តិ = ន. សេចក្ដីស្មោះត្រង់ឥតវៀចវេរ (Fidèleté) ។

ឥដ្ឋមនុញ្ញផល = (< ឥដ្ឋ : ជាទីពេញចិត្ត + មនុញ្ញផល) ន. ផល

ជាទីពេញចិត្តដែលបានសម្រេចដូចបំណង ។

វេវចនសព្ទ

មាតុប្រទេស-មាតុភូមិ ។

សទិសសព្ទ

ឥដ្ឋ-ឥត-ឥធលោក

ឥដ្ឋ = (ម.ថ.អិ:) ន. ដីស្អិត ដែលគេធ្វើជាសណ្ឋានផ្សេង

ហើយ ហាលថ្ងៃឲ្យស្ងួត រួចដុតឲ្យឆ្អិន សម្រាប់ប្រើការសំណង់តាំងឡាយ : ដុះឥដ្ឋ, កាំពែងឥដ្ឋ . . . ។ ដីឥដ្ឋ : ដីដែលប្រើការធ្វើឥដ្ឋកើត ។

ឥដ្ឋ = គុ. ដែលគួរប្រាថ្នា, ដែលត្រូវការ, ដែលជាទីពេញចិត្ត : ឥដ្ឋកាម្ម, ឥដ្ឋផល, ឥដ្ឋមនុញ្ញផល . . . ។

ឥត = និ. ពុំ, មិន, អត់ : ឥតមាន, ឥតដឹង, ឥតបានធ្វើ, ឥតមានប្រាក់ធ្វើទុន . . . ។

ឥធលោក = (ម.ប.អិធគ:) ន. លោកនេះ គឺលោកបច្ចុប្បន្ន ។

| វត្ត–វត្ស៍–វត្ថ–វធ–វាត់ |
|---|

វត្ត = ន. ការប្រព្រឹត្ត, សេចក្តីប្រតិបត្តិ, មុខការដែលត្រូវធ្វើ, ការកាន់សីលធម៌, សេចក្តីគោរព : មនុស្ស

មានវត្តល្អ, វត្តប្រតិបត្តិ, សិស្ស

យកវត្តគ្រូ... ។

វត្ត = ន. ទីអាស្រ័យរបស់ពួកសមណៈ: វត្តលោក, វត្ត

ឧណ្ណាលោម, វត្តស្រះចក, ក្មេង

វត្ត... ។

វត្ថ = (ម.ថ.វ័ត.ថៈ) ន. (ជាពាក្យបាលី, សំស្ក្រឹតជា វស្ត្រ) សំពត់ ។

ច្រើនប្រើផ្សំនឹងសព្ទឯទៀតដូចជា: វត្ថទាន, វត្ថ-

ពន្ធ, វត្ថាភរណៈ: វត្ថាលង្ការ,... ។

វត្សរ៍ = ន. ឆ្នាំ: បៀវត្សរ៍, សតវត្សរ៍ ។

វ័ធ = កិ. ក្តិះខ្វាំងដោយចុងស្នែង: ក្របីវ័ធ ។

វាត់ = កិ. រលាស់ចុះឡើង: វាត់សន្ទូច ។ រលាស់ចុងផុត

ឬរលាស់ចេញ: វាត់ដោយរំពាត់, វាយ

វាត់, វាត់មួយជើង ។

## សូន-សូន្យ

សូន = កិ. ប្រមូលគ្នីៗ ដែលមានសាច់ទន់ជ្រាយឲ្យកើត ជាដុំ, ជាគ្រាប់ ឬជារូប : សូនតុលិកា, សូនរូប . . . ។

សូន្យ = (ម. សុញ្ញ) គុ. ទទេ, ឥត, សោះទទេ : សូន្យឈឹង, ដដឹតសូន្យ . . . ។

## វិញ-វេញ

វិញ = និ. ទៀត, ដូចដែល : វិលវិញ, ត្រឡប់វិញ, ចេញទៅវិញ, ចូលមកវិញ . . . ។

វេញ = កិ. គ្របាញ់បញ្ចូលគ្នា : វេញខ្សែ, វេញជាដុំ មួយ ... ។

## មា - មារ

មា = ន. ពាក្យសម្រាប់កូនរបស់បងហៅបុរសជាប្អូនមាតា ឬបិតា:

ឪពុកមា, មាគ្រូ ...។

មារ = ន. ដំណើរកាំង, អ្នកកាំង: មារសត្រូវ ។

អក្ខរាវិរុទ្ធ

### អំពីជើង "ដ" និង "ត"

ជើង "ដ" និងជើង "ត" មានរាងដូចគ្នា គឺ "ដ" ។ ហេតុនេះយើងត្រូវចំណាំដូចតទៅ៖

១- បើវានៅពីក្រោម "ក" វាជា "ដ"

ឧទាហរណ៍ –

ក្ដីក្ដាំ ក្ដួលក្ដៅ ក្ដួប ក្ដៀង ។ល។ ...

២- បើវានៅក្រោម "ខ" វាជា "ត"

មានតែមួយម៉ាត់គឺ៖

ខ្ទត = មេមាន់ខ្ទត ។

## ៣-បើវានៅពីក្រោម "ធ" វាជា "ត"

ដូចជា

ធ្តោ = ត្រីធ្តោរ -

ធ្តៅ = មាសធ្តោរ ។

សំនួរ

១– ចូរពន្យល់ពាក្យ : បរលោក , បុព្វការី , សមរភូមិ , វិញ្ញាណក្ខន្ធ ។

២ – ចូររកវេវចនស័ព្ទនៃពាក្យ : រដ្ឋ ។

៣ – ចូររកសទិសស័ព្ទនៃពាក្យ : វិញ ។

៤ – ចូរសម្ពន្ធប្រយោគទី ២ នៃអត្ថបទនេះ ។

៥ - ហេតុអ្វីបានជាខ្មែរទម្លាប់ធ្វើបុណ្យភ្ជុំបិណ្ឌ ? បានប្រយោជន៍អ្វីខ្លះដល់ប្រទេសជាតិ ?

# ដំណើរជូជកជួបនឹងចេតបុត្រ

គ្រាណោះ ចេតបុត្រដើរព្រៃ កំពុងត្រាច់រង្គាត់ក្នុងព្រៃ ឮជូជកស្រែកទ្រហោយំ រកព្រះបាទស្រីវេស្សន្តរបរមពោធិសត្វ ដូច្នោះគួរ ចេតបុត្រក៏ស្រែកគំរាមទៅថា រឺយព្រាហ្មណ៍កញ្ចាស់ ម្ដេចក៏មកយំសោករកព្រះអង្គ បើដោយអញរំពឹងគិតមើលទៅ យល់ជាព្រាហ្មណ៍កញ្ចាស់ឯងនេះ មករកសុំទាន ទើបរាំខត្រាប់ មកដល់អាយ ក៏រាំសុំអ្វីមាលព្យាយ តាំងពីព្រះអង្គគង់នៅក្នុងព្រះរាជវាំង ដរាបមកគង់នៅក្នុងភ្នំគិរីវង្កត រាំនាំគ្នាសុំទាំងដំរី បច្ច័យនាគេន្ទ្រ ជាដំរីព្រះទីនាំងដ៏ប្រសើរ ពួករាំសុំសព្វសុំគ្រប់ ពុំគិតប្រណីដោយក្ដីតណ្ហាលោភលន់ ទាល់តែអ្នកនគរ ខឹងជាកោលាហលនាំគ្នាក្រាបបង្គំទូលប្ដឹងដល់សម្ដេចព្រះវរបិតា ឲ្យស្ដេចបំបរបង់ព្រះអង្គចេញចាកព្រះនគរ ព្រះអង្គភាងនាំព្រះរាជ-បុត្រាបុត្រីនិងព្រះរាជទេពី មកគង់នៅក្នុងព្រៃភ្នំគិរីវង្កត ៗ

ព្រាហ្មណ៍កញ្ចាស់នេះឯងហើយ ជាមនុស្សអបលក្ខណ៍ ចំដើរស្វះស្វែងមករកសុំព្រះរាជបុត្រាបុត្រី ដូចកលបក្សាបក្សី គឺកុកនោល កាលណាបានយល់ត្រីក្នុងបឹងត្រពាំងក្នុងរដូវប្រាំងរីងទឹកហែងហួតហើយ តែងហើរមកចាប់ចឹកជី ជកាបលុះតែអស់ ៗ ព្រាហ្មណ៍អប្រិយនេះឯង ជាមនុស្សពាលកំណាចអាថ តាមបំផ្លាញព្រះអង្គជាប្រាកដ វាមិនបេះរកឆើបុកលក់ទន្និញ ៗ ព្រាហ្មណ៍ចង្រៃអើយ កុំទន្ទឹងរកព្រះអង្គឡើយ អញពុំទុកជីវិតប្រស្តែងឲ្យរស់នៅតទៅទៀតទេ អញបាញ់នឹងធ្នូឲ្យត្រូវដើមទ្រូងរួចយកថ្លើមប្រមាត់ញាំភ្លា បូជាក្រុងពាលីធ្វើពលីការទេពតារក្សាប្រកភ្នំ ឯក្បាលប្រស្តែងសោតអញនឹងដោតថ្វាយអ្នកតានៅនាព្រៃភ្នំនេះ ៗ

ប្រឡងសញ្ញាប័ត្រមធ្យមសិក្សា (៨.៦.៥៩) 19

## ពន្យល់ពាក្យ

ក្សណនោះ = ពេលនោះ, ខណៈនោះ ៗ

ប្នើរព្រៃ = ន. អ្នកដើរព្រៃ, ព្រានព្រៃ ។

មាល្យាយ = គុ. ក្រៃ, ក្រៃពេក, ម៉្លេះ, អ្វីម្លេះ, ណាស់ ។

នាគេន្ទ្រ = ន. ស្ដេចដំរី, ដំរីដែលជាធំជាងគេ ។

តណ្ហា = ន. ចំណង់, សេចក្ដីស្រើបស្រាលដោយចំណ

(Passion) ។

កោលាហល = ន. ការច្របួលច្របល់, ការភ្ញាក់ផ្អើលនាំឲ្យរឹករ

នាំឲ្យជ្រួលជ្រើម ។

ទីតាំង = ន. ជំនិះ, យានជំនិះ ។

បំបរបង់ = កិ. បណ្ដេញឲ្យចេញផុតពីនគរ (Expulser) ។

ព្រះរាជទេពី = (រ-ស) ប្រពន្ធ ។

អបលក្ខណ៍ = គុ. ខាតលក្ខណ៍, ឥតបុណ្យ, ថោកទាប, ចង្រៃ

បានយល់ = បានឃើញ, បានដឹង ។

អប្រិយ = គុ. អាក្រក់, ឃោរឃៅ ។

ប្រស្ដែង = ពាក្យសម្រាប់ស្ត្រីជន ហៅអ្នកស្និទ្ធស្នាលនៅក្រោមបង្គាប់របស់ខ្លួនគឺអ្នក, ឯង, នាយ ... ។

បូជា = ន. ការថ្វាយឬជូនវត្ថុ ៗ ចំពោះបូជនីយបុគ្គល គឺបុគ្គលជាទីគោរព ។ ប្រើជាកិរិយាស័ព្ទក៏បាន ។

ពាលី = ន. ឈ្មោះស្ដេចស្វាមួយក្នុងរឿងរាមកេរ្ដិ៍ ។

ពលី = ការបូជា, សួយ, អាករ, ពន្ធដារ, ដង្វាយ, សំណែន, ការសង្គ្រោះ ។ ពលីការ = ន. ការធ្វើពលី ។ ខ្មែរច្រើនប្រើសំដៅចំពោះ ការបូជា, បួងសួងឬការតាំងបោមពិធីផ្សេង ៗ ។

ព្រាហ្មណ៍ = ន. មនុស្សដែលកំណត់តាមលទ្ធិបុរាណថាមានពូជដើមកើតអំពីព្រះឱស្ឋព្រហ្ម ។

គិរី = ន. ភ្នំ ។

ងី = កិ. ស៊ី ។

បេតបុត្រ = ន. ឈ្មោះព្រានព្រៃម្នាក់ នៅក្នុងរឿងវេស្សន្ត

ជាតក ។

ត្រាប់រង្គាត់ = កិ. ដើរផ្សងព្រេងអន្ទោលរសាត់អណ្តែតតែឯក

ឯង ។

### វេវចនស័ព្ទ

ក្សណៈ-ខណៈ-ពេល-វេលា ។

បិតា-ឪពុក-ឪ-ជនក ។

### សទិសស័ព្ទ

**ព្រាន-ព្រៀន**

ព្រាន = ន. ប្រមាញ់, នេសាទ : ព្រានព្រៃ, ព្រានម្រឹគ, ព្រានបក្សី, ព្រានសត្វ ... ។

ព្រៀន = កិ. បង្រៀន : ព្រៀនប្រដៅ ។

## បាត-បាត្រ-បាទ

បាត = ន. ផ្នែកខាងក្រោមនៃជំរៅ: បាតបឹង, បាតទន្លេ, បាតសមុទ្រ ។ ផ្ទៃដៃឬជើង : បាតដៃ បាតជើង ។ ស្រទាប់ថ្នាក់ទាបបំផុត : បាតសង្គម, មនុស្សបាតសង្គម : មនុស្សដែលមានឋានៈតូចទាបបំផុត ‑ ក្នុងសង្គម ។

បាត្រ= ន. ភាជន៍ធ្វើអំពីដែកសម្រាប់បព្វជិតក្នុងពុទ្ធសាសនាប្រើកាន់ទទួលចង្ហាន់ ; បាត្រដែក, បាត្រលោក, លោកបិណ្ឌបាត្រ... ។

បាទ = ន. ជើង ; ព្រះបាទ, បាទា ។

បាទ = ន. ឈ្មោះប្រាក់បូរាណដំឡៃ ៦០សេន : ប្រាក់បាទ ។

បាទ = និ. អើ; ពាក្យសម្រាប់បុរសឆ្លើយ ជំនួសពាក្យអើ :

ទាន! ហើយទាន! ទានទាន! ទៅស៊ី

ទានហ្ម៉ា! ទាន ... ។

## ព្រាម-ព្រាហ្មណ៍

ព្រាម = ១. ឈ្មោះស្វាមួយយ៉ាងសម្បូរខ្លៅពក់ ពោមត្រង់មុះ

សម្បូរពណ៌ប្រផេះស្រមូវ : ស្វាព្រាម ។

ព្រាហ្មណ៍ = ( សូមមើលសេចក្ដីពន្យល់ខាងលើ ) ។

## ត្រពាំង-ទំពាំង

ត្រពាំង = ១. ថ្លុកធំកើតពីមនុស្សជីកសំរាប់ឲ្យដក់ទឹក ឬ កើត

ដោយសារកម្លាំងទឹកហូរហោះក៏មាន ។

ទំពាំង = ១. ពន្លកឬស្សី ឬ បបុសជាដើម : ទំពាំងឬស្សី

ទំពាំងឬស្សីស្រុក , ទំពាំងស្ពុ

ឬស្សី ... ។

អក្ខរាវិរុទ្ធ

បុត្តឬបុត្រ ។ រាំងឬរ៉ង ។ ទ័នឬទាំង ។

រដូវឬរគូវ ។ ប្រស្ដែងឬព្រះស្ដែង ។

ទេវតាឬទេពតា ។ ពលិការឬពលីការ ។

**អំពីជើង "ឌ" និងជើង "ដ"** (ក)

## ៤ - បើវានៅពីក្រោម ណ វាជា "ឌ"

ដូចជា :

កណ្ឌូប , កណ្ដែងកណ្ដោប , កណ្ដាប់ស្រូវ ,
កណ្ដាល, បណ្ដែត, បណ្ដុះ, អណ្ឌូង ។ ល ។

## ៥ - បើវានៅពីក្រោម "ន" វាជា "ដ"

ដូចជា :

កន្ដាំង, បន្ដោង, បន្ដឹង, បន្ដ, អន្ដរជាតិ ។ល។

លើកលែងតែពាក្យ ៥ ម៉ាត់ខាងក្រោមចេញ ដែល

ត្រូវមានថា " ជ ,, ។ ពាក្យតាំង ៥ ម៉ាត់នោះគឺៈ

សន្ដាន = ពូជពង្ស, តំណត្រកូល (Paranté, consanguinité) ។

សន្ដោស = សេចក្ដីអាណិតអាសូរ, ការយោគយល់, សេចក្ដីអត់ទុន (Pitié-compassion) ។

អន្ដរធាន = សេចក្ដីវិនាស ; បាត់បង់ ។

ចិន្ដា = សេចក្ដីគិត, គំនិត (Pensée) ។

ចោរកន្ដារ = ផ្លូវឆ្ងាយដែលមានចោរ ។

ចំណាំ

ស្មើ-ស្មើរ

ក្នុងការសរសេរគេតែងប្រឡំពាក្យតាំងពីរម៉ាត់នេះគឺគេច្រើនសរសេរជា : " ស្មើរណេះ, ស្មើរណោះ" ដោយប្រឡំនឹងពាក្យ " ស្មើរ

ណោះ, ជើរណោះ " ។ ហេតុនេះត្រូវ

បំណាំដូចតទៅ ៖

ស្មើ = គុ.ឬ.កិ.វិ. ដែលប៉ុនគ្នា, ត្រូវគ្នា, មិនលើសមិនខ្វះពីគ្នា; រាប

ដូចគ្នា, ដែលជាកណ្តាល មិនលំអៀងទៅរក

ខាងណា : ឆ្លង់ស្មើគ្នា, ស្មើមុខ, រាប

អានស្មើ, ស្មើដោយជីវិត, ស្មើ

ហើយ ... ។

ជើរ = ន. ពេល, កាល : ជើរម៉ាងហើយ? ជើរណោះ,

ជើរណោះ ... ។

សំនួរ

១ ចូរពន្យល់ពាក្យ : នាគត្រូវ, គោលាហល,

ពលីការ, បំបរបង់ ។

២—ចូររកសទិសស័ព្ទនៃពាក្យ : រាប ។

៣- ចូរស្រង់កិរិយាស័ព្ទ ទាំងអស់ក្នុងអត្ថបទនេះ ។

៤ ព្រះវេស្សន្តរសុខចិត្តលះបង់កូន និងទ្រព្យសម្បត្តិឲ្យព្រាហ្មណ៍ដើម្បីបានត្រាស់ តើជាការប្រសើរឬទេ? អ្នកចូលចិត្តឬទេ? ព្រោះអ្វី?

# រឿងចចកនិងស្គរ

មានចចកមួយស្រេកឃ្លានខ្លាំង ដើរស្វះស្វែងរកអាហារ ត្រមង់ត្រមោចកាត់ព្រៃក្ខាលតាវល្វឹងគិរីបពិត បានឃើញស្នាម សមរភូមិចាស់មួយ ដែលកងទ័ពច្បាំងតតាំងគ្នា ។ សេនាទាហាន ដែលច្បាំងគ្នា ហើយដើរបាត់ទៅ បានចោលស្គរមួយទេរនៅ លើមែកឈើ ។ មែកឈើនោះ កាលបើមានខ្យល់បក់មក ក៏ ហាក់ដូចជាទៅវាយស្គរនោះឮស្គរទូងៗ ។ ចចកឮហើយភិតភ័យ តក្កមាញ៉ាំរន្ធត់សព្វសព៌ាង្គកាយគិតថា : "នុះអញអន្តរាយដល់ ហើយ បើទៅឆ្ងាយទៅក៏នឹងគេចចេញឲ្យផុត តែណ្ហើយចុះ គាត្នាអញមិនគួរប្រញាប់ប្រញាល់លះបង់ព្រៃជាទីឋានដ៏មនោរម ពីដូនពីតាទេ ព្រោះថាក្នុងគ្រាមានអាសន្ន ឬមានសេចក្ដីភ័យ មកដល់ ទស្សនវិទូមិនធ្វើកិច្ចការអ្វី ៗ ដោយរហ័សពេក គឺពិចារ ណា គេមិនក្ដៅក្រហាយកើតវិប្បដិសារីឡើយ ។ បើដូចនេះ

អាត្មាអញត្រូវចូលទៅមើលឲ្យបច្ចក្ខនឹងភ្នែក នូវសំឡេងនេះសិន ,, ។

បបកសម្តែងសេចក្តីក្លាហានយ៉ាងម៉ឺងម៉ាត់ ដើរតម្រង់ទៅជិតឃើញស្គរកញ្ចាស់មួយទើរនៅលើមែកឈើ ពិនិត្យឃើញយ៉ាងប្រត្យក្សថា កាលណាមានខ្យល់បក់មក មែកឈើដែលយោលទៅមកទៅប៉ះនឹងស្គរ ហាក់ដូចជាគេវាយស្គរទូង ៗ កាលណាឥតខ្យល់ក៏បាត់ឮស្គរទៅ ។ បបកយល់ច្បាស់ជាស្គរហើយ ក៏ដើរចូលទៅជិត យកដៃវាយលេង ដោយក្តីបំណងយ៉ាងបីតិក្រៃកាយ ហើយគិតថា: "ឱស្គរនេះបានជាភោជនាហារច្រើនណាស់ អាត្មាអញពុំដែលមានភ័ព្វវាសនាបានអាហារច្រើនម៉្លេះទេ ខាងក្នុងប្រហែលជាពោរពេញទៅដោយសាច់និងខ្លាញ់ច្រើនអនេកប្បការហើយ ,, ។ ខណៈនោះ បបកក៏ខំប្រឹងកកេរបោះទម្លុះស្បែកពាសស្គរនឹងក្រៀមក្រោះ ក្បាលចូលទៅខាងក្នុងដោយចិត្តសោមនស្សក្រៃលែង ដល់ហើយគ្មានឃើញ

ពីកើតក្ដីអាក់អន់ចិត្ត ពោលជាពាក្យស្លោកថា : " ទូន់ៗជួបស្គរ ខាន់ក្នុងប្រហោងផ្នង់ " ។

ប្រឡងសញ្ញាប័ត្រមធ្យមសិក្សា ( ២១.៦.៦០ )

## ពន្យល់ពាក្យ

ត្រមង់ត្រមោប = គុ. តែម្នាក់ឯង ។

វ្រក្ស = ន. ឈើទាំងឡាយ ។ ឯ.ក. វ្រក្ស ។

លតា = ន. វល្លិ ។ ច្រើនប្រើទាំងពីរជា ៖ លតាវល្លិ ។

បពិត ឬ បរពត = ន. ភ្នំ ។

សមរភូមិ = ( មើលសេចក្ដីពន្យល់ក្នុងអត្ថបទបុណ្យភ្ជុំបិណ្ឌ ) ។

ភ័យតក្កមា = ភ័យញាប់ញ័ររន្ធត់ ។

សព៌ាង្គកាយ = ( < សព្វ + អង្គ + កាយ ) ន. ពេញទាំងខ្លួន ។

ច្រើនប្រើជា : សព្វសព៌ាង្គកាយ ។

អន្តរាយ = ន. សេចក្ដីវិនាស ។

មនោរម = គុ. ដែលជាទីសប្បាយក្នុងចិត្ត, ដែលគួរឲ្យរីករាយ
ក្នុងចិត្ត ។

អាសង្ក = ន. ភ័យ, ហេតុអ្វីៗដែលគួរឲ្យភ័យ, គ្រោះថ្នាក់ផ្សេងៗ ។

ទស្សនវិទូ = ន. អ្នកប្រាជ្ញខាងទស្សនវិជ្ជា (Philosophe) ។

វិប្បដិសារី = ន. សេចក្ដីសោកស្ដាយ ក្រោយពេលដែលបាន
ប្រព្រឹត្តសេចក្ដីខុសឆ្គងណាមួយ (Remords) ។

បីតិ = ន. សេចក្ដីរីករាយដែលកើតឡើងភ្លាមៗ ។

ភោជនាហារ = ន. ( <ភោជ+អាហារ ) អាហារសម្រាប់
បរិភោគ ។

វិសជ្ជា = ( សូមមើលសេចក្ដីពន្យល់ក្នុងអត្ថបទខាងដើម ) ។

វេវចនស័ព្ទ

ខ្យល់-ជំនោរ-វាយោ-ព្រះពាយ ។

សេនា-ពល ទាហាន-កងទ័ព ។

## អក្ខរាវិរុទ្ធ

*បរពត ឬ បព៌ត ។ មនោរម ឬ មនោរម្យ ។*

| អំពីជើង « ដ » និងជើង « ត » | (តចប់) |
|---|---|

៦ – បើវាទៅពីក្រោម «ស» វាជា «ដ» ផង «ត» ផង

### ផ្នែកខាង « ដ »

ស្ដ, ស្ដន, ស្ដម្ភ, ស្ដាប់, ស្ដាយ ស្ដារ, ស្ដី, ស្ដឹង, ស្ដឺត,
ស្ដុក, ស្ដូក, ស្ដួបស្ដើង, ស្ដៀង, ស្ដៀន, ស្ដេប, ស្ដែង, ស្ដោះ
ស្ដៅ, ស្ដាំ ។

### ផ្នែកខាង « ត »

ស្តត, ស្តនិកសត្វ, ស្តា, ស្តឹក, ស្តុកិកឋា, ស្តុល, ស្តូប,
ស្តែត, ស្តោ, ស្តោក· ស្តោបតាការ· ស្ត្រី ។

## ចំណាំ

**គួរ**

ពាក្យនេះគ្មានសរសេរជា «គួ» យ៉ាងនេះទេ មានតែ «គួរ» សរសេរជា «គ+ួ+រ» ។ ពាក្យ «គួរ» នេះ មាន ៣ យ៉ាងគឺ ៖

គួរ = គុ. សម, គប្បី, ឥតទាស់ : គួរសម, គួរដែរ, ពាក្យនោះគួរហើយ ។

គួរ ឬ គួរតែ = អា-និ-សម, សមតែ, ល្មមតែ : គួរខ្លាច, គួរចៀសវាង កុំលក់ខ្លួនបំរើចក្រ-ពត្តិ, គួរស្រឡាញ់ឧត្តមគតិ ជាមនុស្ស ... ។

គួរ = ន. ចង្កោមផ្លែ : គួរស្រូវ, គួរអម្ពិល ... ។

## សំណួរ

១ – ចូរពន្យល់ពាក្យ : សមរភូមិ, សពាង្គកាយ, អន្តរាយ,
ទស្សនវិទូ, វិប្បដិសារី ។

២ - ចូររកវេវចនសព្ទនៃពាក្យ : បពិត ។

៣ – ចូរញែកពាក្យ : " សព្វសពាង្គកាយ " ឲ្យដាច់
ចេញពីគ្នា ហើយពន្យល់ន័យរបស់ពាក្យនេះ
ឲ្យច្បាស់លាស់ផង ។

៤ – អត្ថបទនេះអាចហុចដំបូន្មានឲ្យយើងដូចម្ដេចខ្លះ ?

ចប់

អវសានកថា

ដោយសៀវភៅនេះមានទំព័រច្រើនហួសពេកទៅហើយ ហេតុនេះទើបយើងដកអត្ថបទចេញខ្លះ ទាំងឲ្យមិនគ្រប់ចំនួន ៥០ ដូចយើងបានផ្សាយនៅលើក្របខាងមុខ។

សូមអភ័យទោស !

រោងពុម្ព ឥនិមិត្ត

តម្លៃ ៤០៛០០